ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Nov-2015, 15:00
CMS/CFO: Sann Rada

**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញាអន្តរជាតិ

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់/Confidential

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស: សម្ងាត់/Confidential

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សារណាលើបញ្ហាថាតើ អ៊ឹម ចែម គួរត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" ឬ ក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរឬយ៉ាងណា ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តិឡើង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ**

---

**ដាក់ដោយ៖**

**សហព្រះរាជអាជ្ញាអន្តរជាតិ៖**
Nicholas KOUMJIAN

**ចម្លងជូន៖**

**សហព្រះរាជអាជ្ញាជាតិ៖**
ជា លាង

**ផ្ញើជូន៖**

**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Mark B. HARMON

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤ ទាំងអស់**

**សហមេធាវីការពារក្ដី អោ អាន**
មុំ លុច្ឆ
Göran SLUITER
Richard ROGERS

**សហមេធាវីការពារក្ដី អ៊ឹម ចែម**
ប៊ិត ស៊ាងលីម
John R.W.D. Jones QC

## I. សេចក្ដីផ្ដើម

1. សហព្រះរាជអាជ្ញាអន្តរជាតិ សូមធ្វើការឆ្លើយតបទៅនឹង ដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេត ដែលអញ្ជើញភាគីនានាឲ្យដាក់ការកត់សម្គាល់របស់ខ្លួន អំពីថាតើសហចៅក្រមស៊ើបអង្កេត គួរចាត់ទុកថា អ៊ឹម ចែមជា "មេដឹកនាំជាន់ខ្ពស់" ឬក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងពេលចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩"[1]។

## II. ច្បាប់ជាធរមាន

2. ទាំងកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក[2] និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[3] បានចែងថាគោលបំណងនៃការបង្កើតតុលាការនេះគឺដើម្បី "កាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩។ មាត្រា ២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.កចែងថា យុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក គ្របលើ "មេដឹកនាំជាន់ខ្ពស់" និងអ្នក "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងពេលពាក់ព័ន្ធ[4]។ នៅក្នុងសំណុំរឿង ឌុច អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការសម្រេចថាតើជនជាប់ចោទជា "មេដឹកនាំជាន់ខ្ពស់" ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរឬយ៉ាងណានោះ គឺជាបញ្ហាដែលមិនត្រូវវិនិច្ឆ័យ ហើយស្ថិតលើឆន្ទានុសិទ្ធិទាំងស្រុង[5]របស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត៖

---

[1] ឯកសារ D251 សំណើសុំដាក់សារណាថាតើ អ៊ឹម ចែម គួរត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" ឬក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥ ("សំណើ")។

[2] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធការជំនុំជម្រះតាមច្បាប់កម្ពុជា ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣, មាត្រា ១ (ចាប់ពីនេះទៅគឺ "កិច្ចព្រមព្រៀងស្តីពីការបង្កើតអ.វ.ត.ក")។

[3] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ រួមទាំងវិសោធនកម្មដែលត្រូវបានប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤, មាត្រា ១ ("ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក")។

[4] ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក, មាត្រា ២។

[5] ឯកសារ F28 សាលដីកាលើសំណុំរឿង ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២, នៅត្រង់កថាខណ្ឌ ៧៩ ["ពាក្យពេចន៍ "ទទួលខុសត្រូវខ្ពស់បំផុត" គឺជាបញ្ហានៃគោលការណ៍ណែនាំនៃការស៊ើបអង្កេត និងការចោទប្រកាន់សម្រាប់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត នៅក្នុងការប្រើឆន្ទានុសិទ្ធិរបស់ខ្លួនដោយឯករាជ្យ ក្នុងពេលចោទប្រកាន់ និងស៊ើបអង្កេតទៅលើជន

"ពាក្យពេចន៍ "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" មិនមែនជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.កនោះទេ ប៉ុន្តែពាក្យពេចន៍នេះគឺជាគោលការណ៍នៃការស៊ើបអង្កេត និងការចោទប្រកាន់ទាំងស្រុង ក្នុងការណែនាំដល់ឆន្ទានុសិទ្ធិឯករាជ្យ របស់សហព្រះរាជអាជ្ញា និង សហចៅក្រមស៊ើបអង្កេត នូវមធ្យោបាយល្អបំផុតមួយក្នុងការប្រើប្រាស់ ធនធានដែលមានកម្រិតរបស់ខ្លួន ដើម្បីសម្រេចគោលបំណងនៃការបង្កើត អ.វ.ត.ក"[6]។

3. ពាក្យ "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" មិនត្រូវបានកំណត់និយមន័យបន្ថែមទៀតឡើយ ទាំងនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក៏ដូចជាកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក។ មាត្រា ៣១ ដល់៣៣ នៃអនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីច្បាប់សន្ធិសញ្ញា[7] ចែងថាសន្ធិសញ្ញាគួរត្រូវបានបកស្រាយ "ដោយសុទ្ធចិត្ត" និងស្របទៅតាម "អត្ថន័យទូទៅ" នៃពាក្យពេចន៍របស់ខ្លួន "នៅក្នុងបរិបទរបស់សន្ធិសញ្ញានោះ ហើយស្របតាមគោលដៅ និងគោលបំណងរបស់សន្ធិសញ្ញានោះ"[8]។ ដើម្បីបកស្រាយអត្ថន័យរបស់បទប្បញ្ញត្តិនៃសន្ធិសញ្ញា វិធាននៃអនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីច្បាប់សន្ធិសញ្ញា ក៏បានអនុញ្ញាតឲ្យពឹងផ្អែកទៅលើការងារត្រៀមរៀបចំ និងកាលៈទេសៈនៃការសន្និដ្ឋានលើ

ល្មើស ដែលបានប្រព្រឹត្តអំពើល្មើសយ៉ាងធ្ងន់ធ្ងរបំផុត ដែលជននេះស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក"] ហើយកថាខណ្ឌ ៨០ ["នៅក្នុងបរិបទរបស់ អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងមានអំណាច ក្នុងការពិនិត្យមើលឡើងវិញលើឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត ដោយផ្អែកលើការចោទឡើងថា សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត បានប្រើប្រាស់ឆន្ទានុសិទ្ធិដែលមានចែង នៅក្នុងមាត្រា ៥(៣) និង៦(៣) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលដោយពុំសុទ្ធចិត និងមិនស្របទៅតាមការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈត្រឹមត្រូវ។ អំណាចពិនិត្យមើលឡើងវិញរបស់ អង្គជំនុំជម្រះសាលាដំបូងមាន វិសាលភាពតិចតួចបំផុត ហើយត្រូវប្រើប្រាស់ដោយគោរពឲ្យបានពេញលេញ ចំពោះឯករាជ្យភាពរបស់ការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេត។ អំណាចពិនិត្យមើលឡើងវិញនេះមិនអាចប្រើប្រាស់ទៅតាមការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូងដែលថា សហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត ពុំបានជ្រើសរើស "មេដឹកនាំជាន់ខ្ពស់" ឬជនណាមួយដែល "ទទួលខុសត្រូវខ្ពស់បំផុត"នោះ""]។

[6] ឯកសារ F28 សាលដីកាលើសំណុំរឿង ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២, នៅត្រង់កថាខណ្ឌ ៧៩។

[7] អនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីច្បាប់សន្ធិសញ្ញា, 115 U.N.T.S 331, ចុះហត្ថលេខានៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៦៩ ចូលជាធរមានថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៨០, 115 UNTS 331 ("អនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីច្បាប់សន្ធិសញ្ញា").

[8] អនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីច្បាប់សន្ធិសញ្ញា, មាត្រា ៣១(១) ។ អនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីច្បាប់សន្ធិសញ្ញា រវាងរដ្ឋនិងអង្គការអន្តរជាតិ ឬរវាងអង្គការអន្តរជាតិនានា, 25 I.L.M 543, អនុម័តនៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៨៦ ("អនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីច្បាប់សន្ធិសញ្ញា រវាងរដ្ឋនិងអង្គការអន្តរជាតិ ឬរវាងអង្គការអន្តរជាតិនានា") មាត្រា ៣១(១)។

សន្ធិសញ្ញា ដើម្បីបញ្ជាក់បំភ្លឺលើពាក្យពេចន៍ ដែលអត្ថន័យទូទៅរបស់វា មានភាពមិនច្បាស់លាស់ ឬ ស្រពិចស្រពិល[9]។

4. ដោយផ្អែកលើការវិភាគយ៉ាងលម្អិតទៅលើ ការងារត្រៀមរៀបចំ និងប្រវត្តិនៃការចរចាសម្រាប់ កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក[10] អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ឌុច យល់ឃើញថាពាក្យ "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" សំដៅទៅរកប្រភេទនៃកម្មាភិបាលខ្មែរក្រហមពីរផ្សេងពីគ្នា៖

> ប្រភេទទីមួយ គឺជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ពីព្រោះមេដឹកនាំជាន់ខ្ពស់ម្នាក់មិនមែនជាជនសង្ស័យ ដោយផ្អែកតែទៅលើតួនាទីជាអ្នកដឹកនាំរបស់ខ្លួនប៉ុណ្ណោះទេ។ ប្រភេទមួយផ្សេងទៀត គឺជាអ្នកដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ប៉ុន្តែជាអ្នកស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតផងដែរ[11]។

ហេតុដូច្នេះប្រសិនបើជនត្រូវចោទគឺជាកម្មាភិបាលខ្មែរក្រហម គាត់មិនចាំបាច់ត្រូវតែជាមេដឹកនាំជាន់ខ្ពស់ ទើបអាចក្លាយជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះឡើយ។

*អ្នកទទួលខុសត្រូវខ្ពស់បំផុត*

5. ក្នុងការសម្រេចថាតើបុគ្គលម្នាក់គឺជា អ្នកទទួលខុសត្រូវខ្ពស់បំផុតដែរឬអត់ ចំពោះឧក្រិដ្ឋកម្មអន្តរជាតិ អ.វ.ត.ក ក៏ដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិនានា បានអនុម័តយកលក្ខណៈវិនិច្ឆ័យចំនួនពីរ៖ ស្ថានទម្ងន់នៃបទឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ប្រឆាំងបុគ្គល និងកម្រិតនៃការទទួលខុសត្រូវរបស់បុគ្គល ដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់នេះ[12]។

6. តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (តុលាការ ICTY) មានអាណត្តិការងារដែលជាផ្នែកមួយ នៃយុទ្ធសាស្ត្របញ្ចប់ភារកិច្ចរបស់ខ្លួន ដើម្បីផ្តោតទៅលើ "មេដឹកនាំជាន់

---

[9] អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា, មាត្រា ៣១(២)(ខ)។ អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញារវាងរដ្ឋនិងអង្គការអន្តរជាតិ ឬរវាងអង្គការអន្តរជាតិនានា, មាត្រា ៣២(ក)។

[10] ឯកសារ F28 សាលដីកាលើសំណុំរឿង ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ នៅត្រង់កថាខណ្ឌ ៤៦ ដល់៥៧។

[11] ឯកសារ F28 សាលដីកាលើសំណុំរឿង ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២, នៅត្រង់កថាខណ្ឌ ៥៧។

[12] ឯកសារ **D251** សំណើ, នៅត្រង់កថាខណ្ឌ ៣។

ខ្ពស់បំផុត ដែលមានការទទួលខុសត្រូវខ្ពស់បំផុត"[13] ហើយចារីដទៃដែលនៅសល់ត្រូវបញ្ជូន ទៅជំនុំជម្រះនៅកម្រិតថ្នាក់ជាតិ[14]។ ក្នុងការវាយតម្លៃអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ក្រុមប្រឹក្សាបញ្ជូនសំណុំរឿងរបស់តុលាការ ICTY បានពិចារណាពី "ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់" និង "កម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ"[15]។ គោលការណ៍ទាំងពីរនេះត្រូវបានឆ្លុះបញ្ចាំងផងដែរ នៅក្នុងសេចក្តីសម្រេចរបស់តុលាការពិសេស សម្រាប់ប្រទេសសេរ៉ាឡេអូន[16] សេចក្តីថ្លែងការណ៍របស់រដ្ឋអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិ[17] និងត្រូវបានអនុម័តយកដោយអង្គ

---

[13] សេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ 1534, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៤, UN Doc. No. S/Res/1534, កថាខណ្ឌ ៥ដល់៦។ សេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ 1503, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៣, UN Doc. No. S/Res/1503, កថាខណ្ឌ ៧។

[14] វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់ តុលាការ ICTY, វិធាន ១១ស្ទួន [ផ្ទេរពីដំណើរការនៃការផ្ទេររឿងក្តី ទៅតុលាការថ្នាក់ជាតិមានសមត្ថកិច្ច]។ វិធាន ១១ស្ទួន យោងទៅរកសេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខ 1534 និងបានបញ្ជាក់ថា តុលាការ ICTY និងពិចារណាលើ "ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់" និង "កម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ" ក្នុងការសម្រេចថាតើត្រូវបញ្ជូនរឿងក្តី ដែរឬយ៉ាងណា។ សូមមើលផងដែរ សូមមើលផងដែរ រដ្ឋអាជ្ញា តទល់នឹង *Dragomir Milošević*, IT-98-29/1-PT, សេចក្តីសម្រេចលើការបញ្ជូនរឿងក្តី អនុលោមតាមវិធាន ១១ស្ទួន, ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៥, នៅត្រង់កថាខណ្ឌ ១ ដល់៣ (រៀបរាប់ពីដំណើរការបញ្ជូន) (ចាប់ពីពេលនេះទៅគឺ សេចក្តីសម្រេចបញ្ជូនរឿងក្តី *Milošević*).

[15] រដ្ឋអាជ្ញា តទល់នឹង *Lukić*, IT-98-32/1-PT, ICTY, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៧, នៅត្រង់កថាខណ្ឌ ២៦ (ចាប់ពីពេលនេះទៅគឺសេចក្តីសម្រេចបញ្ជូនរឿងក្តី *Lukić* )។

[16] នៅក្នុងសេចក្តីសម្រេចលើញត្តិបឋមរបស់មេធាវីការពារក្តី ស្តីពីកង្វះយុត្តាធិការលើបុគ្គល ដែលញត្តិត្រូវបានដាក់ក្នុងនាមជនជាប់ចោទ *Fofana,* អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ SCSL បានដកស្រង់ *travaux preparatoires*។ "ទោះបីជាអ្នក "ទទួលខុសត្រូវខ្ពស់បំផុត" ប្រាកដជារួមបញ្ចូលមេដឹកនាំយោធា និងនយោបាយក៏ដោយ ប៉ុន្តែអ្នកដែលមានអំណាចបញ្ជា នៅក្នុងបណ្តាញបញ្ជា អាចត្រូវបានចាត់ទុកផងដែរថាជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដោយវិនិច្ឆយទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ឬទំហំដ៏ធំធេងរបស់ឧក្រិដ្ឋកម្មនោះ។ ហេតុដូច្នេះ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" សំដៅលើថ្នាក់ដឹកនាំ ឬតួនាទីមានអំណាចរបស់ជនជាប់ចោទ ព្រមទាំងការយល់ឃើញពីភាពធ្ងន់ធ្ងរ ស្ថានទម្ងន់ ឬទំហំធំធេងនៃឧក្រិដ្ឋកម្ម" (*រដ្ឋអាជ្ញា តទល់នឹង* Norman, *Fofana, និង Kondewa* SCSL-2004-14-PT, សេចក្តីសម្រេចលើញត្តិបឋមរបស់មេធាវីការពារក្តី ស្តីពីកង្វះយុត្តាធិការលើបុគ្គល ដែលញត្តិត្រូវបានដាក់ក្នុងនាមជនជាប់ចោទ *Fofana* (អង្គជំនុំជម្រះសាលាដំបូង), ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៤, នៅត្រង់កថាខណ្ឌ ២២)។

[17] ICC OTP, ឯកសារស្តីពីបញ្ហាគោលនយោបាយមួយចំនួន នៅចំពោះមុខការិយាល័យរដ្ឋអាជ្ញា, តុលាការព្រហ្មទណ្ឌអន្តរជាតិ, ខែ កញ្ញា ឆ្នាំ ២០០៣, ទំព័រ ៧ ["ទស្សនទាននៃភាពធ្ងន់ធ្ងរ មិនគួរត្រូវបានភ្ជាប់តែជាមួយអំពើសកម្ម ដែលបង្កើតបានជាឧក្រិដ្ឋកម្មនោះឡើយ ប៉ុន្តែត្រូវភ្ជាប់ជាមួយកម្រិតនៃការចូលរួម ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មផង"]

ជំនុំជម្រះសាលាដំបូង[18] អង្គជំនុំជម្រះតុលាការកំពូល[19] និងសហចៅក្រមស៊ើបអង្កេត[20] របស់អ.វ.ត.ក។ ការអនុវត្តគោលការណ៍ទាំងពីរនេះ មិនតម្រូវឱ្យមានការប្រៀបធៀប និងការចាត់ចំណាត់ថ្នាក់ ការទទួលខុសត្រូវរបស់ចារីទាំងអស់ឡើយ[21] ប៉ុន្តែជាជំនួសវិញគួរគិតគូរដល់សំណុំរឿងដទៃទៀត ដែលត្រូវបានជំនុំជម្រះដោយអង្គជំនុំជម្រះ និងកាលៈទេសៈពិសេសនៃទំនាស់[22]។

7. កត្តាពាក់ព័ន្ធដើម្បីសម្រេចលើស្ថានទម្ងន់ នៃបទល្មើសដែលបានប្រព្រឹត្តរួមមាន៖ វិសាលភាពភូមិសាស្ត្រ និងពេលវេលានៃបទឧក្រិដ្ឋកម្ម[23] លក្ខណៈនៃការប្រព្រឹត្តិបទឧក្រិដ្ឋនោះ[24] ចំនួននៃឧប្បត្តិហេតុ[25]

---

[18] ឯកសារ **E188** សាលក្រមសំណុំរឿង ០០១ (ឌុច), ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, នៅត្រង់កថាខណ្ឌ ២២ [បានវិភាគអំពីលក្ខខណ្ឌតម្រូវយុត្តាធិការ]។

[19] ឯកសារ F28 សាលដីកាលើសំណុះរឿង ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២, នៅត្រង់កថាខណ្ឌ ៧១ ["លក្ខណៈវិនិច្ឆ័យសម្រាប់ការបែងចែកបែបនេះ ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ ត្រូវបានប្រើប្រាស់មិនមែនសម្រាប់ត្រឹមជារបាំងយុត្តាធិការប៉ុណ្ណោះទេ ប៉ុន្តែត្រូវបានប្រើប្រាស់ជាគោលនយោបាយជំនុំជម្រះ"]។

[20] ឯកសារ ***CF3*-D48** សេចក្តីសម្រេចលើយុត្តាធិការបុគ្គល និងគោលនយោបាយស៊ើបអង្កេត ពាក់ព័ន្ធជនសង្ស័យមាស មុត, ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១២, នៅត្រង់កថាខណ្ឌ ១៥ ដល់១៦។ ឯកសារ ***CF3*-D49** សេចក្តីសម្រេចលើយុត្តាធិការបុគ្គល និងគោលនយោបាយស៊ើបអង្កេត ពាក់ព័ន្ធជនសង្ស័យសូ ម៉េត, ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១២, នៅត្រង់កថាខណ្ឌ ១៥ ដល់១៦។

[21] ឯកសារ F28 សាលដីកាលើសំណុះរឿង ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២, នៅត្រង់កថាខណ្ឌ ៦២ ["ទីមួយ ពុំមានវិធីសាស្ត្រជាសត្យានុម័តសម្រាប់ អង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេច ធ្វើការប្រៀបធៀប និងធ្វើការកំណត់ចំណាត់ថ្នាក់ នៃការទទួលខុសត្រូវព្រហ្មទណ្ឌ របស់កម្មាភិបាលខ្មែរក្រហមទាំងអស់បានឡើយ។ ទីពីរ សញ្ញាណនៃការទទួលខុសត្រូវ ផ្នែកព្រហ្មទណ្ឌដែលយកមកប្រៀបធៀបគ្នានេះ គឺផ្ទុយទៅនឹងមាត្រា ២៩ ថ្មី នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ដែលចែងថា "តួនាទី ឬឋានៈរបស់ជនសង្ស័យមិនអាចជួយជននេះ ឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ឬជួយបន្ថយទណ្ឌកម្មដល់ជននេះបានឡើយ ... ការធ្វើបែបនេះគឺមានន័យស្មើនឹង ការបង្កើតឱ្យមានមធ្យោបាយការពារដោយប្រយោល ដោយមូលហេតុបញ្ជារបស់ថ្នាក់លើ ហើយផ្ទុយនឹងបទប្បញ្ញត្តិនានា ដែលមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក"]។

[22] រដ្ឋអាជ្ញា តទល់នឹង *Ademi* និង *Norac*, IT-04-78-PT, សេចក្តីសម្រេចស្តីពីការបញ្ជូនរឿងក្តី អនុលោមតាមវិធាន ១១ស្ទួន, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៥ (*សេចក្តីសម្រេចបញ្ជូនរឿងក្តី Ademi*) នៅត្រង់កថាខណ្ឌ ២៨ ["ទោះបីជាស្ថានទម្ងន់នៃឧក្រិដ្ឋកម្មជាក់លាក់ទាំងអស់នេះ មានភាពធ្ងន់ធ្ងរ ឬមិនធ្ងន់ធ្ងរ ដែលតម្រូវឱ្យមានការជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះ ប៉ុន្តែអាស្រ័យទៅលើកាលៈទេសៈ និងបរិបទដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត ហើយចាំបាច់ត្រូវពិនិត្យមើលនៅក្នុងបរិបទ នៃរឿងក្តីដទៃទៀត ដែលត្រូវបានជំនុំជម្រះដោយតុលាការនេះ"]។

[23] រដ្ឋអាជ្ញា តទល់នឹង *Janković*, IT-96-23/2-AR11bis.2, សេចក្តីសម្រេចលើការបញ្ជូនរឿងក្តីអនុលោមតាមវិធាន ១១ស្ទួន, ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥, (ចាប់ពីពេលនេះទៅហៅថា សេចក្តីសម្រេចបញ្ជូនរឿងក្តី *Jankovic*) នៅត្រង់កថាខណ្ឌ ១៩។

និងចំនួនជនរងគ្រោះ[26]។ ការវាយតម្លៃទៅលើកត្តាទាំងអស់នេះ មិនគួរជាលំហាត់គណិតវិទ្យាតឹងរ៉ឹងឡើយ ប៉ុន្តែតម្រូវឲ្យមានការវិភាគលាយឡំរួមគ្នា[27]។

8. កត្តាពាក់ព័ន្ធដើម្បីសម្រេចលើកម្រិតនៃការទទួលខុសត្រូវ របស់បុគ្គលដែលត្រូវបានចោទប្រកាន់ ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មរួមមាន៖ កម្រិតនៃការចូលរួមនៅក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់[28]

---

*សេចក្តីសម្រេចបញ្ជូនរឿងក្តី* Ademi នៅត្រង់កថាខណ្ឌ ២៨។ *រដ្ឋអាជ្ញា តទល់នឹង Ljubičić,* IT-00-41-PT, សេចក្តីសម្រេចលើការបញ្ជូនរឿងក្តីអនុលោមតាមវិធាន ១១ស្ទួន, ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៦ (ចាប់ពីពេលនេះទៅហៅថា សេចក្តីសម្រេចបញ្ជូនរឿងក្តី *Ljubičić*) នៅត្រង់កថាខណ្ឌ ១៨។ *រដ្ឋអាជ្ញា តទល់នឹង Kovačević,* IT-01-42/2-I, សេចក្តីសម្រេចលើការបញ្ជូនរឿងក្តីអនុលោមតាមវិធាន ១១ស្ទួន, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦, (ចាប់ពីពេលនេះទៅហៅថា សេចក្តីសម្រេចបញ្ជូនរឿងក្តី *Kovačević*) នៅត្រង់កថាខណ្ឌ ២០ *សេចក្តីសម្រេចបញ្ជូនរឿងក្តី Lukić* នៅត្រង់កថាខណ្ឌ ២៧។ *រដ្ឋអាជ្ញា តទល់នឹង Mitar Rašević និង Savo Todović,* IT-97-25/l-ARllbis,សាលដីកាលើបណ្តឹងសាទុក្ខប្រឆាំង សេចក្តីសម្រេចលើការបញ្ជូនរឿងក្តីអនុលោមតាមវិធាន ១១ស្ទួន, ខែ កញ្ញា ឆ្នាំ ២០០៦ (ចាប់ពីពេលនេះទៅហៅថា សាលដីកាលើបណ្តឹងសាទុក្ខ *Raševićនិង Todović*) កថាខណ្ឌ ១៣ និង១៦។

[24] *សេចក្តីសម្រេចបញ្ជូនរឿងក្តី Lukić* នៅត្រង់កថាខណ្ឌ ២៧ [“នៅពេលសម្រេចលើស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម... ក្រុមប្រឹក្សាជំនុំជម្រះអាចពិចារណាផងដែរទៅលើ តើហេតុការណ៍ផ្សេងៗពីគ្នាប៉ុន្មាន ដែលត្រូវបានចោទប្រកាន់ចំពោះជនជាប់ចោទ ហើយនិងមធ្យោបាយក្នុងការដឹងឮពីអំពើឧក្រិដ្ឋ ដែលត្រូវបានចោទប្រកាន់។ ក្រុមប្រឹក្សាជំនុំជម្រះក៏អាចធ្វើការពិចារណាផងដែរ ទៅលើកាលៈទេសៈផ្សេងទៀតនៃបទឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់”]។

[25] *ដូចជើងទំព័រខាងលើ*

[26] *សេចក្តីសម្រេចបញ្ជូនរឿងក្តី Janković* នៅត្រង់កថាខណ្ឌ ១៩។ *សេចក្តីសម្រេចបញ្ជូនរឿងក្តី Kovačević* នៅត្រង់កថាខណ្ឌ ១២, ២០។ *សេចក្តីសម្រេចបញ្ជូនរឿងក្តី Lukić* នៅត្រង់កថាខណ្ឌ ២៧ និង២៩។ *រដ្ឋអាជ្ញា តទល់នឹង Mitar Raševićនិង Savo Todović,* IT-97-25/1-PT, ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៥, សេចក្តីសម្រេចលើការបញ្ជូនរឿងក្តី អនុលោមតាមវិធាន ១១ ស្ទួន (ក្រុមប្រឹក្សាជំនុំជម្រះលើការបញ្ជូនរឿងក្តី), កថាខណ្ឌ ២៣។ សាលដីកាលើរឿងក្តី *Raševićនិង Todović* នៅត្រង់កថាខណ្ឌ ២៥ [“ អង្គជំនុំជម្រះតុលាការកំពូលមិនយល់ស្របជាមួយ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថាក្រុមប្រឹក្សាជំនុំជម្រះលើការបញ្ជូនរឿងក្តី មិនបានធ្វើការពិចារណាទៅលើបុគ្គលមួយចំនួន ដែលត្រូវបានទទួលរងផលប៉ះពាល់ ពីបទឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ប្រឆាំងពួកគេ... នៅពេលវាយតម្លៃលើស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ប្រឆាំងម្ចាស់បណ្តឹងសាទុក្ខ និងកម្រិតនៃការទទួលខុសត្រូវរបស់គាត់...”]។

[27] *សូមមើល រដ្ឋអាជ្ញា តទល់នឹង Ntaganda,* ICC-01/04-169, ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៦, សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញា សុំដីកាចាប់ខ្លួន, មាត្រា ៥៨ (អង្គជំនុំជម្រះតុលាការកំពូល) នៅត្រង់កថាខណ្ឌ ៧៦ [“តួនាទីជាក់លាក់របស់បុគ្គល ឬចំពោះបញ្ហានេះ អង្គភាព អាចប្រែប្រួលច្រើនដោយអាស្រ័យលើកាលៈទេសៈ នៃរឿងក្តី ហើយមិនគួរត្រូវបានវាយតម្លៃដាច់តែឯង ឬធ្វើបុរេវិនិច្ឆ័យផ្អែលលើមូលដ្ឋានផ្លូវការហួសហេតុពេកនោះដែរ”]។

ឋានានុក្រម ឬតួនាទីរបស់ជនជាប់ចោទ[29] រួមបញ្ចូលទាំងចំនួននៃអ្នកនៅក្រោមបង្គាប់ និងថ្នាក់លើ[30] សិទ្ធិអំណាចប្រកបដោយប្រសិទ្ធិភាព[31] និងសមត្ថភាពក្នុងការចេញបញ្ជា[32] វិសាលភាពពេលវេលានៃការត្រួតត្រារបស់ពួកគេ[33] សិទ្ធិអំណាចក្នុងការចរចា ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ឬអនុវត្តកិច្ចព្រមព្រៀង[34] ការដឹងឮជាក់ស្តែងរបស់ពួកគេចំពោះឧក្រិដ្ឋកម្ម និងថាតើអ្នកនៅក្នុងតួនាទីខ្ពស់ជាងទាំងនោះ ត្រូវបានគេផ្តន្ទាទោសហើយឬនៅ[35]។

---

[28] *សេចក្តីសម្រេចបញ្ជូនរឿងក្តី* Ademi នៅត្រង់កថាខណ្ឌ ២៩ ["កម្រិតនៃការទទួលខុសត្រូវគួរត្រូវបានបកស្រាយ ដើម្បីបញ្ចូលទាំងឋានៈយោធារបស់ជនជាប់ចោទ ក៏ដូចជាតួនាទីជាក់ស្តែងរបស់ពួកគេ នៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម"]។ *សេចក្តីសម្រេចបញ្ជូនរឿងក្តី* Lukić នៅត្រង់កថាខណ្ឌ ២៨។

[29] សេចក្តីសម្រេចបញ្ជូនរឿងក្តី *Ademi* នៅត្រង់កថាខណ្ឌ ២៩ ["កម្រិតនៃការទទួលខុសត្រូវគួរត្រូវបានបកស្រាយ ដើម្បីរួមបញ្ចូលទាំងឋានៈយោធារបស់ជនជាប់ចោទ ក៏ដូចជាតួនាទីជាក់ស្តែងរបស់ពួកគេ នៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម"]។ *Kovačević* នៅត្រង់កថាខណ្ឌ ២០។ *សេចក្តីសម្រេចបញ្ជូនរឿងក្តី* Milošević នៅត្រង់កថាខណ្ឌ ២៣ ["នៅក្នុងការវាយតម្លៃលើតួនាទីរបស់ Dragomir Milošević, ក្រុមប្រឹក្សាជំនុំជម្រះលើការបញ្ជូនរឿងក្តី បានកត់សម្គាល់ជាពិសេសថា គាត់គឺជាមេបញ្ជាការអចិន្ត្រៃយ៍ មិនមែនមេបញ្ជាការស្តីទី ឬបណ្តោះអាសន្នឡើយ ..."]។ *សេចក្តីសម្រេចបញ្ជូនរឿងក្តី* Lukić នៅត្រង់កថាខណ្ឌ ២៨ ["កម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ ពាក់ព័ន្ធទាំងទៅនឹងតួនាទីរបស់ជនជាប់ចោទ ក្នុងការប្រព្រឹត្តិបទល្មើសដែលត្រូវបានចោទប្រកាន់ និងចំពោះតួនាទីនិងឋានៈរបស់ជនជាប់ចោទក្នុងឋានានុក្រមស៊ីវិល នយោបាយ និងយោធា ដោយផ្អែកលើសិទ្ធិអំណាចជាក់ស្តែង ឬសិទ្ធិអំណាចតាមផ្លូវច្បាប់"]។

[30] *សេចក្តីសម្រេចបញ្ជូនរឿងក្តី* Milošević នៅត្រង់កថាខណ្ឌ២៣។

[31] *សេចក្តីសម្រេចបញ្ជូនរឿងក្តី* Lukić នៅត្រង់កថាខណ្ឌ ២៩ ["កម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ ពាក់ព័ន្ធទាំងទៅនឹងតួនាទីរបស់ជនជាប់ចោទ ក្នុងការប្រព្រឹត្តិបទល្មើសដែលត្រូវបានចោទប្រកាន់ និងចំពោះតួនាទីនិងឋានៈរបស់ជនជាប់ចោទក្នុងឋានានុក្រមស៊ីវិល នយោបាយ និងយោធា ដោយផ្អែកលើសិទ្ធិអំណាចជាក់ស្តែង ឬសិទ្ធិអំណាចតាមផ្លូវច្បាប់...បុគ្គលម្នាក់ដែលមានឋានៈខ្ពស់អាចមានសិទ្ធិអំណាច ចាត់ចែងសកម្មភាពរបស់អ្នកដទៃ៖ ដោយសារតែគាត់អាចបង្កព្យសនកម្មធំជាង ធៀបទៅនឹងព្យសនកម្មដែលគាត់អាចបង្កឡើង ក្នុងករណីដែលគាត់មិនមានតួនាទី ឬឋានៈបែបនេះ។ ហេតុដូច្នេះគាត់មានកម្រិតនៃការទទួលខុសត្រូវខ្ពស់ជាង"]។ *សេចក្តីសម្រេចបញ្ជូនរឿងក្តី* Ademi នៅត្រង់កថាខណ្ឌ ២៩។

[32] *សេចក្តីសម្រេចបញ្ជូនរឿងក្តី* Ademi នៅត្រង់កថាខណ្ឌ ២៩។

[33] *សេចក្តីសម្រេចបញ្ជូនរឿងក្តី* Milošević នៅត្រង់កថាខណ្ឌ ២៣ ["ក្នុងការវាយតម្លៃលើតួនាទីរបស់ Dragomir Milošević, ក្រុមប្រឹក្សាជំនុំជម្រះលើការបញ្ជូនរឿងក្តី កត់សម្គាល់ជាពិសេសថា គាត់មិនមែនជាមេបញ្ជាការស្តីទី ឬបណ្តោះអាសន្នឡើយ គាត់គឺជាមេបញ្ជាការអចិន្ត្រៃយ៍របស់ SRK ក្នុងរយៈពេលយូរជាងមួយឆ្នាំ ហើយមានថ្នាក់តែមួយប៉ុណ្ណោះក្នុងមេបញ្ជាការយោធា, ឧទាហរណ៍ មេបញ្ជាការយោធាជាន់ខ្ពស់បំផុតនៅលើគាត់ ...."]។

[34] *សេចក្តីសម្រេចបញ្ជូនរឿងក្តី* Milošević នៅត្រង់កថាខណ្ឌ ២៣ ["ក្នុងរឿងក្តីប្រឆាំង Dragomir Milošević ដែលគាត់បានចរចា បានចុះហត្ថលេខា និងបានអនុវត្តកិច្ចព្រមព្រៀងប្រឆាំងការកាត់បន្ថយ និងកិច្ចព្រមព្រៀងឈប់បាញ់ក្នុងស្រុក ព្រមទាំង

*មេដឹកនាំជាន់ខ្ពស់*

9. ពាក់ព័ន្ធទៅនិងពាក្យពេចន៍ "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ" ប្រវត្តិនីតិបញ្ញត្តិរបស់អ.វ.ត.ក និងយុត្តិសាស្ត្រអន្តរជាតិបានកំណត់ថា ពាក្យពេចន៍មិនត្រូវបានកម្រិតតែត្រឹម សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា[36] ឬ "អ្នកបង្កើតគោលនយោបាយទាំងមូល"[37]។ ប៉ុន្តែបើតាមទស្សនៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អត្ថន័យត្រង់នៃពាក្យនេះបានចង្អុលបង្ហាញថា ពាក្យនេះក្តោបទៅលើ ក្រុមមនុស្សមួយក្រុមជាក់លាក់ ដែលស្ថិតនៅក្នុងឋានានុក្រមជាន់ខ្ពស់បំផុត ផ្នែកនយោបាយ និងយោធារបស់បក្សកុម្មុយនីស្តកម្ពុជា និងរបបកម្ពុជាប្រជាធិបត្យ។

## III. សារណាលើអង្គហេតុពាក់ព័ន្ធ អ៊ឹម ចែម

### ក. សាវតារ និងតួនាទីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

---

ចូលរួមក្នុងការចរចារទាក់ទងអាវុធធន់ធ្ងន់ និងការចូលទៅក្នុងតំបន់ជុំវិញ Sarajevo របស់ UNPROFOR ដោយមានការត្រួតពិនិត្យ"]។

[35] *សេចក្តីសម្រេចបញ្ជូនរឿងក្តី Kovačević* នៅត្រង់កថាខណ្ឌ ២០ ["បុគ្គលពីរនាក់ផ្សេងទៀត ម្នាក់មានឋានៈក្នុងជួរកងទ័ពខ្ពស់ជាង ជនជាប់ចោទនោះ ត្រូវបានផ្តន្ទាទោសរួចទៅហើយអំពីតួនាទីរបស់ពួកគេ ក្នុងការវាយប្រហារលើ Dubrovnik។ ហេតុដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះលើការបញ្ជូនរឿងក្តី មិនអាចរកឃើញមូលដ្ឋានគ្រប់គ្រាន់ សម្រាប់ការកំណត់ប្រភេទនៃបទល្មើសរបស់ជនជាប់ចោទថាជា "មេដឹកនាំជាន់ខ្ពស់បំផុត" ដូចដែលបានប្រមើលមើលដោយយុទ្ធសាស្ត្របញ្ចប់"]។

[36] ឯកសារ F28 សាលដីកាលើសំណុំរឿង ខុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ៧៦ ដល់៧៧ ដកស្រង់ សម័យប្រជុំលើទីមួយ នៃនីតិកាលទីបីរបស់រដ្ឋសភាជាតិកម្ពុជា ថ្ងៃទី ៤-៥ ខែ តុលា ឆ្នាំ ២០០៤ ទំព័រ ២៣ (ឯកឧត្តម សុខ អាន បញ្ជាក់ថា "ទាក់ទិនទៅនឹងមេដឹកនាំជាន់ខ្ពស់ យើងសំដៅទៅលើបុគ្គលមិនលើសពី ១០នាក់ឡើយ ប៉ុន្តែយើងមិនបញ្ជាក់ថា ពួកគេជាសមាជិកគណៈអចិន្ត្រៃយ៍ឡើយ។ នេះគឺជាកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា")។ឯកសារ E188 សាលក្រមសំណុំរឿង ០០១ (ខុច), កថាខណ្ឌ ១៩ ដក់ស្របរបាយការណ៍របស់ក្រុមអ្នកជំនាញ នៅត្រង់កថាខណ្ឌ ១០៩ ["ក្រុមអ្នកជំនាញមិនជឿជាក់ថា ពាក្យ "ថ្នាក់ដឹកនាំ" គួរប្រៀបធៀបទៅលើបុគ្គលទាំងអស់ នៅកម្រិតជាន់ខ្ពស់នៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬសូម្បីត្រឹមបក្សកុម្មុយនីស្តឡើយ"]។

[37] *សេចក្តីសម្រេចបញ្ជូនរឿងក្តី Milošević* នៅត្រង់កថាខណ្ឌ ២២ ["ប៉ុន្តែក្រុមប្រឹក្សាជំនុំជម្រះលើការបញ្ជូនរឿងក្តី មិនបានពិចារណាថាឃ្លា "មេដឹកនាំខ្ពស់បំផុត" ដែលត្រូវបានប្រើប្រាស់ដោយក្រុមប្រឹក្សាសន្តិសុខ ត្រូវបានកម្រិតតែត្រឹមបុគ្គលដែលជា "ស្ថាបត្យករ" នៃ "គោលនយោបាយរួម" ដែលបង្កើតបានជាមូលដ្ឋាននៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់... ការនេះនឹងលប់បំបាត់នូវកម្រិតនៃការទទួលខុសត្រូវពិតប្រាកដ របស់មេបញ្ជាការជាច្រើន នៅកម្រិតសមរភូមិ និងកម្រិតសេនាធិការ"]។ *សេចក្តីសម្រេចបញ្ជូនរឿងក្តី Lukić* នៅត្រង់កថាខណ្ឌ ២៨ ["ប៉ុន្តែទស្សនៈ "មេដឹកនាំខ្ពស់បំផុត" គឺមិនកម្រិតត្រឹមតែអ្នកបង្កើតគោលនយោបាយរួម ដែលបង្កើតបានជាមូលដ្ឋាននៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ឡើយ"]។

10. អ៊ឹម ចែមកើតនៅភូមិក្បាលអូរ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ នៅអំឡុងឆ្នាំ ១៩៤៣-១៩៤៤[38]។ ស្រុកត្រាំកក់គឺជាស្រុកកំណើតរបស់តាម៉ុក និងជាមូលដ្ឋានស្នូលមួយរបស់ចលនាខ្មែរក្រហម[39]។ នៅឆ្នាំ ១៩៦៤ អ៊ឹម ចែមបានរៀបការជាមួយណុប ញ៉ែនដែលជាអ្នកភូមិក្បាលអូរដែរ[40]។ ដូចដែលបានរៀបរាប់លម្អិតនៅផ្នែកខាងក្រោម ប្តីរបស់គាត់ក៏មានតួនាទីសំខាន់ផងដែរ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

11. អ៊ឹម ចែម បានបញ្ជាក់ថាគាត់បានចូលរួម ជាមួយខ្មែរក្រហមនៅក្នុងឆ្នាំ ១៩៧០ បន្ទាប់ពីបង/ប្អូនប្រុសរបស់គាត់ដែលជានីរសាររបស់តាម៉ុក ត្រូវបានចាប់ខ្លួនហើយសម្លាប់ចោលដោយទាហានលន់ នល់[41]។ គាត់មានតួនាទី និងការទទួលខុសត្រូវផ្សេងៗគ្នា នៅក្នុងពេលសង្គ្រាមឆ្នាំ ១៩៧០ ដល់ ១៩៧៥។ នៅក្នុងឆ្នាំ ១៩៧១ គាត់ត្រូវបានតែងតាំងឲ្យទទួលខុសត្រូវ លើឃុំជាងទង ស្រុកត្រាំកក់[42]។ នៅក្នុងឆ្នាំ ១៩៧២ ឬ១៩៧៣ គាត់ត្រូវបានតែងតាំងឲ្យទទួលខុសត្រូវ ក្រុមកងទ័ពនារីដែលមានចំនួន

---

[38] ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951787-89។ D123/1/5.1c បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951825។

[39] ឯកសារ *CF2*-E1/23.1 សក្ខីកម្មសវនាការ នួន ជា, ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១, នៅត្រង់ 11.56.30 [បានកំណត់ថាត្រាំកក់គឺជា សាខាបក្សស្នូលមួយ ក្នុងចំណោមសាខាបក្សស្នូលទាំងពីរ]។ ឯកសារ **D6.1.542** ទស្សនាវដ្តីទង់បដិវត្ត, ខែ មិថុនា ឆ្នាំ ១៩៧៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00446848-52 [ទទួលស្គាល់ថាត្រាំកក់គឺជាស្រុកគំរូមួយ ក្នុងចំណោមស្រុកគំរូទាំងបីក្នុងកម្ពុជាប្រជាធិបតេយ្យ]។ ឯកសារ **D1.3.10.7** របាយការណ៍របស់ Henri Locard អំពីស្រុកត្រាំកក់, នៅត្រង់ឯកសារភាសាអង់គ្លេស 00217690 [បានពណ៌នាថាត្រាំកក់គឺជា "គំរូនៃសង្គមកម្ពុជាប្រជាធិបតេយ្យ"]។

[40] ឯកសារ D123/1/5.1a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00089783, 00089785។ ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951787, 00951790។

[41] ឯកសារ D123/1/5.1c បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951834-37។ ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951791។

[42] ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951793។ ឯកសារ D1.3.12.1 បទសម្ភាសន៍ជាមួយ អ៊ឹម ចែម (ដោយ John Iverson), ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00217515 [បញ្ជាក់ថាគាត់គឺជាមេឃុំជាងទងរយៈពេលពីរឆ្នាំ នៅដើមទស្សវត្សឆ្នាំ ១៩៧០]។ ឯកសារD118/242 កំណត់ហេតុស្តាប់ចម្លើយ ខឹម បឿន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ៨០ [អ៊ឹម ចែម "បានរៀបចំការផ្លាស់ប្តូរការងាររួមគ្នារបស់នារី នៅក្នុងភូមិ និងនៅក្នុងឃុំជាងទង"]។

ប្រហែល ៤០០ ទៅ៥០០នាក់ ដែលគាត់ជាអ្នកអប់រំ និងបណ្តុះបណ្តាលនៅភ្នំដំរីរមៀល[43]។ នៅក្នុងឆ្នាំ ១៩៧៤ នៅពេលដែលស្រុកអង្គរជ័យត្រូវបានរំដោះដោយខ្មែរក្រហម គាត់ត្រូវបានតាម៉ុកតែងតាំងឲ្យរៀបចំ និង "គ្រប់គ្រងប្រជាជននៅក្នុងស្រុកនោះ"[44]។ ប្តីរបស់គាត់ឈ្មោះញ៉ែននៅពេលក្រោយមកបានក្លាយជាលេខាស្រុក[45]។

---

[43] ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951794-95។ ឯកសារ D123/1/5.1c បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951838-40 [ក៏បានកត់សម្គាល់ផងដែរថាប្តីរបស់គាត់ ទទួលខុសត្រូវលើកងទ័ពបុរស ក្នុងអំឡុងពេលជាមួយគ្នា]។ ឯកសារD1.3.12.1 កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, នៅត្រង់ ឯកសារភាសាអង់គ្លេស 00217520។

[44]ឯកសារ D123/1/5.1c បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951841-42 [បញ្ជាក់ថាគាត់ស្នាក់នៅអង្គរជ័យអស់រយៈពេលពីរឆ្នាំ ហើយបន្ទាប់មកបានប្តូទៅនៅកោះអណ្តែត]។ ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951795 [បញ្ជាក់ថាគាត់ត្រូវបានតែងតាំងឲ្យទៅរៀបចំមនុស្ស នៅអង្គរជ័យនិងកោះអណ្តែត ហើយគាត់ត្រូវ "ទទួលខុសត្រូវលើស្ត្រីទាំងអស់"]។ ឯកសារ **D219/37** កំណត់ហេតុស្តាប់ចម្លើយ សួន មុត ដោយក.ស.ច.ស នៅត្រង់ចម្លើយ16។ ឯកសារ **D219/4.1** កិច្ចសម្ភាសន៍ជាមួយ សួន មុត ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ ឯកសារភាសាអង់គ្លេស 01056790 [ចែម និងញ៉ែនមកគ្រប់គ្រងស្រុកអង្គរជ័យនៅក្នុងឆ្នាំ ១៩៧៣ ដោយចែមទទួលខុសត្រូវកម្រិតតំបន់]។ ឯកសារ **D118/259** កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម ដោយក.ស.ច.ស នៅត្រង់ចម្លើយ ៤៣។ ឯកសារ **D118/209** កំណត់ហេតុស្តាប់ចម្លើយ អ៊ុល ហឿន ដោយក.ស.ច.ស នៅត្រង់ចម្លើយ ១២៨ ដល់១៣០។ ឯកសារ **D119/70/4** កិច្ចសម្ភាសន៍ជាមួយ អ៊ុល ហឿន ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ឯកសារភាសាអង់គ្លេស 01050190 ["ស្រុកអង្គរជ័យត្រូវបានគ្រប់គ្រងដោយយាយចែម តាញ៉ែន"]។ ឯកសារ D119/84 កំណត់ហេតុស្តាប់ចម្លើយ មឿង វ៉េត ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១២ ដល់១៣ [ចែមរស់នៅនិងធ្វើការក្បែរវត្តអង្គទេព ក្នុងស្រុកអង្គរជ័យ ក្នុងឆ្នាំ ១៩៧៥]។

[45] ឯកសារ D119/84 កំណត់ហេតុស្តាប់ចម្លើយ មឿង វ៉េត ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ១។ ឯកសារ **D119/156** កំណត់ហេតុស្តាប់ចម្លើយ ឈឿង ជឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ១២ [បានកំណត់អត្តសញ្ញាណញ៉ែនថាជា គណៈស្រុកអង្គរជ័យ ក្រោយឆ្នាំ ១៩៧៥]។ ឯកសារ **D118/274** កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៤៥, ៩០ ដល់៩២។ ឯកសារ **D118/259** កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម ដោយក.ស.ច.ស នៅត្រង់ចម្លើយ ៤០។ឯកសារ **D119/13** កំណត់ហេតុស្តាប់ចម្លើយ ជាម ជ្រាវ ដោយក.ស.ច.ស នៅត្រង់ចម្លើយ ៤ដល់៨។ ឯកសារ**D219/37** កំណត់ហេតុស្តាប់ចម្លើយ សួន មុត ដោយក.ស.ច.ស នៅត្រង់ចម្លើយ ១១, ១៦។ ឯកសារ D119/15 កំណត់ហេតុស្តាប់ចម្លើយ សៅ វ៉ាន់ ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១២។ ឯកសារ **D119/11** កំណត់ហេតុស្តាប់ចម្លើយ ផៃ អឿក ដោយក.ស.ច.ស នៅត្រង់ចម្លើយ ៥។ ឯកសារD123/1/5.1c បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951846 [បញ្ជាក់ថាប្តីរបស់គាត់រស់នៅអង្គរជ័យ ដើម្បីជួយគ្រប់គ្រងស្រុកនោះ ហើយក្រោយមកត្រូវបានតែងតាំងឲ្យទៅទីរួមខេត្តតាកែវ]។

12. សាច់ញាតិរបស់ អ៊ឹម ចែម នៅភូមិជាមួយគាត់ដែរនោះ មានតួនាទីជាមេឃុំនៅក្នុងស្រុកត្រាំកក់ ហើយបានចូលរួមក្នុងកិច្ចប្រជុំថ្នាក់ស្រុក។ គាត់បានផ្តល់សក្ខីកម្មថា អ៊ឹម ចែម ទទួលខុសត្រូវលើកិច្ចការនារី នៅក្នុងតំបន់១៣ ចាប់ពីឆ្នាំ ១៩៧៣ ដល់ឆ្នាំ ១៩៧៧ ដូច្នេះហើយគាត់គឺជា "អ្នកមានឋានៈខ្ពស់" ដែល "គ្រប់គ្រងលើកម្មាភិបាលស្ត្រីទាំងអស់នៅក្នុងតំបន់"[46]។ នៅក្នុងតួនាទីនោះ អ៊ឹម ចែម ទទួលខុសត្រូវលើស្រុកទាំងប្រាំនៅក្នុងតំបន់ ១៣៖ ស្រុកត្រាំកក់ (១០៥), ស្រុកអង្គរជ័យ (១០៦), ស្រុកទ្រាំង (១០៧), ស្រុកកោះអណ្តែត (១០៨), និងស្រុកគិរីវង់ (១០៩)[47]។ មន្ទីរនារីតំបន់១៣ដែលគេស្គាល់ថាជាមន្ទីរ ១០៥ ដំបូងមានទីតាំងនៅជិតភ្នំដំរីរមៀល ហើយក្រោយមកបានប្តូរទៅទីរួមខេត្តតាកែវ[48]។

---

[46] ឯកសារD118/242 កំណត់ហេតុស្តាប់ចម្លើយ ខឹម បឿន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១ដល់២, ៧៣ ដល់៧៧ ["យាយចែមធ្លាប់ថ្លែងនៅក្នុងកិច្ចប្រជុំនៅមន្ទីរតំបន់ ១៣ ហើយគាត់បានប្រកាសពីតួនាទីរបស់គាត់"], ចម្លើយ ៧៩ ["ខ្ញុំដឹងថាយាយចែមគឺជាអ្នកគ្រប់គ្រងស្ត្រីនៅក្នុងភូមិ។ បន្ទាប់មកដោយសារគាត់ធ្វើការងារបានល្អ គាត់ត្រូវបានគេដំឡើងឋានៈទៅតំបន់តែម្តង"], ចម្លើយ ១០៥ ដល់១១០។ *សូមមើលផងដែរ* ឯកសារ **D119/83** កំណត់ហេតុស្តាប់ចម្លើយ មឿង វ៉េត ដោយក.ស.ច.ស នៅត្រង់ចម្លើយ ១៧ដល់១៩ [សក្ខីកម្មរបស់កម្មាភិបាលតំបន់ ១៣ ដែលធំពេញវ័យនៅក្បែផ្ទះអ៊ឹម ចែម ត្រឹម៥០ម៉ែត្រ]។ ឯកសារ D119/84 កំណត់ហេតុស្តាប់ចម្លើយ មឿង វ៉េត ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១៩ ដល់២០, ២៩ ដល់៣០ [អ៊ឹម ចែមគ្រប់គ្រងកម្មាភិបាលស្ត្រី "រាប់ពាន់នាក់" មកពីស្រុកទាំង៥ ក្នុងតំបន់ ១៣]។ ឯកសារ **D118/274** កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ២៨ [មេឃុំនៃភូមិភាគនិរតី បានកំណត់ថាចែមគឺជា "ប្រធានសមាគមន៍នារីតំបន់ ១៣"]។ ឯកសារ **D118/259** កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម ដោយក.ស.ច.ស នៅត្រង់ចម្លើយ ៤០ដល់៤៥។ ឯកសារ **D119/15** កំណត់ហេតុស្តាប់ចម្លើយ សៅ វ៉ាន់ ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១២។ ឯកសារ **D119/82** កំណត់ហេតុស្តាប់ចម្លើយ នាង អ៊ូច ដោយក.ស.ច.ស នៅត្រង់ចម្លើយ ៤១, ៤៩។ ឯកសារ D119/108 កំណត់ហេតុស្តាប់ចម្លើយ សុខ រុំ ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៤៥ ដល់៤៩ [បញ្ជាក់ថាចែមស្ថិតនៅក្នុងគណៈតំបន់ ១៣ ហើយបានដឹកនាំការប្រជុំជាមួយកម្មាភិបាលនារី នៅកោះអណ្តែតក្នុងឆ្នាំ ១៩៧៦]។

[47] ឯកសារ **D119/156** កំណត់ហេតុស្តាប់ចម្លើយ ឈឿង ជឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១៥ដល់១៧ [អតីតមេភូមិបក្សកុម្មុយនីស្តកម្ពុជា ដែលបានចូលរួមក្នុងការប្រជុំដែលកោះហៅដោយអ៊ឹម ចែមបានបញ្ជាក់ថាគាត់ "ធ្វើការនៅក្នុងស្រុកជាច្រើនក្នុងតំបន់" រួមទាំងស្រុក ១០៥, ១០៦ និង១០៩]។ ឯកសារ **D118/259** កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម ដោយក.ស.ច.ស នៅត្រង់ចម្លើយ ៤០, ៤៣ [ចម្លើយរបស់អតីតលេខាស្រុកត្រាំកក់ថា ចែម "ទៅធ្វើការនៅគ្រប់ស្រុកទាំងអស់ក្នុងតំបន់ ១៣"]។ ឯកសារ **D119/82** កំណត់ហេតុស្តាប់ចម្លើយ នាង អ៊ូច ដោយក.ស.ច.ស នៅត្រង់ចម្លើយ ៤៣ ដល់៤៦ [ចែម មកពីតំបន់ហើយកោះហៅស្ត្រីៗនៅក្នុងស្រុកកោះអណ្តែតឲ្យទៅប្រជុំ]។

[48] ឯកសារD118/242 កំណត់ហេតុស្តាប់ចម្លើយ ខឹម បឿន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១០៧ ដល់១០៨ [សាក្សី "បានជួបញឹកញាប់" ហើយបាននិយាយជាមួយអ៊ឹម ចែម នៅក្នុងភូមិកំណើតរបស់ពួកគេ គឺនៅមន្ទីរតំបន់ក្នុងខេត្តតាកែវ ឬមន្ទីរនារី

13. នៅក្នុងឆ្នាំ ១៩៧៦ អ៊ឹម ចែម ត្រូវបានប៉ុល ពត និងតាម៉ុកចាត់តាំងឱ្យប្តូរទៅកោះអណ្តែត ហើយត្រូវបានតែងតាំងជាលេខាស្រុកនោះ[49]។ គាត់បាននិយាយថាគេផ្តល់តួនាទីនេះឱ្យគាត់ ព្រោះគណៈស្រុកមុនតែងតែមានជម្លោះគ្នាញឹកញាប់ ហើយប៉ុល ពត និងតា ម៉ុកជឿជាក់ថាគាត់អាច "សម្រេចផែនការ"បាន[50]។ អនុរបស់គាត់នៅកោះអណ្តែត មានឈ្មោះនាង អ៊ុំ ហៅតាសាន ដែលជាប្អូនថ្លៃរបស់តា ម៉ុក ហើយនៅពេលក្រោយមកគាត់បានក្លាយជាលេខាស្រុក ត្រាំកក់[51]។ នៅខែ មីនា ឆ្នាំ ១៩៧៦ អ៊ឹម ចែម ត្រូវបានតែងតាំងជាតំណាងភូមិភាគនិរតី នៅក្នុងសភាតំណាងប្រជាជន របស់កម្ពុជាប្រជាធិបតេយ្យ[52]។

---

តំបន់នៅជិតដំរីរមៀល]។ ឯកសារ **D119/83** កំណត់ហេតុស្តាប់ចម្លើយ មឿង វេត ដោយក.ស.ច.ស នៅត្រង់ចម្លើយ ១១។ ឯកសារ D119/84 កំណត់ហេតុស្តាប់ចម្លើយ មឿង វេត ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១៥។

[49] D123/1/5.1c បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ឯកសារភាសាអង់គ្លេស 00951845។ ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951796 [បញ្ជាក់ថាគាត់ត្រូវបានគេផ្ទេរពីអង្គរជ័យ ទៅកោះអណ្តែតក្នុងឆ្នាំ ១៩៧៦]។ ឯកសារD119/16 កំណត់ហេតុស្តាប់ចម្លើយ កៅ ជឹង ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ២១, ២៤ [អ៊ឹម ចែម ទទួលខុសត្រូវលើកងទ័ពស្រុកកោះអណ្តែត]។ ឯកសារ D118/208 កំណត់ហេតុស្តាប់ចម្លើយ អ៊ុល ហឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៥៦។

[50] ឯកសារ D123/1/5.1c បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951845។

[51] ឯកសារ D123/1/5.1c បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951846។ ឯកសារD118/242 កំណត់ហេតុស្តាប់ចម្លើយ ខឹម ហឿន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៨។ ឯកសារ **D219/34** កំណត់ហេតុស្តាប់ចម្លើយ អ៊ុល ហឿន ដោយក.ស.ច.ស នៅត្រង់ចម្លើយ ៦ដល់៧, ១៣ ដល់១៤។ ឯកសារ **D118/208** កំណត់ហេតុស្តាប់ចម្លើយ អ៊ុល ហឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១១៣។ សូមមើលឯកសារ **D6.1.210** លិខិតមកពីលេខាស្រុកត្រាំកក់ ឈ្មោះសាន ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៧៨ នៅត្រង់ឯកសារភាសាអង់គ្លេស 00831486 [បង្គាប់ឱ្យ "សម្អាត" កុមាររួមជាមួយម្តាយរបស់ពួកវា]។

[52] ឯកសារ **D1.3.23.1** ការផ្សាយរបស់វិទ្យុកម្ពុជាប្រជាធិបតេយ្យ, ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៧៦, នៅត្រង់ឯកសារភាសាអង់គ្លេស 00087743 [លេខ ៤ – "ស្រី ចែម (ស)"]។ ឯកសារ D119/84 កំណត់ហេតុស្តាប់ចម្លើយ មឿង វេត ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៣៣។ ឯកសារ **D119/65** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៥៥ ដល់៥៨។ យោងតាមរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ សភាមានការទទួលខុសត្រូវតែមួយគត់ក្នុងការតាក់តែងច្បាប់ នៅក្នុងរបប។ សភាមានគោលដៅដើម្បីបិទបាំងការពារភាពស្របច្បាប់ប្រជាធិបតេយ្យ ចំពោះរបប ប៉ុន្តែភស្តុតាងទាំងអស់បានចង្អុលបង្ហាញថា សភាបានជួបប្រជុំតែម្តងគត់ ហើយមិនបានអនុម័តច្បាប់អ្វីទាំងអស់ ហើយមិនមានតួនាទីអ្វីនៅក្នុងការបង្កើតគោលនយោបាយ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ។

14. អ៊ឹម ចែម បានបញ្ជាក់ថា បន្ទាប់ពីនៅកោះអណ្ដែតមួយឆ្នាំមក គាត់ត្រូវបានតាម៉ុកផ្ទេរទៅទីរួមខេត្ត តាកែវ ដែលជាទីតាំងតំបន់១៣ និងមន្ទីរភូមិភាគនិរតី[53] ហើយស្នាក់នៅទីនោះមិនដល់ប្រាំមួយខែផង[54]។ គាត់បានទទួលស្គាល់ថាគាត់គឺជាសមាជិកតំបន់ ហើយគាត់ទទួលបាន "ការតម្លើងឋានៈ" ជាគណៈតំបន់១៣ នៅពេលលេខាតំបន់ឈ្មោះ សោមផ្កាក់ខ្លួនឈឺ[55]។ នៅក្នុងពេលនោះគាត់ធ្វើការនៅមន្ទីរតំបន់នៅតាកែវ ហើយគាត់បន្តទទួលខុសត្រូវលើស្រុកកោះអណ្ដែត[56]។ ក្នុងនាមជាលេខាស្រុក និងជាសមាជិកគណៈកម្មាការតំបន់ នៅក្នុងភូមិភាគនិរតី អ៊ឹម ចែម ធ្វើការទំនាក់ទំនងយ៉ាងទៀងទាត់ ហើយប្រជុំយ៉ាងទៀតទាត់ជាមួយតាម៉ុកជាលេខាភូមិភាគ និងជាសមាជិកពេញសិទ្ធិរបស់គណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា[57]។ គាត់បានចូលរួមកិច្ចប្រជុំតំបន់[58] ហើយថ្លែង

---

[53] ឯកសារ D119/84 កំណត់ហេតុស្ដាប់ចម្លើយ មៀង វ៉េត ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១៨។ ឯកសារ D118/208 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុល ហឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៨៥។ ឯកសារ **D118/151** កំណត់ហេតុស្ដាប់ចម្លើយ ខៀវ នៅ ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៩។ ឯកសារ **D118/152** កំណត់ហេតុស្ដាប់ចម្លើយ ភោគ ទូច ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១, ៥, ៨៤។

[54] ឯកសារ D123/1/5.1c បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951848-49។

[55] ឯកសារ D123/1/5.1c បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951849 ["សៈ ប៉ុន្តែលោកមិនធ្វើការនៅតំបន់១៣ទេ មែនទេ? ឆៈ អត់ទេ ខ្ញុំបន្តពីប្រធានសនរបស់ខ្ញុំ ហើយខ្ញុំគ្រាន់តែជាសមាជិក។ សៈ សមាជិកតំបន់? ឆៈ ចាស"]។ សូមមើលផងដែរ ឯកសារ **D118/274** កំណត់ហេតុស្ដាប់ចម្លើយ ប៊ុន ធឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ២៩។ ឯកសារ **D219/4.1** កិច្ចសម្ភាសន៍ជាមួយ សួន មុត ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ ឯកសារភាសាអង់គ្លេស 01056790-92។ ឯកសារ **D219/37** កំណត់ហេតុស្ដាប់ចម្លើយ សួន មុត ដោយក.ស.ច.ស នៅត្រង់ចម្លើយ ១៧ ដល់១៨, ២១ [បញ្ជាក់ថាចែមគឺជាសមាជិកតំបន់អស់រយៈពេល "យូរគួរសម"]។ ឯកសារ **D219/34** កំណត់ហេតុស្ដាប់ចម្លើយ អ៊ុល ហឿន ដោយក.ស.ច.ស នៅត្រង់ចម្លើយ ១០ ដល់១១, ២២។ឯកសារ **D118/78** កំណត់ហេតុស្ដាប់ចម្លើយ អ៊ិន សុភាព ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៨។ ឯកសារ D219/294 កំណត់ហេតុស្ដាប់ចម្លើយ មូល អេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៨ ដល់២៩, ៣១ [សក្ខីកម្មរបស់អតីតលេខាស្រុកបក្សកុម្មុយនីស្តកម្ពុជា ដែលថាចែមមាន "តួនាទីជាន់ខ្ពស់"]។ ឯកសារ D119/84 កំណត់ហេតុស្ដាប់ចម្លើយ មៀង វ៉េត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៩ដល់២០ [សាក្សីបានបញ្ជូនសំបុត្រមួយដែលផ្ញើរជូន "សមមិត្តនារីចែម, គណៈអចិន្ត្រៃយ៍តំបន់ ១៣"]។

[56] ឯកសារ **D123/1/5.1c** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951848-49។

[57] ឯកសារ **D123/1/5.1c** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951847។ ឯកសារ **D118/275** កំណត់ហេតុស្ដាប់ចម្លើយ ប៊ុន ធឿន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤៩ដល់៥០។ ឯកសារ **D118/259** កំណត់ហេតុស្ដាប់ចម្លើយ ពេជ្រ ជឹម ដោយក.ស.ច.ស នៅត្រង់ចម្លើយ ៤៦ [ចម្លើយរបស់អតីតលេខាស្រុកត្រាំកក់ រៀបរាប់ពីទំនាក់ទំនងរយៈពេលយូររវាងតាម៉ុក និងអ៊ឹម ចែម]។

សុន្ទរកថានៅពេលបិទកិច្ចប្រជុំទាំងអស់នោះ ដោយបញ្ចេញមតិចំពោះ “បញ្ហា” នៅក្នុងតំបន់ទាក់ទងសន្តិសុខ ការចាប់ខ្លួន ខ្មាំង និងជនក្បត់[59]។

15. នៅក្នុងឆ្នាំ ១៩៧៧ អ៊ឹម ចែម ត្រូវបានផ្លាស់ទៅតំបន់៥ របស់ភូមិភាគពាយ័ព្យ ហើយត្រូវបានតែងតាំងជាលេខាស្រុកព្រះនេត្រព្រះ[60]។ គាត់ទទួលបានការទុកចិត្តពីថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដោយឲ្យទទួលខុសត្រូវលើស្រុកមួយ ដែលមានប្រជាជនចំនួន ១០០ ០០០នាក់ ដែល៩០ ០០០នាក់ជាប្រជាជន១៧មេសា ដែលត្រូវគេជម្លៀស[61]។ គាត់បានយកកងទ័ពចំនួន៥០០នាក់ មកពីភូមិភាគនិរតី

---

[58] ឯកសារ **D118/274** កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ២៩ [“ខ្ញុំតែងតែឃើញវត្តមានរបស់គាត់ នៅក្នុងរាល់កិច្ចប្រជុំទាំងអស់របស់តំបន់”], ចម្លើយ ៧២។ ឯកសារ **D118/204** កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៣៦។

[59] ឯកសារ **D118/242** កំណត់ហេតុស្តាប់ចម្លើយ ខឹម បឿន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៩៨ ដល់៩៩។ ឯកសារ **D118/274** កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៣៩ ដល់៤២ [សក្ខីកម្មរបស់មេឃុំដែលបានស្តាប់ឮចែមពិភាក្សាអំពីការចាប់ខ្លួនកម្មាភិបាល]។ ឯកសារ D119/108 កំណត់ហេតុស្តាប់ចម្លើយ សុខ រុំ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥៥ [មានវត្តមាននៅវគ្គរៀនសូត្រនៅទីរួមខេត្តតាកែវ ដែលក្នុងវគ្គនេះចែមបានឡើងថ្លែង]។

[60] ឯកសារD1.3.12.1 កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, នៅត្រង់ឯកសារភាសាអង់គ្លេស 00217518។ ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ឯកសារភាសាអង់គ្លេស 00951796 [ទទួលស្គាល់ថាគាត់ត្រូវបានចាត់តាំងទៅតំបន់ពាយ័ព្យ ដោយតាម៉ុក ហើយត្រូវបានតែងតាំងជាលេខាស្រុកព្រះនេត្រព្រះ]។ ឯកសារ **D119/65** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៦២។ ឯកសារ**D119/32** កំណត់ហេតុស្តាប់ចម្លើយ ឈឹម ផាន់ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣៤។ ឯកសារ **D119/98** កំណត់ហេតុស្តាប់ចម្លើយ កោ ឡេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១១។ ឯកសារ **D119/94** កំណត់ហេតុស្តាប់ចម្លើយ ប៊ូ ម៉ៅ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣០។ ឯកសារ **D119/123** កំណត់ហេតុស្តាប់ចម្លើយ ហែម មាន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៦ដល់៧។ ឯកសារ D119/110 កំណត់ហេតុស្តាប់ចម្លើយ ជុំ កន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤១។ ឯកសារ **D119/49** កំណត់ហេតុស្តាប់ចម្លើយ ធីប សម្បត្តិ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៦។ ឯកសារ D119/73 កំណត់ហេតុស្តាប់ចម្លើយ នូ ដួង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៤ ដល់២៨។ ឯកសារ **D119/33** កំណត់ហេតុស្តាប់ចម្លើយ ឈិត យក់ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២១។ ឯកសារ **D1.3.4.6** ចម្លើយសារភាពមន្ទីរស២១ របស់គង់ សុផល ហៅគោ នៅត្រង់ឯកសារភាសាអង់គ្លេស 00217743 [បានបញ្ជាក់ថា “ចែម(ស)” ជា “លេខាស្រុកព្រះនេត្រព្រះ”]។

[61] ឯកសារ D1.3.12.1 កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, នៅត្រង់ឯកសារភាសាអង់គ្លេស 00217518។ ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ឯកសារភាសាអង់គ្លេស 00951801-02 [ស្រុកព្រះនេត្រព្រះមានប្រជាជនមូលដ្ឋាន ១០ ០០០នាក់ និងប្រជាជនថ្មី ៩០ ០០០នាក់]។ ឯកសារ **D1.3.10.3** របាយការណ៍ដែលមានចំណងជើងថា ទស្សនៈទូទៅនៃតំបន់ **៥, ថ្ងៃទី ២៧** ខែ មិថុនា ឆ្នាំ ១៩៧៧ នៅត្រង់ឯកសារភាសាអង់គ្លេស 00223176-77 [ក៏បានកត់សម្គាល់ផងដែរថាមាន "សមាសធាតុមិនល្អ" ជាច្រើននៅព្រះនេត្រព្រះ]។

មកតាមគាត់[62] ដកហូតអាវុធពីកងឈ្លបក្នុងស្រុក[63] រៀបចំឡើងវិញនូវកម្លាំងរបស់កងចល័ត និងកងឈ្លបនៅក្នុងតំបន់របស់គាត់[64] និងបានតែងតាំងមនុស្សដែលបានគាត់ជ្រើសរើស និងយកមកពីពាយ័ព្យ ឱ្យកាន់តំណែងនៅឃុំ និងសហករណ៍[65]។ អ៊ឹម ចែម បានបញ្ជាក់ថាគាត់មកដល់ព្រះនេត្រព្រះ មុនពេលអតីតមេស្រុក (មោង) ត្រូវបានគេ "យកទៅ"[66]។ កំណត់ត្រា ស២១ បានបញ្ជាក់ថា លេខា

[62] ឯកសារD1.3.12.1 កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, នៅត្រង់ ឯកសារភាសាអង់គ្លេស 00217519។ ឯកសារ**D219/37** កំណត់ហេតុស្តាប់ចម្លើយ សួន មុត ដោយក.ស.ច.ស នៅត្រង់ចម្លើយ ៣១ដល់៣៥ [សក្ខីកម្មរបស់កម្មាភិបាលនិរតី ដែលជាផ្នែកនៃក្រុមដែលមានគ្នា១០០០នាក់ ដឹកនាំដោយអ៊ឹម ចែម មកពីតាកែវ ទៅស្វាយស៊ីសុផុន ដែលរួមមាន "មេភូមិ មេឃុំ ឈ្លប និងពេទ្យ"]។ ឯកសារ **D106/5** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយក.ស.ច.ស នៅត្រង់ចម្លើយ ១១ដល់១២។ ឯកសារ **D119/65** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៣៩ដល់៤១, ៤៤ [បញ្ជាក់ថាមានមនុស្ស ២០០០នាក់ នៅក្នុងក្រុមដែលដឹកនាំដោយ អ៊ឹម ចែម មកពីនិរតីទៅតំបន់៥ នៃភូមិភាគពាយ័ព្យ ដោយក្នុងនោះរួមមាន "កងទ័ព៣០០០នាក់" និងកងនារី ៣០០ ទៅ៤០០នាក់ មកពីស្រែអំបិល]។

[63] ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951804 ["ខ្ញុំប្រមូលកាំភ្លើងទាំងអស់ពីឈ្លប ហើយយកមកទុកនៅផ្ទះខ្ញុំ"]។ ឯកសារ D123/1/5.1a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00089776 ["ខ្ញុំដកហូតកាំភ្លើងពីពួកឈ្លប"]។ ឯកសារ **D219/23** កំណត់ហេតុស្តាប់ចម្លើយ ពុំ កូ ដោយក.ស.ច.ស នៅត្រង់ចម្លើយ ៥៧ ដល់៥៨ [អតីតជំនួយការគណៈស្រុកព្រះនេត្រព្រះបានរៀបរាប់ពីការដែលគាត់បានប្រគល់អាវុធ ទៅឱ្យយាយចែមនៅផ្ទះរបស់គាត់]។

[64] ឯកសារD1.3.12.1 កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, នៅត្រង់ ឯកសារភាសាអង់គ្លេស 00217520-21។ ឯកសារ D123/1/5.1a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00089773, 00089776។

[65] ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951798-99។ ឯកសារ D119/65 កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៧១ ដល់៧៣ [រៀបរាប់ពីការប្រជុំដែលតាឆែល និងយាយចែម បានចាត់តាំងកម្លាំង], ចម្លើយ ៨០ ["យាយចែមគឺជាអ្នកដែលបង្គាប់ខ្ញុំឱ្យរៀបចំកងកម្លាំង"], ចម្លើយ ៨៥, ៩៦។ ឯកសារ D119/20 កំណត់ហេតុស្តាប់ចម្លើយ លី ស៊ិញ ដោយក.ស.ច.ស នៅត្រង់ចម្លើយ ៣ដល់៥ [អតីតប្រពន្ធរបស់សាក្សីជាស្ថិតក្នុងក្រុមកម្មាភិបាលនិរតី ដែលមកព្រះនេត្រព្រះជាមួយអ៊ឹម ចែម ក្នុងខែ មិថុនា ឬ កក្កដា ឆ្នាំ ១៩៧៧]។ ឯកសារ D119/110 កំណត់ហេតុស្តាប់ចម្លើយ ជុំ កន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤១ [សាក្សីត្រូវបានចែមតែងតាំងជាគណៈឃុំភ្នំលាភ]។

[66] ឯកសារD1.3.12.1 កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, នៅត្រង់ ឯកសារភាសាអង់គ្លេស 00217518-20។ ឯកសារ D123/1/5.1a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00089773។ ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951797 ["នៅពេលមកដល់អតីតគណៈស្រុកគឺនៅទីនោះនៅ

ស្រុកព្រះនេត្រព្រះ អាន មោង បានចូលស២១ នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៧៧ ហើយប្រហែលជាត្រូវបានចាប់ខ្លួនយ៉ាងច្រើនបំផុត១០ថ្ងៃមុន[67]។ ការនេះបានច្រានចោទការអះអាងរបស់ អ៊ឹម ចែម ដែលថា គាត់បានផ្លាស់ទីទៅព្រះនេត្រព្រះនៅចុងឆ្នាំ ១៩៧៨[68] ហើយបានបញ្ជាក់ថាគាត់បានទទួលតួនាទីថ្មីនៅក្នុងស្រុកនោះ នៅខែ មិថុនា ឆ្នាំ ១៩៧៨ គឺនៅមុនពេលចាប់ខ្លួន និងបោសសម្អាតអតីតមេដឹកនាំស្រុក។

16. បន្ថែមពីលើតួនាទីរបស់គាត់ជាលេខាស្រុកព្រះនេត្រព្រះ អ៊ឹម ចែម បានក្លាយជាសមាជិក និងក្រោយមកជាអនុលេខាគណៈកម្មាការតំបន់ ៥[69]។ ប្តីរបស់គាត់ឈ្មោះញ៉ែន ត្រូវបានតែងតាំងជាលេខាស្រុកសេរីសោភ័ណ (ពេលខ្លះហៅថាស្វាយស៊ីសុផុន)[70]។ ដូច្នេះអ៊ឹម ចែម និងប្តីរបស់គាត់បានត្រួតត្រា

---

ឡើយ"]។ សូមមើលផងដែរ ឯកសារ **D119/65** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៨១។ ឯកសារ **D219/23** កំណត់ហេតុស្តាប់ចម្លើយ ពុំ កូ ដោយក.ស.ច.ស នៅត្រង់ចម្លើយ ៦៩។

[67] ឯកសារ **D191.1.111** បញ្ជីឈ្មោះអ្នកទោស ស២១ ដែលត្រូវបានកម្ទេចនៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៧៧, នៅត្រង់ឯកសារភាសាអង់គ្លេស 00873645 (No. 134)។ ឯកសារ **D6.1.883** បញ្ជីឈ្មោះអ្នកទោស ស២១ ដែលក.ស.ព បានកែសម្រួលហើយ [No. 57]។ ឯកសារ **D1.3.4.1** ចម្លើយសារភាពមន្ទីរស២១ របស់ អាន មោង, ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៧ នៅត្រង់ឯកសារភាសាអង់គ្លេស 00786926 ["នៅថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ១៩៧៧, អង្គការបានចាប់ខ្លួនយើង"]។

[68] ឯកសារ D123/1/5.1c បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951851។

[69] ឯកសារ**D219/4.1** កិច្ចសម្ភាសន៍ជាមួយ សួន មុត ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ ឯកសារភាសាអង់គ្លេស 01056808 [ចែមនៅគណៈតំបន់៥ជាមួយ ហឿន រិន និងជាល]។ ឯកសារ**D219/37** កំណត់ហេតុស្តាប់ចម្លើយ សួន មុត ដោយក.ស.ច.ស នៅត្រង់ចម្លើយ ៤២ ដល់៤៤, ៥២ដល់៥៤ [បញ្ជាក់អ៊ឹម ចែមធ្វើការនៅមន្ទីរស្រុកស្វាយស៊ីសុផុន ព្រះនេត្រព្រះ និងភ្នំស្រុក ហើយបានចូលរួមក្នុងកិច្ចប្រជុំនៅមន្ទីរតំបន់៥]។ ឯកសារ **D119/91** កំណត់ហេតុស្តាប់ចម្លើយ ជៀម តាប់ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៥, ២៥។ ឯកសារ **D119/69/2** កិច្ចសម្ភាសន៍ជាមួយ ក្រូច ទឹម ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ ឯកសារភាសាអង់គ្លេស 00986290 ["ចែមជាគណៈតំបន់"]។ ឯកសារ D119/108 កំណត់ហេតុស្តាប់ចម្លើយ សុខ រុំ ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១០៧, ១១២, ១២៤ [បញ្ជាក់ថាយាយ ចែមជាញឹកញាប់មកធ្វើការនៅស្វាយស៊ីសុផុន ហើយបានកោះហៅគណៈស្រុកមកប្រជុំរៀងរាល់១០ថ្ងៃម្តង]។ ឯកសារ D119/66 កំណត់ហេតុស្តាប់ចម្លើយ បិន ហុយ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១១។ ឯកសារ **D118/65** កំណត់ហេតុស្តាប់ចម្លើយ ជឹម ចាន់ធឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ២៩។

[70] ឯកសារ D123/1/5.1a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00089782។ ឯកសារ D123/1/5.1c បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951863។ ឯកសារ D119/94 កំណត់ហេតុស្តាប់ចម្លើយ ប៊ូ ម៉ៅ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥២។ ឯកសារ D119/156 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ជឿន

ស្រុកពីរ ក្នុងចំណោមស្រុកទាំងបួននៅក្នុងតំបន់៥។ ប្រធានសហករណ៍ភ្នំស្រុកម្នាក់បានផ្តល់សក្ខីកម្ម ថា គាត់និងកម្មាភិបាលតំបន់ដទៃទៀត ត្រូវបានគេកោះហៅទៅប្រជុំនៅស្រុកព្រះនេត្រព្រះ ក្នុងខែ កក្កដា ឬសីហា ឆ្នាំ ១៩៧៧ ដែលកិច្ចប្រជុំនេះដឹកនាំដោយ អ៊ឹម ចែម និងប្តីរបស់គាត់ ហើយនៅក្នុងកិច្ចប្រជុំនេះអ៊ឹម ចែមបានប្រកាសថា គាត់គឺជា "គណៈតំបន់៥ថ្មី" ហើយបានដកគាត់ចេញពីតំណែងរបស់គាត់[71]។ ក្នុងពេលនៅភូមិភាគពាយ័ព្យ អ៊ឹម ចែម បានជួប ហើយទទួលបញ្ជាពីតា ម៉ុក ហើយគាត់បានបញ្ជាក់ថាទំនាក់ទំនងរបស់ពួកគាត់គឺជិតស្និទ្ធខ្លាំង ដល់ថ្នាក់គាត់មិនខ្លាចក្នុងការសួរដេញដោលលើការបញ្ជារបស់តា ម៉ុក ព្រមទាំងហ៊ានជំទាស់ជាមួយតាម៉ុក និងពិភាក្សាជាចំហរអំពីការខ្វះខាតអាហារនៅស្រុករបស់គាត់[72]។ សាក្សីម្នាក់បានរៀបរាប់ថា ចែមគឺជា "ដៃស្តាំរបស់តា ម៉ុក"[73]។

17. ឯកសារសម័យកម្ពុជាប្រជាធិបតេយ្យបានកំណត់ពី កាលបរិច្ឆេទដែលសមាជិកចាស់របស់គណៈតំបន់៥ ត្រូវបានចាប់ខ្លួន ហើយអ៊ឹម ចែម បានចាប់ផ្តើមតួនាទីរបស់គាត់នៅក្នុងគណៈតំបន់នោះ។ អ៊ឹម ចែមបានបញ្ជាក់ថា ហ្មឿងដែលជាអតីតលេខាតំបន់៥ ត្រូវបានគេយកទៅនៅពេលដែលគាត់មក

---

ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ២៧ [សក្ខីកម្មរបស់អតីតកម្មាភិបាលនិរតី ដែលបានផ្ទេរពីអង្គរជ័យមកស្វាយស៊ីសុផុន នៅក្នុងឆ្នាំ ១៩៧៧]។ ឯកសារ **D119/115** កំណត់ហេតុស្តាប់ចម្លើយ ទិល ហារ ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ២១ដល់ ២២។ ឯកសារ**D219/37** កំណត់ហេតុស្តាប់ចម្លើយ សួន មុត ដោយក.ស.ច.ស នៅត្រង់ចម្លើយ ៤៥។ ឯកសារ **D219/4.1** កិច្ចសម្ភាសន៍ជាមួយ សួន មុត ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ឯកសារភាសាអង់គ្លេស 01056798, 01056805 [កត់សម្គាល់ថាញ៉ែនត្រូវបានផ្ទេរនៅពេលក្រោយមក ពីសេរីសោភ័ណ្ឌទៅស្រុកភ្នំស្រុក]។

[71] ឯកសារ **D119/91** កំណត់ហេតុស្តាប់ចម្លើយ ជៀម តាប់ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៥ដល់២០ [ក៏បានបញ្ជាក់ផងដែរថាមានតែយាយ ចែម និងប្តីរបស់គាត់ប៉ុណ្ណោះដែលបានឡើងនិយាយនៅក្នុងសមាជ]។

[72] ឯកសារ D123/1/5.1a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00089777។ ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951810-12 ["ចំពោះខ្ញុំ ខ្ញុំហ៊ានរាយការណ៍ទៅគាត់ព្រោះខ្ញុំស្គាល់គាត់ច្បាស់... នៅពេលដែលគាត់និយាយមួយម៉ាត់ ខ្ញុំឆ្លើយទៅវិញពីរម៉ាត់"]។ ឯកសារ **D119/123** កំណត់ហេតុស្តាប់ចម្លើយ ហែម មាន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២០ [និរសាបានរៀបរាប់ពីការបញ្ជូនសំបុត្រពីតាម៉ុក ទៅយាយចែម]។ ឯកសារ D219/294 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥៥ដល់៥៨។ ឯកសារ D119/66 កំណត់ហេតុស្តាប់ចម្លើយ ប៊ិន ហុយ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៥ [រៀបរាប់ពីកិច្ចប្រជុំដឹកនាំដោយតាម៉ុក និងយាយចែម ក្នុងឆ្នាំ ១៩៧៨]។

[73] ឯកសារ **D119/124** កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម អេន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២២។ *សូមមើលផងដែរ* ឯកសារ **D219/294** កំណត់ហេតុស្តាប់ចម្លើយ មូល អេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៦៣។

ដល់តំបន់[74] ដោយទុក "តាឡៃ និងជាល (កូនប្រុសរបស់លេខាភូមិភាគឈ្មោះ ញឹម)" ឲ្យនៅថ្នាក់តំបន់[75]។ គង់ ឡែម ហៅឡៃដែលជាសមាជិកគណៈតំបន់៥ បានចូលស២១នៅថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៧៧[76] ចំណែក ជាល ត្រូវបានចាប់ខ្លួនប្រហែលនៅពេលជាមួយនឹងឪពុករបស់គាត់នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៨[77]។ វុធដែលជាសមាជិកម្នាក់ទៀតនៃអតីតគណៈតំបន់ ត្រូវបានបោសសម្អាតនៅក្នុងឆ្នាំ ១៩៧៧ផងដែរ[78]។ ហឿងត្រូវបានជំនួសដោយកម្មាភិបាលនិរតីឈ្មោះ ហេង រិន ហៅម៉ី ក្នុង

---

[74] ឯកសារD1.3.12.1 កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, នៅត្រង់ ឯកសារភាសាអង់គ្លេស 00217520។ D123/1/5.1c បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951854។លេខាតំបន់ ៥ ឈ្មោះមែន ឈុន ហៅហឿងត្រូវបានដកចេញពីភូមិភាគពាយ័ព្យ ហើយបញ្ជូនទៅក្រសួងការបរទេស នៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៧៧ ហើយពីរសប្តាហ៍ក្រោយមកគឺនៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៧៧ ត្រូវបានចាប់ខ្លួន ហើយត្រូវបានបញ្ជូនទៅស២១។ ឯកសារ **D1.3.25.4** បញ្ជីអ្នកទោសស២១, ខែ កញ្ញា ឆ្នាំ ១៩៧៧, នៅត្រង់ ឯកសារភាសាអង់គ្លេស 00837611 (No. 42)។ឯកសារ **D6.1.326** ចម្លើយសារភាពរបស់ មែន ឈុន ហៅហឿង នៅមន្ទីរស២១ នៅត្រង់ ឯកសារភាសាអង់គ្លេស 00766159។ឯកសារ **D1.3.10.3** របាយការណ៍ដែលមានចំណងជើងថា ទស្សនៈទូទៅនៃតំបន់ ៥, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៧៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00223175 [បញ្ជាក់ថា ហឿង "ត្រូវបានចាប់ខ្លួន"]។

[75] ឯកសារ D123/1/5.1a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00089774-75។

[76] ឯកសារ **D191.1.111** បញ្ជីឈ្មោះអ្នកទោស ស២១ ដែលត្រូវបានកម្ទេចនៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៧៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00873628 (No. 248)។ ឯកសារ **D191.1.111** បញ្ជីឈ្មោះអ្នកទោស ស២១ ដែលត្រូវបានកម្ទេចនិងថតរូប , នៅត្រង់ ឯកសារភាសាអង់គ្លេស 00873281 (No. 9)។

[77] ឯកសារ **D119/98** កំណត់ហេតុស្តាប់ចម្លើយ កោ ឡេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៩ [ញឹម និងជាល ត្រូវបានបោសសម្អាតនៅពាក់កណ្តាលឆ្នាំ ១៩៧៨]។ ឯកសារ **D119/65** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៩៥ [តាជាលបានបាត់ខ្លួននៅពាក់កណ្តាលឆ្នាំ ១៩៧៨]។ ឯកសារ **D1.3.18.2** ចម្លើយសារភាពរបស់មូល សម្បត្តិ ហៅរស់ ញឹម នៅមន្ទីរស២១, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៧៨។ ឯកសារ **D6.1.1105** Ben Kiernan, *របបប៉ុល ពត* នៅត្រង់ ឯកសារភាសាអង់គ្លេស 00678710។

[78] ឯកសារ **D1.3.10.3** របាយការណ៍ដែលមានចំណងជើងថា ទស្សនៈទូទៅនៃតំបន់ ៥, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៧៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00223175។ឯកសារ **D6.1.364** កំណត់ហេតុស្តាប់ចម្លើយ ឈឿន សែម ដោយ ក.ស.ច.ស នៅត្រង់ ឯកសារភាសាអង់គ្លេស 00338375 [សក្ខីកម្មរបស់ប្តីប្រពន្ធលេខាស្រុកភ្នំស្រុក ឈ្មោះហាត់ ថាតាវុធអតីតអនុរបស់ហឿង ត្រូវបានចាប់ខ្លួន និងសម្លាប់]។ ឯកសារ **D119/156** កំណត់ហេតុស្តាប់ចម្លើយ ឈឿង ជឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ២៩ [កម្មាភិបាលនិរតីដែលត្រូវបានផ្ទេរពីភូមិភាគពាយ័ព្យ នៅពាក់កណ្តាលឆ្នាំ ១៩៧៧ បានបញ្ជាក់ថា "ជាល, វុធ និង ឡៃ គឺជាគណៈតំបន់៥" នៅពេលដែលគាត់មកដល់ ប៉ុន្តែក្រោយមកនៅក្នុងឆ្នាំដដែលនេះ ពួកគេបានបាត់ខ្លួន]។

តំណែងជាលេខាតំបន់៥[79]។ ផ្អែកលើពេលវេលានេះ អ៊ឹម ចែម បានក្លាយជាសមាជិកគណៈតំបន់៥ ស្ថិតក្រោមរិន មុនខែ កញ្ញា ឆ្នាំ ១៩៧៧ (គឺនៅពេលចាប់ខ្លួនឡៃ) ហើយបានក្លាយជាអនុលេខាមុនខែ មិថុនា ឆ្នាំ ១៩៧៨ (គឺ នៅពេលចាប់ខ្លួនជាល)។ រចនាសម្ព័ន្ធអង្គភាពរបស់តំបន់៥ ដោយផ្អែកលើ កំណត់ត្រាស២១ ព្រមទាំងរបាយការណ៍ និងការសម្ភាសន៍អតីតកម្មាភិបាលភូមិភាគពាយ័ព្យ ត្រូវ បានភ្ជាប់ជាមួយជាឧបសម្ព័ន្ធក។

18. នៅចុងឆ្នាំ ១៩៧៨ តំបន់នានារបស់ភូមិភាគពាយ័ព្យ ត្រូវបានរៀបចំឡើងវិញ ហើយតំបន់ថ្មីមួយត្រូវ បានបង្កើតឡើងដោយបញ្ចូលផ្នែកខាងជើងនៃតំបន់៣ចាស់ (មង្គលបុរី) ទៅក្នុងតំបន់៥[80]។ រិន ដែល ជាលេខាតំបន់៥ចាស់ ត្រូវបានចាប់ខ្លួននៅក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៨[81] ហើយត្រូវបានជំនួសដោយអតីត មេស្រុកត្រាំកក់ គឺតាចាយ[82]។ កម្មាភិបាលភូមិភាគនិរតីដែលត្រូវបានចាត់តាំងដោយតាចាយ ឲ្យមក

---

[79] ឯកសារ **D119/156** កំណត់ហេតុស្តាប់ចម្លើយ ឈឿង ជឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ២៦, ២៨ដល់២៩ ។ ឯកសារ **D119/94** កំណត់ហេតុស្តាប់ចម្លើយ ប៊ូ ម៉ោ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៣។ ឯកសារ **D119/98** កំណត់ហេតុស្តាប់ចម្លើយ កោ ឡេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១១ [តារិនជំនួសហឿង ជាគណៈតំបន់]។ ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951805 ["ពូរិនមកពីកំពត" បានមកគ្រប់គ្រងតំបន់ ៥ ជំនួសជាល]។ មុនពេលរិនមកដល់ ជាលដែលជាកូនរបស់រស់ ញឹមដែលលេខាភូមិភាគ គឺជាប្រធានតំបន់បណ្តោះអាសន្ន។ ឯកសារ **D119/33** កំណត់ហេតុស្តាប់ចម្លើយ ឈិត យក់ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៣ ["នៅក្នុងតំបន់ ៥ ក្រោយពេលតា ហឿនត្រូវបានចាប់ខ្លួន តា ជាលបានមកជំនួសគាត់ប្រហែលបីបួនខែ ហើយក្រោយមករិន (មកពីភូមិភាគនិរតី) បានមកជំនួសតាជាល"]។ ឯកសារ **D67.6** កិច្ចសម្ភាសន៍ជាមួយ ប៉ាន់ ឆុង ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ ឯកសារភាសាអង់គ្លេស 00728686-88, 00728691 [បញ្ជាក់ថា ជាលគឺជាប្រធានតំបន់បាន "ប្រហែលបីខែ" ហើយក្រោយពេលតែងតាំងរិន ជាល ក្លាយជាអនុ ឬ "ជំនួយការ"]។

[80] ឯកសារ **D118/93** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ស៊ឹម ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៤ ដល់១៨។ ឯកសារ **D67.9** កិច្ចសម្ភាសន៍ជាមួយ ឈីត យឿក ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ ឯកសារភាសាអង់គ្លេស 00731140 ["មង្គលបូរីនិងបរិលស្ថិតនៅក្នុងតំបន់ ៥"]។ ឯកសារD118/153 កំណត់ហេតុស្តាប់ចម្លើយ ឡុង វុន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣២ ដល់៣៥ ។ ឯកសារ D219/294 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤១ ដល់៤២។

[81] ឯកសារ **D6.1.44** តារាងសួរចម្លើយនៅស២១, ខែ ធ្នូ ឆ្នាំ ១៩៧៨, នៅត្រង់ ឯកសារភាសាអង់គ្លេស 00789707 [បានកត់ត្រាថារិន ចូលមន្ទីរស២១ នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨។ ប្រពន្ធរបស់គាត់ និងក្មួយស្រីអាយុ១៣ឆ្នាំ ត្រូវបានបញ្ជូនទៅស២១ នៅពីរសប្តាហ៍ក្រោយ]។ ឯកសារ **D1.3.4.4** ចម្លើយសារភាពរបស់ ហឿង រិន ហៅម៉ី នៅ មន្ទីរស២១, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨។ ឯកសារ **D6.1.883** បញ្ជីឈ្មោះអ្នកទោស ស២១ ដែលក.ស.ព បានកែសម្រួលហើយ [No. 2431].

[82] ឯកសារ**D219/37** កំណត់ហេតុស្តាប់ចម្លើយ សួន មុត ដោយក.ស.ច.ស នៅត្រង់ចម្លើយ ៤៩ដល់៥០ ["បន្ទាប់ពីតារិនត្រូវបានចាប់ខ្លួន តាចាយដឹកនាំជំនួសតារិន ហើយធ្វើការជាមួយយាយចែម"]។ ឯកសារ**D219/4.1** កិច្ចសម្ភាសន៍ជាមួយ សួន មុត

ភូមិភាគពាយ័ព្យ ហើយដែលមានវត្តមាននៅក្នុងកិច្ចប្រជុំ គណៈកម្មាធិការតំបន់ថ្មី បានផ្តល់សក្ខីកម្មថា អ៊ឹម ចែមបានក្លាយជាអនុលេខាតំបន់ថ្មីនោះ[83]។ គាត់ក៏បានបញ្ជាក់ផងដែរថា ញ៉ែន ដែលជាប្តីរបស់ អ៊ឹម ចែម ក៏បានក្លាយជាសមាជិកគណៈកម្មាធិការតំបន់ផងដែរ[84]។ ហេតុដូច្នេះបើទោះបីជាកម្មាភិបាលខ្លះបានផ្តល់សក្ខីកម្មថា អ៊ឹម ចែម បានក្លាយជាលេខាតំបន់ ក្រោយពេលវិនត្រូវបានចាប់ខ្លួនក៏ដោយ[85] តែតួនាទីជាក់ស្តែងរបស់គាត់ហាក់បីដូចជា បានក្លាយជាអនុលេខាតំបន់ដែលបានពង្រីកថ្មី ហើយត្រូវទទួលខុសត្រូវលើអតីតស្រុកនានានៃតំបន់៥។

19. ហេតុដូច្នេះភស្តុតាងបានកំណត់ថា អ៊ឹម ចែម មានតួនាទីយ៉ាងសំខាន់ក្នុងសិទ្ធិអំណាច នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅកម្រិតថ្នាក់ស្រុក និងថ្នាក់តំបន់ ហើយនៅពេលចុងក្រោយនៃរបប គាត់បានឡើងតួនាទីទៅជា អនុលេខាតំបន់ដ៏សំខាន់មួយ នៅក្នុងភូមិភាគពាយ័ព្យ។ គាត់បាននិយាយថា

---

ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ ឯកសារភាសាអង់គ្លេស 01056807-08, 01056814។ ឯកសារ **D119/123** កំណត់ហេតុស្តាប់ចម្លើយ ហែម មាន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥ដល់១៦ [សាក្សីបានបញ្ជូនលិខិតពីតាចាយទៅយាយចែម]។ ឯកសារ **D118/93** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សឹម ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៧ដល់៩, ១៧ដល់១៩ ["ស៊ីសុផុននិងមង្គលបូរីគឺស្ថិតនៅក្នុងតំបន់តែមួយ ក្រោមតាចាយ"], ឆ ៣៣ ។ ឯកសារ **D219/294** កំណត់ហេតុស្តាប់ចម្លើយ មួល អេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤១, ៤៥។

[83] ឯកសារ **D118/93** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សឹម ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៩ ដល់២១។ សូមមើលផងដែរ ឯកសារ **D118/153** កំណត់ហេតុស្តាប់ចម្លើយ ឡុង វុន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥៧ដល់៥៩ [កម្មាភិបាលមានវត្តមាននៅកិច្ចប្រជុំគណៈតំបន់ថ្មី ដែលរួមមានតាចាយ និងយាយ ចែម]។ ឯកសារ**D219/4.1** កិច្ចសម្ភាសន៍ជាមួយ សួន មុត ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ ឯកសារភាសាអង់គ្លេស 01056814 ["សៈ ពួកគេចាប់ខ្លួនតាជាល និងក្រោយមកតាវិន។ តើមានតែយាយ ចែម ទេឬដែលនៅសល់? ឆៈ មានតែយាយ ចែមទេដែលនៅ ហើយបន្ទាប់មកតា ចាយ មក"]។ ឯកសារ **D119/20** កំណត់ហេតុស្តាប់ចម្លើយ លី ស៊ិញ ដោយក.ស.ច.ស នៅត្រង់ចម្លើយ ១៦ [ចែមត្រូវបានតែងតាំងជាគណៈតំបន់៥ នៅចុងឆ្នាំ ១៩៧៨]។

[84] ឯកសារ **D118/93** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សឹម ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៩។

[85] សូមមើលជាឧទាហរណ៍, ឯកសារ **D119/33** កំណត់ហេតុស្តាប់ចម្លើយ ឈិត យក់ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៧, ១៩ដល់២០ [សក្ខីកម្មរបស់អតីតប្រធានសេដ្ឋកិច្ចចល័ត តំបន់៥ បានថា យាយ ចែម ជា "លេខាតំបន់បណ្តោះអាសន្ន" នៅជិតចុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងអំឡុងពេលនោះគាត់បានជួបជាមួយចែម ដើម្បីពិភាក្សាពីការផ្គត់ផ្គង់ស្រូវ]។ ឯកសារ **D67.9** កិច្ចសម្ភាសន៍ជាមួយ ឈើត យឿក ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ ឯកសារភាសាអង់គ្លេស 00731142។

គាត់ត្រូវបានគេដំឡើងឋានៈ ទៅដល់ឋានៈក្នុងបក្សកុម្មុយនីស្តកម្ពុជា ដោយសារតែគាត់បំពេញ "ភារកិច្ចបានល្អ" និងអាច "បំពេញបានតាមផែនការ (បក្ស)"[86]។

### ខ. ការទទួលខុសត្រូវលើការចាប់ខ្លួន និងការសម្លាប់[87]

20. អ៊ឹម ចែម បានបដិសេធមិនបានបញ្ជា ឬចូលរួមនៅក្នុងការសម្លាប់ណាមួយឡើយ ហើយគាត់បានអះអាងថាកងទ័ពជាអ្នកទទួលខុសត្រូវលើបញ្ហាបែបនេះ[88]។ ប៉ុន្តែក្នុងនាមជាលេខាស្រុកនៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ អ៊ឹម ចែម បានត្រួតត្រាទៅលើឈ្លបស្រុក ហើយមានសិទ្ធិអំណាចចាប់ខ្លួនប្រជាជន ហើយបញ្ជូនអ្នកទាំងនោះទៅមន្ទីរសន្តិសុខ ឬអប់រំ[89]។ ចម្លើយផ្ទាល់របស់អ៊ឹម ចែម

[86] ឯកសារ **D1.3.12.1** កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, នៅត្រង់ ឯកសារភាសាអង់គ្លេស 00217517-18 ["ដោយបង្ហាញថាខ្ញុំបំពេញភារកិច្ចខ្ញុំបានល្អ គេផ្តល់ភារកិច្ចបន្ថែមទៀតមកខ្ញុំ ខ្ញុំទទួលបានភារកិច្ចបន្ថែមចាប់ពីកម្រិតភូមិ ឡើងដល់កម្រិតឃុំហើយបន្ទាប់មកកម្រិតស្រុក"]។ ឯកសារ **D123/1/5.1c** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951842, 00951845។

[87] នៅក្នុងផ្នែកបន្ត សហព្រះរាជអាជ្ញាអន្តរជាតិបានផ្តោតជាចម្បងទៅលើឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខភ្នំត្រយោង និងការដ្ឋានស្ពានស្រែង ដែលអ៊ឹម ចែមត្រូវបានចោទប្រកាន់ ដូចក្នុងការជូនដំណឹងដែលបានដាក់ដោយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥។ ឯកសារ **D239.1** ការជូនដំណឹងពីបទចោទប្រឆាំង អ៊ឹម ចែម។ ហេតុដូច្នេះសារណានេះដោះស្រាយចំពោះការទទួលខុសត្រូវរបស់គាត់ ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត នៅទីកន្លែងដទៃទៀត អនុលោមតាមផែនការឧក្រិដ្ឋរួម។

[88] ឯកសារD1.3.12.1 កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, នៅត្រង់ ឯកសារភាសាអង់គ្លេស 00217532-33, 00217543 ["បញ្ហានេះគួរតែជារបបកងទ័ព ដែលមានអាវុធបាញ់ប្រហារ"]។

[89] ឯកសារ **D119/65** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១៨៩, ២២២ ដល់២២៣ [ចែមបានស្នើសហករណ៍ "ឲ្យជូនដំណឹងមកគាត់អំពីបញ្ហានានា" ហើយគាត់សម្រេច "នរណាដែលត្រូវបញ្ជូនទៅមន្ទីររៀនសូត្រ"]។ ឯកសារ **D119/64.1** កិច្ចសម្ភាសន៍ជាមួយ ទុំ សឿន ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ ឯកសារភាសាអង់គ្លេស 00951706, 00951711-13 [ចែមបានបញ្ជូនអ្នកជាប់ឃុំទៅមន្ទីរសន្តិសុខ ហើយគាត់ទទួលខុសត្រូវលើផ្នាំសន្តិសុខនៅព្រះនេត្រព្រះ]។ ឯកសារ **D119/144** កំណត់ហេតុស្តាប់ចម្លើយ ឡាត សយ ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៥២ដល់៥៣, ៥៨, ៦២ ដល់៦៣ [សក្ខីកម្មរបស់កងទ័ពស្រុកភ្នំស្រុក]។ ឯកសារ **D119/94** កំណត់ហេតុស្តាប់ចម្លើយ ប៊ូ ម៉ៅ ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៥៤, ៥៦ [យាយ ចែម ទទួលខុសត្រូវលើឈ្លបប្រដាប់អាវុធ និងមន្ទីរសន្តិសុខនៅស្រុកព្រះនេត្រព្រះ]។ ឯកសារ **D119/29** កំណត់ហេតុស្តាប់ចម្លើយ ផាន ឈួង ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ២២។ ឯកសារ **D119/49** កំណត់ហេតុស្តាប់ចម្លើយ ធីប សម្បត្តិ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣៩, ៤៣ដល់៤៥។ ឯកសារ **D119/16** កំណត់ហេតុស្តាប់ចម្លើយ កៅ ជឹង ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ២១, ២៤។ ឯកសារ **D219/37** កំណត់ហេតុស្តាប់ចម្លើយ សួន មុត ដោយក.ស.ច.ស នៅត្រង់ចម្លើយ ៥៥ [ចែមធ្វើដំណើរដោយមាននិរសា "ប្រដាប់ដោយអាវុធ" អមដំណើរ]។ ឯកសារ D119/90 កំណត់ហេតុស្តាប់ចម្លើយ ជួន ភាព ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៣ [ចែមអមដំណើរដោយ "យោធា

បានផ្ទុះបញ្ចាំងពីសិទ្ធិអំណាចក្នុងការសម្រេចរបស់គាត់ ពាក់ព័ន្ធការចាប់ខ្លួន និងការឃុំខ្លួនអ្នកទោស[90]។ អតីតនិរសាររបស់គាត់បានផ្តល់សក្ខីកម្មថា អ៊ឹម ចែមបើកកិច្ចប្រជុំនៅផ្ទះរបស់គាត់ ជាមួយប្រធានសហករណ៍ ហើយជា "អ្នកសម្រេច" ថានរណាខ្លះដែលត្រូវចាប់ខ្លួន[91]។ ការនេះគឺស្របជាមួយភស្តុតាងមកពីតំបន់ដទៃទៀត ក្នុងកម្ពុជាប្រជាធិបតេយ្យ អំពីសិទ្ធិអំណាចរបស់លេខាស្រុក[92]

---

ប្រដាប់ដោយអាវុធ" នៅពេលចុះពិនិត្យមើលការដ្ឋាន]។ ឯកសារ **D219/294** កំណត់ហេតុស្តាប់ចម្លើយ មូល អេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៨៦ ដល់១៨៨។ យោង ឯកសារ D119/110 កំណត់ហេតុស្តាប់ចម្លើយ ជុំ កន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៧៦ដល់៨៤ [មេឃុំភ្នំលាភផ្តល់សក្ខីកម្មថា គាត់បានទទួលបញ្ជាពីចែមឲ្យ "បញ្ជូនមនុស្សទៅរៀនសូត្រ" ប៉ុន្តែគាត់ជឿថា បញ្ជានេះចេញពីកម្រិតតំបន់ ឬភូមិភាគ]។

[90] ឯកសារ D123/1/5.1a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00089782 [បានរៀបរាប់ថាតើគាត់បដិសេធ មិនចាប់ខ្លួនមនុស្សមួយចំនួនដោយរបៀបណា]។ ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951797 [អះអាងថាគាត់បានប្តូរទៅនៅផ្ទះនៅភ្នំលាភ ដែលផ្ទះនោះជាមន្ទីរឃុំឃាំង ហើយគាត់បានដោះលែងអ្នកទោសទាំងអស់], 00951816 [រៀបរាប់ពីការដែលគាត់ "បញ្ជា" ឲ្យដោះលែងអ្នកទោសម្នាក់]។

[91] ឯកសារ **D219/397** កំណត់ហេតុស្តាប់ចម្លើយ ប៊ិន សុខ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤២ ["ប្រធានសហករណ៍ទាំងអស់មកពិភាក្សាជាមួយគាត់ អំពីការចាប់ខ្លួនដែលពួកគេចង់អនុវត្ត។ នេះមានន័យថាការចាប់ខ្លួនប្រជាជនទ្រង់ទ្រាយធំទាំងអស់ត្រូវតែសម្រេចដោយយាយ ចែម ជាដំបូងសិន"]។

[92] សូមមើលជាឧទាហរណ៍, ឯកសារ **D219/120** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុទ្ធ ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១២ [សក្ខីកម្មរបស់អតីតលេខាស្រុកកំពង់សៀមៈ ខ្ញុំផ្តល់សិទ្ធិដល់អនុប្រធានរបស់ខ្ញុំ... ឲ្យចាប់ខ្លួនមនុស្ស"], ឆ ២៩ ["បន្ទាប់ពីខ្ញុំបានទទួលព័ត៌មាន ឬរបាយការណ៍ពីឃុំ ខ្ញុំនឹងសម្រេចមួយករណីម្តងៗ... ថានរណាដែលត្រូវបញ្ជូនទៅទួលបេង"]។ ***CF2*-D40/5** កំណត់ហេតុស្តាប់ចម្លើយ ព្រំ ព្រឿង ដោយ ក.ស.ច.ស នៅ ត្រង់ ឯកសារភាសាអង់គ្លេស 00165239-40 [សក្ខីកម្មរបស់ប្រធានសន្តិសុខស្រុកខ្សាច់កណ្តាល ដែលថាបញ្ជាឲ្យចាប់ខ្លួនអ្នកទោស គឺមកពីលេខាស្រុក]។ ឯកសារ **D219/28** កំណត់ហេតុស្តាប់ចម្លើយ ម៉ា ស៊ឹម ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៥៣, ៦៤ [មេស្រុក "ទទួលខុសត្រូវលើកងទ័ពស្រុក និងសន្តិសុខ" ហើយទទួលខុសត្រូវលើការបញ្ជាឲ្យចាប់ខ្លួន]។ ឯកសារ **D117/36.1.1** កំណត់ហេតុស្តាប់ចម្លើយ គឹម សុខ ដោយ ក.ស.ច.ស នៅ ត្រង់ឯកសារភាសាអង់គ្លេស 00231666, 00231670 [សក្ខីកម្មរបស់ប្រធានគុកដំរីស្រុតថា មេដឹកនាំស្រុកមានអំណាចពាក់ព័ន្ធមន្ទីរសន្តិសុខ ប៉ុន្តែចាំបាច់ត្រូវមានបញ្ជាពីថ្នាក់តំបន់ក្នុងការសម្លាប់]។ ឯកសារ ***CF2*-D166/182** កំណត់ហេតុស្តាប់ចម្លើយ មុល អែម ដោយ ក.ស.ច.ស នៅត្រង់ឯកសារភាសាអង់គ្លេស 00358614 [សក្ខីកម្មរបស់អនុប្រធានមន្ទីរសន្តិសុខដំរីស្រុតថា សេចក្តីសម្រេចចាប់ខ្លួនធ្វើឡើងដោយគណៈស្រុក ផ្អែកលើរបាយការណ៍ពីឃុំ]។ ឯកសារ ***CF2*-D125/184** កំណត់ហេតុស្តាប់ចម្លើយ យន់ គីម ដោយ ក.ស.ច.ស នៅត្រង់ឯកសារភាសាអង់គ្លេស 00345191។ ឯកសារ **D219/5** កំណត់ហេតុស្តាប់ចម្លើយ ជាម ញ៉ ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៨៩ ["គណៈស្រុកមានអំណាចក្នុងការចាប់ខ្លួន និងសម្លាប់មនុស្ស"]។ ឯកសារ **D219/40** កំណត់ហេតុស្តាប់ចម្លើយ ផាន់ ឆេន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៣៣ដល់៣៥។ ឯកសារ **D6.1.991** កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សឿម ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១៣ដល់១៤។ Cf: **D6.1.688** កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធឿន ដោយ ក.ស.ច.ស នៅត្រង់ឯកសារភាសាអង់គ្លេស 00384401 ["ថ្នាក់ស្រុកមានអំណាចសម្លាប់

រួមមានកំណត់ត្រាដែលនៅសល់ពីស្រុកត្រាំកក់ ដែលបង្ហាញថាមេស្រុកមានសិទ្ធិអំណាច ក្នុងការបង្គាប់ឱ្យមានការឃាត់ខ្លួន[93] ប៉ុន្តែជាទូទៅតម្រូវឱ្យមានការអនុម័តពីតំបន់ ក្នុងការសម្លាប់[94]។

21. បើទោះបីជា អ៊ឹម ចែម ក្នុងតួនាទីរបស់គាត់ជាសមាជិកតំបន់ មិនមានសិទ្ធិអំណាចតាមផ្លូវច្បាប់ ក្នុងការបញ្ជាឱ្យសម្លាប់ក៏ដោយ[95] ប៉ុន្តែសេចក្តីសម្រេចរបស់គាត់ក្នុងនាមជាលេខាស្រុក អំពីនរណាដែលត្រូវចាប់ខ្លួន ហើយត្រូវបញ្ជូនទៅមន្ទីរសន្តិសុខ គឺមានផលវិបាកយ៉ាងខ្លាំងក្លា[96]។ ជនរងគ្រោះដែលត្រូវបានចាប់ខ្លួន ភ្លាមៗនោះត្រូវទទួលរងការឃុំខ្លួនដោយខុសច្បាប់ នៅក្នុងស្ថានភាពដ៏អាក្រក់ ហើយត្រូវទទួលរងការសួរចម្លើយ ដែលជាទូទៅតែងតែមានការធ្វើទារុណកម្ម។ តថភាពយ៉ាងជាក់

---

មនុស្ស"]។ ឯកសារ **D118/274** កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៨៦ដល់៨៧។ ឯកសារ **D6.1.122** កំណត់ហេតុស្តាប់ចម្លើយ ប៉េ ជុយ ជីបសែ ដោយ ក.ស.ច.ស នៅត្រង់ឯកសារភាសាអង់គ្លេស 00225212-13 [សក្ខីកម្មរបស់កម្មាភិបាលមន្ទីរសន្តិសុខពង្រះ៖ "ទាល់តែមានបញ្ជាពីស្រុក ទើបមានការសួរចម្លើយ ដោះលែង ឬសម្លាប់"]។ *(ឯកសារដែលមាននៅក្នុងសំណុំរឿង ០០២បច្ចុប្បន្ន ត្រូវបានកំណត់ជាមួយ 'CF2' ហើយត្រូវបានស្នើថាឯកសារបែបនេះទាំងអស់ត្រូវដាក់ចូលទៅក្នុងសំណុំរឿង ០០៤)*។

[93] *សូមមើលជាឧទាហរណ៍*, D6.1.283 នៅត្រង់ឯកសារភាសាអង់គ្លេស 00322160 [បញ្ជាពីគិតជាលេខាស្រុកត្រាំកក់ "ឱ្យចាប់ខ្លួនប្រាក់ ណាន និងនាំវាយកទៅកន្លែងរបស់យើង"]។ ឯកសារ **D6.1.299** នៅត្រង់ឯកសារភាសាអង់គ្លេស 00322177 [លិខិតមកពីលេខាស្រុកឈ្មោះគិត អនុញ្ញាតឱ្យចាប់ខ្លួន]។ឯកសារ **D6.1.295** នៅត្រង់ឯកសារភាសាអង់គ្លេស 00388587 [លិខិតមកពីមេស្រុកឈ្មោះនាង អ៊ូច ហៅតា សាន៖ "ខ្ញុំបានសម្រេចថាមនុស្សទាំងបួននាក់នេះ គួរត្រូវបានចាប់ខ្លួន"]។

[94] ឯកសារ **D6.1.1200** នៅត្រង់ ឯកសារភាសាអង់គ្លេស 00276593-94 [របាយការណ៍ពីចម្លើយសារភាពរបស់អ្នកទោសដែលត្រូវបានបញ្ជូនដោយមេគុកក្រាំងតាចាន់ រួមមានការណែនាំសរសេរដោយដៃឱ្យ "កម្ទេច" មកពីលេខាតំបន់១៣ឈ្មោះប្រាក់]។ ឯកសារD118/242 កំណត់ហេតុស្តាប់ចម្លើយ ខឹម បឿន ដោយ ក.ស.ច.ស នៅត្រង់ A259. សូមមើលផងដែរ ឯកសារ **D219/119.1.5** កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដារ ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៥៥ [លេខាតំបន់១១មាន "សិទ្ធិអំណាចចេញបញ្ជាសម្លាប់មនុស្ស"]។ ឯកសារ **D6.1.679** កំណត់ហេតុស្តាប់ចម្លើយ សេង សឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៤៤ [សក្ខីកម្មរបស់មេស្រុកស្អាង៖ "កម្មាភិបាលមកពីតំបន់បានអញ្ជើញគណៈស្រុក ឱ្យចូលរួមប្រជុំ ហើយក្នុងពេលប្រជុំមានការសម្រេចថានរណាដែលត្រូវសម្លាប់ និងនរណាដែលមិនត្រូវសម្លាប់"]។

[95] យោង ឯកសារ **D219/347** កំណត់ហេតុស្តាប់ចម្លើយ ឈឹម ផាន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៩ដល់១១ [បានពិភាក្សាពីការចេញបញ្ជាសម្លាប់ ដោយគណៈស្រុកនៅព្រះនេត្រព្រះ]។

[96] សូមមើល Stephen Heder, *Reassessing the Role of Senior Leaders and Local Officials in Democratic Kampuchea Crimes: Cambodian Accountability in Comparative Perspective*, នៅត្រង់ទំព័រ ១២ ដល់១៦ [រៀបរាប់ពីសារសំខាន់នៃការវិនិច្ឆ័យដោយមេស្រុកបក្សកុម្មុយនីស្តកម្ពុជា ហើយបានកត់សម្គាល់ថាបក្សចាត់ទុកពួកគេថា "សំខាន់ទីពីរបន្ទាប់ពីសមាជិកគណៈមជ្ឈិម ដោយសារតែពួកគេមានតួនាទីសំខាន់មធ្យម ចន្លោះមេដឹកនាំមជ្ឈិម និងស្ថានភាពនៅមូលដ្ឋាន"]។

ច្បាស់នេះគឺថា ភាគច្រើនលើសលប់នៃអ្នកដែលត្រូវបានបញ្ជូន ទៅមន្ទីរសន្តិសុខស្រុក នឹងស្លាប់ដោយសារជំងឺ ភាពអត់ឃ្លាន ការធ្វើបាប ឬការសម្លាប់[97]។

22. អ៊ឹម ចែម ទទួលស្គាល់ថា កម្ពុជាប្រជាធិបតេយ្យគឺជារបប "ផ្តាច់ការ" ដែលដំណើរការដោយគ្មានច្បាប់ ហើយអ្នកដែលត្រូវបានគេចោទប្រកាន់ថាជាខ្មាំង ត្រូវប្រឈមនឹងផលវិបាកធ្ងន់ធ្ងរ ហើយប្រហែលជាត្រូវសម្លាប់[98]។ នៅក្នុងកិច្ចប្រជុំថ្នាក់ស្រុក គាត់បានព្រមានប្រជាជនថាពួកគេចាំបាច់ "មិនត្រូវប្រឆាំងអង្គការឡើយ បើមិនដូច្នេះទេ អង្គការនឹងយកទៅរៀនសូត្រ"[99]។ គាត់យល់ច្បាស់អំពីផលវិបាកនៃការសម្រេច ចាប់ខ្លួនខ្មាំងដែលត្រូវបានចោទប្រកាន់។ ដោយនិយាយផ្ទាល់មាត់គាត់ថា "ប្រសិនបើចោទប្រកាន់ខុស ហើយប្រសិនបើខ្ញុំជាមេដឹកនាំយល់ស្របតាមនេះ ជីវិតរបស់មនុស្សទាំងនោះនឹងចប់"[100]។ អតីតនីរសារបស់អ៊ឹម ចែម បានទទួលស្គាល់ថា គាត់ទទួលខុសត្រូវលើការស្លាប់ នៅក្នុងស្រុករបស់គាត់ "ព្រោះគាត់ទទួលខុសត្រូវលើការងារទាំងអស់ និងលើអ្នកទោសទាំងអស់នៅព្រះនេត្រព្រះ"[101]។

---

[97] សូមមើលជាឧទាហរណ៍, ឯកសារ **D6.1.709** កំណត់ហេតុស្តាប់ចម្លើយ ស្រី ថន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៥៣ [សេចក្តីកម្មរបស់ឆ្មាំគុកក្រាំងតាចាន់ថា "អ្នកទោស៩៩%ត្រូវបានកម្ទេច"]។ ឯកសារ **D219/57** កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៦២ [សេចក្តីកម្មរបស់កម្មាភិបាលមន្ទីរសន្តិសុខភូមិវាលនិយាយថា មានតែអ្នកទោសតិចតួចប៉ុណ្ណោះដែលនៅរស់រានមានជីវិត]។

[98] ឯកសារD1.3.12.1 កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២00៧, នៅត្រង់ ឯកសារភាសាអង់គ្លេស 00217530-31 ["ប្រជាជនបានចោទប្រកាន់គ្នាទៅវិញទៅមក ដោយនិយាយថាអ្នកនេះ ឬអ្នកនោះជាខ្មាំង ដែលបណ្តាលឲ្យមានផលប៉ះពាល់ខ្លាំងដល់ការរស់នៅរបស់ពួកគេ... របបផ្តាច់ការដែលការចោទប្រកាន់មានន័យថាសម្លាប់ភ្លាមៗ"], 00217544 ["មិនមែនទាំងអស់សុទ្ធតែត្រូវសម្លាប់ក្រោយពេលចាប់ខ្លួនឡើយ។ មិនមាននរណាដឹងថាពួកគេត្រូវបានយកទៅណា និងសម្លាប់ចោលនៅទីណាទេ... ប៉ុន្តែមនុស្សបានបាត់បន្តបន្ទាប់"]។ ឯកសារ **D123/1/5.1b** បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២0 ខែ មិថុនា ឆ្នាំ ២00៨ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951819.

[99] ឯកសារ D119/30 កំណត់ហេតុស្តាប់ចម្លើយ ភួន ស៊ុនទី ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៧។

[100] ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២0 ខែ មិថុនា ឆ្នាំ ២00៨ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951819។

[101] ឯកសារ **D219/397** កំណត់ហេតុស្តាប់ចម្លើយ ប៊ិន សុខ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤២ [បន្ថែមថា "ខ្ញុំគិតថា យាយ ចែម មិនមែនជាមនុស្សកាចសាហាវទេ ប៉ុន្តែគាត់គឺជាអ្នកសម្រេច"].

23. ក្រោយពេល អ៊ឹម ចែម និងកម្មាភិបាលនិរតីមកដល់ស្រុកព្រះនេត្រព្រះ ពួកគេបានបង្កើតមន្ទីរសន្តិសុខ នៅការដ្ឋានវាយថ្មភ្នំត្រយោង[102]។ ដំបូងឡើយមានកន្លែងឃុំខ្លួនធំៗចំនួនពីរ និងកន្លែងឃុំខ្លួនតូចៗបីបួន ប៉ុន្តែក្រោយមកកន្លែងបន្ថែមត្រូវបានសង់ឡើង ដើម្បីពង្រីកគុក[103]។ ឆ្មាំគុក២០ ទៅ៣០នាក់

[102] ឯកសារ **D119/65** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១៤៣ ដល់១៤៦ [សក្ខីកម្មរបស់មេគុកភ្នំត្រយោងថា មន្ទីរត្រូវបានបង្កើតឡើង "ក្រោយពេលមនុស្សភូមិភាគនិរតីមកដល់"]។ ឯកសារ **D119/64.1** កិច្ចសម្ភាសន៍ជាមួយ ទុំ សឿន ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ ឯកសារភាសាអង់គ្លេស 00951706 ["ស៖ អ្នកណាបង្កើតមណ្ឌលនោះ? ឆ៖ យាយ ចែម"]។ ឯកសារ**D106/8** កំណត់ហេតុស្តាប់ចម្លើយ ធីប សំផាត ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣៩។ ឯកសារ **D219/318** កំណត់ហេតុស្តាប់ចម្លើយ ដាន តាំ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥៨។ ឯកសារ **D219/23** កំណត់ហេតុស្តាប់ចម្លើយ ពុំ កូ ដោយក.ស.ច.ស នៅត្រង់ចម្លើយ ២៨។ ឯកសារ D106/7 កំណត់ហេតុស្តាប់ចម្លើយ ស៊ុម សល ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣៣។ ឯកសារ **D119/20** កំណត់ហេតុស្តាប់ចម្លើយ លី ស៊ីញ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៥។

[103] ឯកសារ D119/30 កំណត់ហេតុស្តាប់ចម្លើយ ភួន ស៊ុនទី ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣៣។ ឯកសារD106/8 កំណត់ហេតុស្តាប់ចម្លើយ ធីប សំផាត ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣៦ [ដោយសារតែ "ចំនួនអ្នកទោសមានច្រើន" ទើបមន្ទីរសន្តិសុខចាំបាច់ត្រូវតែពង្រីកទៅខាងកើត]។ ឯកសារ **D119/19** កំណត់ហេតុស្តាប់ចម្លើយ ផន មុន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៩ ["មានផ្ទះ១០ខ្នងដែលមានមនុស្សជាច្រើនត្រូវបានឃុំឃាំងនៅក្នុងនោះ"]។ ឯកសារ D219/153 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សឿន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៥ ["រោងបួនទៅ១០មានដំបូលស័ង្កសី"]។ ឯកសារ **D119/65** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១៥១ [ផ្ទះថ្មី១០ខ្នងត្រូវបានសង់ឡើងនៅទីនោះបន្ទាប់ពីគាត់មកដល់]។ ឯកសារ **D119/64.1** កិច្ចសម្ភាសន៍ជាមួយ ទុំ សឿន ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ ឯកសារភាសាអង់គ្លេស 00951709។ ឯកសារ **D219/102** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥០ ដល់៥២ [បញ្ជាក់ថាគាត់បានសង់រោងបាយដែល "មានបណ្តោយ៦០ម៉ែត្រ និងទទឹង៣០ម៉ែត្រ"].

ធ្វើការនៅមន្ទីរសន្តិសុខ[104] នៅលើផ្ទៃដីពីរហិកតា[105]។ នៅពេលកងទ័ពវៀតណាមចូលមកដល់ គឺនៅសល់ផែនការសង់មន្ទីរសន្តិសុខធំជាងមុនទៅទៀត[106]។

24. ទោះបីជាការស៊ើបអង្កេតរបស់ ក.ស.ច.ស មិនបានគាំទ្រពេញលេញដល់ការប៉ាន់ស្មានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលថា មានមនុស្សស្លាប់ ៤0000នាក់ នៅភ្នំត្រយោង[107] តែមានការកំណត់ថា ប្រជាជនរាប់ពាន់នាក់បានស្លាប់នៅ មន្ទីរសន្តិសុខនេះ នៅពេលដែលអ៊ឹម ចែមនៅគ្រប់គ្រង។ ទោះបីជាចំនួនអ្នកទោសមានការប្រែប្រួល តែជាទូទៅមានយ៉ាងហោចណាស់មនុស្ស៣00នាក់ ត្រូវបានឃុំខ្លួននៅកន្លែងនោះ ហើយពេលខ្លះមានអ្នកជាប់ឃុំដល់ទៅជាង ១000នាក់[108]។ ប្រធានសេដ្ឋ

[104] ឯកសារ **D119/49** កំណត់ហេតុស្តាប់ចម្លើយ ធីប សម្បត្តិ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥៤ ["ឆ្នាំប្រហែល ៣០នាក់"]។ ឯកសារ D106/7 កំណត់ហេតុស្តាប់ចម្លើយ ស៊ុម សល ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ១១ [សក្ខីកម្មរបស់អតីឆ្មាំភ្នំត្រយោងថា មានឆ្មាំ៣០នាក់]។ ឯកសារ **D219/318** កំណត់ហេតុស្តាប់ចម្លើយ ដន តំ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៦២ ["មានឆ្មាំយ៉ាងច្រើននៅភ្នំត្រយោង" គឺច្រើនជាងគុកតំបន់ទៀត]។ ឯកសារ **D219/94** កំណត់ហេតុស្តាប់ចម្លើយ គីម យ៉េត ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៧៧ ["ឆ្មាំប្រហែល២០នាក់"]។ ឯកសារ **D119/159** កំណត់ហេតុស្តាប់ចម្លើយ ឡេង វឿន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤៩ (ដូចគ្នា)។

[105] ឯកសារ **D119/64.1** កិច្ចសម្ភាសន៍ជាមួយ ទុំ សឿន ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ ឯកសារភាសាអង់គ្លេស 00951705.

[106] ឯកសារ **D106/5** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយក.ស.ច.ស នៅត្រង់ចម្លើយ ២១, ២៤។ ឯកសារ **D119/65** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ២០៨ [រៀបរាប់ពីផែនការសង់មន្ទីរសន្តិសុខថ្មី នៅភ្នំស្រមោច ដែលមានចម្ងាយ៥០០ម៉ែត្រពីភ្នំត្រយោង].

[107] ឯកសារ **D1.3.10.10** របាយការណ៍ផែនទីបន្ទាយមានជ័យ នៅត្រង់ឯកសារភាសាអង់គ្លេស 00218610។ ឯកសារ **D219/144** កំណត់ហេតុស្តាប់ចម្លើយ ភឿន ពុងរ៉ាស៊ី ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៤ ដល់១៥។

[108] ឯកសារ **D119/49** កំណត់ហេតុស្តាប់ចម្លើយ ធីប សម្បត្តិ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥៣។ ឯកសារ **D219/318** កំណត់ហេតុស្តាប់ចម្លើយ ដាន តាំ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥៥ ["ខ្ញុំឃើញមនុស្សរាប់ពាន់នាក់នៅទីនោះ"]។ ឯកសារ**D219/149** កំណត់ហេតុស្តាប់ចម្លើយ ជុំ ជីម ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣៧ ["ខ្ញុំប៉ាន់ប្រមាណថាមានមនុស្សរាប់ពាន់នាក់ ព្រោះចំនួនប្រជាជនពីរសហករណ៍ក៏មិនស្មើចំនួនអ្នកទោស នៅភ្នំត្រយោងដែរ"]។ ឯកសារ D219/153 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សឿន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ២១ ["អ្នកទោសរាប់ពាន់នាក់"]។ ឯកសារ D119/30 កំណត់ហេតុស្តាប់ចម្លើយ ភួន ស៊ុនទី ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៤, ៣១ [រៀបរាប់ពីការប្រជុំមួយដែលចូលរួមដោយអ្នកទោស៣00នាក់ ហើយបានកត់សម្គាល់ជាទូទៅថា មាន"អ្នកទោសច្រើនពេក" មិនអាចរាប់អស់"]។ ឯកសារ **D119/159** កំណត់ហេតុស្តាប់ចម្លើយ ឡេង វឿន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤៩ ["អ្នកទោសប្រហែល ៥00នាក់"]។ ឯកសារ **D106/6** កំណត់ហេតុស្តាប់ចម្លើយ គីម យ៉េត ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣១ [បញ្ជាក់ថាជាទូទៅគឺមានអ្នកទោស ២00 ទៅ៣00នាក់]។ ឯកសារ **D119/65** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ

កិច្ចចល័តតំបន់៥ ដែលទទួលខុសត្រូវលើការបញ្ជូនស្បៀងទៅភ្នំត្រយ៉ូង បានផ្តល់សក្ខីកម្មថា គាត់ត្រូវបានស្នើឱ្យផ្គត់ផ្គង់អង្ករឱ្យបានគ្រប់ សម្រាប់មនុស្ស៦០០នាក់[109]។ សាក្សីបានរៀបរាប់ពីការសម្លាប់ទ្រង់ទ្រាយធំ ចំពោះអ្នកទោស ដែលពេលខ្លះច្រើនរហូតដល់៩០នាក់ ក្នុងមួយពេល[110] ហើយបានបញ្ជាក់ថាអ្នកទោសដទៃទៀតជាច្រើននាក់ បានស្លាប់ដោយសារធ្វើការងារធ្ងន់ និងអត់ឃ្លាន[111]។

---

១៥៩ ដល់១៦១ [សក្ខីកម្មរបស់អតីតមេគុកថា មានមនុស្ស៣០០ ទៅ៤០០នាក់នៅទីនោះ]។ ឯកសារ **D101/1.2** កំណត់ហេតុស្តាប់ចម្លើយ តោ ពិនថាង ជាមួយ ក.ស.ច.ស នៅត្រង់ឯកសារភាសាអង់គ្លេស 00751068 [អ្នកទោស ៥០ទៅ៦០នាក់ជាប់ខ្នោះជើងនៅក្នុងអគារមួយតែឯង]។ ឯកសារ **D119/155** កំណត់ហេតុស្តាប់ចម្លើយ ឡាច ឈាងឡុង ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥៦ដល់៦២ [អ្នកទោស៧០នាក់ "ដេកជើងទល់គ្នា" នៅក្នុងអគារមួយ]. សូមមើលផងដែរ ឯកសារ **D219/318** កំណត់ហេតុស្តាប់ចម្លើយ ដន ត៌ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៦២ ដល់៦៣ [ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានឃុំខ្លួន ទាំងនៅភ្នំត្រយោង និងនៅមន្ទីរសន្តិសុខតំបន់នៅចំការគ បានបញ្ជាក់ថាភ្នំត្រយោងគឺ "សំខាន់ជាងនិងធំជាង" ដោយសារតែមានអ្នកទោសច្រើនជាង ហើយរបបអាហារនិងស្ថានភាពរស់នៅគឺអាក្រក់ជាងខ្លាំងនៅភ្នំត្រយោង].

[109] ឯកសារ **D119/33** កំណត់ហេតុស្តាប់ចម្លើយ ឈិត យក់ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២២។

[110] ឯកសារ **D119/49** កំណត់ហេតុស្តាប់ចម្លើយ ធីប សម្បត្តិ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៦០ ដល់៦៤ [បានឃើញការសម្លាប់អ្នកទោស៩០នាក់]។ ឯកសារ**D106/8** កំណត់ហេតុស្តាប់ចម្លើយ ធីប សំផាត ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៧ ដល់៣១។ ឯកសារ D119/30 កំណត់ហេតុស្តាប់ចម្លើយ ភួន ស៊ុនទី ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ២០ដល់២១, ៣12 [បានឃើញការសម្លាប់មនុស្ស៧នាក់ ហើយឆ្មាំបានប្រាប់ពីការសម្លាប់ជាទូទៅ "យ៉ាងហោចណាស់អ្នកទោស ៣០ ទៅ៥០នាក់"]។ ឯកសារ **D119/19** កំណត់ហេតុស្តាប់ចម្លើយ ផន មុន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣៤។ ឯកសារ **D106/6** កំណត់ហេតុស្តាប់ចម្លើយ គីម យ៉េត ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៦ ដល់១៧, ២៦, ៣១ដល់៣២ ។ ឯកសារ **D219/94** កំណត់ហេតុស្តាប់ចម្លើយ គីម យ៉េត ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥៩ ដល់៦៧ [បានឮបញ្ជាឱ្យកប់សាកសព ៣០ ទៅ៤០សាកសព ក្រោយពេលសម្លាប់រួម], ឆ ៨២ដល់៨៣។ ឯកសារ**D219/149** កំណត់ហេតុស្តាប់ចម្លើយ ជុំ ធីម ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣១, ៣៨ [អ្នកទោស ១៥ ទៅ ២០នាក់ត្រូវបានសម្លាប់រៀងរាល់២ទៅ៣ថ្ងៃម្តង]។ ឯកសារ **D219/211** កំណត់ហេតុស្តាប់ចម្លើយ អឿន ចាន់រី ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៣, ១៨។ ឯកសារ D219/153 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សឿន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣២។ ឯកសារ D1.3.11.20 កិច្ចសម្ភាសន៍ជាមួយ គឹម នៅសួស [អ្នកទោសបទល្មើសធ្ងន់ធ្ងរដែលនៅសល់ ត្រូវបានសម្លាប់នៅថ្ងៃចុងក្រោយនៃរបប]។ នៅក្នុងការស្តាប់ចម្លើយលើកទីមួយរបស់គាត់ជាមួយ ក.ស.ច.ស អតីតប្រធានភ្នំត្រយោងបានអះអាងថា មានមនុស្សតែ៣០០ទៅ៤០០នាក់ប៉ុណ្ណោះដែលស្លាប់នៅគុក (ឯកសារ **D106/5** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយក.ស.ច.ស នៅត្រង់ចម្លើយ ២៤)។ នៅក្នុងការស្តាប់ចម្លើយលើកទីពីរ គាត់បានបដិសេធថាមិនបានឆ្លើយចម្លើយលើកមុនឡើយ ហើយបានអះអាងថាមិនមានការសម្លាប់ ឬការស្លាប់មនុស្សទាល់តែសោះ (ឯកសារ **D119/65** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១៩១ ដល់១៩៣, ១៩៦, ២១៧)។

[111] ឯកសារ D106/7 កំណត់ហេតុស្តាប់ចម្លើយ ស៊ុម សល ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៦, ៣១។ ឯកសារ D119/49 កំណត់ហេតុស្តាប់ចម្លើយ ធីប សម្បត្តិ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥៧។ ឯកសារ D119/159 កំណត់ហេតុស្តាប់ចម្លើយ ឡេង វឿន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥០ ["មានអ្នកទោសពីរទៅបីនាក់ស្លាប់រាល់ថ្ងៃដោយអត់

ជនរងគ្រោះដែលត្រូវបានស្លាប់នៅទីនោះមានទាំងកុមារផងដែរ[112]។ អ្នកជាប់ឃុំម្នាក់ដែលនៅរស់រានមានជីវិតជឿថា "មនុស្សរាប់ម៉ឺននាក់" ស្លាប់នៅទីនោះ[113] ហើយអតីតឆ្មាំគុកម្នាក់បានប៉ាន់ប្រមាណថា ចំនួនអ្នកស្លាប់គឺពី ៥ពាន់នាក់ ទៅ១ម៉ឺននាក់[114]។ របាយការណ៍មួយដែលរៀបចំឡើងដោយរដ្ឋាភិបាល សាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងឆ្នាំ ១៩៨៤ បានកំណត់ថាមនុស្ស ២០ ០០០ នាក់ ត្រូវបានសម្លាប់នៅភ្នំត្រយោង[115]។

25. ការទទួលខុសត្រូវរបស់អ៊ឹម ចែម ចំពោះមន្ទីរសន្តិសុខភ្នំត្រយោង ត្រូវបានកំណត់យ៉ាងច្បាស់លាស់។ អតីតមេគុកនោះឈ្មោះ ទុំ សឿន ជាកម្មាភិបាលនិរតីមកពីស្រុកត្រាំកក់ ដែលមកភូមិភាគពាយ័ព្យជាមួយអ៊ឹម ចែម។ គាត់ត្រូវបានអ្នកទោសហៅថាយមរាជ[116]។ ទុំ សឿនបញ្ជាក់ថាគឺអ៊ឹម ចែម ជាអ្នកចាត់តាំងគាត់ឲ្យរៀបចំមន្ទីរ ហើយថាគាត់គឺជា "មេដឹកនាំកំពូល" នៅទីនោះ ហើយជាអ្នកដែលគាត់

---

អាហារ"]។ ឯកសារ **D119/130** កំណត់ហេតុស្តាប់ចម្លើយ អោម ហឿន ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៤៧ ["ភាគច្រើនស្លាប់ដោយអត់អាហារ"]។ ឯកសារ **D219/92** កំណត់ហេតុស្តាប់ចម្លើយ ភួន ស៊ុនទី ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៥០។ ឯកសារ **D219/318** កំណត់ហេតុស្តាប់ចម្លើយ ដាន តាំ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥៥ ["មិនមានអាហារហូបនោះទេ មានតែស្លឹកឈើ"], ឆ ៦៣ដល់៦៤។ ឯកសារ **D219/127** កំណត់ហេតុស្តាប់ចម្លើយ ប្រាំង សាល ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៥៤ [អតីតឆ្មាំគុកបានប៉ាន់ប្រមាណថាមានមនុស្ស ៥០០០ ទៅ១០០០០ នាក់ស្លាប់នៅទីនោះ ដែលភាគច្រើនគឺ "ស្លាប់ដោយសារជំងឺ ដោយសារខ្វះអាហារ និងអាចត្រូវកងទ័ពសម្លាប់""]។ ឯកសារ D219/153 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សឿន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ២១ [មនុស្សរាប់ពាន់នាក់ស្លាប់ដោយសារអត់អាហារ]។ ឯកសារ **D219/141** កំណត់ហេតុស្តាប់ចម្លើយ យក់ នាម ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៧ ដល់១៦ [ក្រោយពេលរៀតណាមមកដល់ សាក្សីបានឃើញសាកសពអ្នកទោស នៅជាប់ខ្នោះជើងក្នុងគុក]។ ឯកសារ D106/4 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ខន ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ២៤។

[112] ឯកសារ **D119/19** កំណត់ហេតុស្តាប់ចម្លើយ ផន មុន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣៤ [បញ្ជាឲ្យកប់សាកសពដែលមានសាកសពមួយចំនួនជាសាកសពក្មេង]។

[113] ឯកសារ D119/30 កំណត់ហេតុស្តាប់ចម្លើយ ភួន ស៊ុនទី ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣១។ ឯកសារ D219/92 កំណត់ហេតុស្តាប់ចម្លើយ ភួន ស៊ុនទី ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៤៨ ដល់៥០ [បានពន្យល់ថាការប៉ាន់ប្រមាណគឺផ្អែកលើចម្លើយរបស់ឆ្មាំគុកដែលថា មនុស្ស៣០ទៅ៥០នាក់ត្រូវបានសម្លាប់រៀងរាល់យប់]។

[114] ឯកសារ **D219/127** កំណត់ហេតុស្តាប់ចម្លើយ ប្រាំង សាល ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៥៤។

[115] ឯកសារ **D119/50.2** របាយការណ៍ពីមន្ទីរឃោសនាការណ៍ស្រុកព្រះនេត្រព្រះ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៨៤, នៅត្រង់ឯកសារភាសាអង់គ្លេស 00938421។

[116] ឯកសារ **D106/6** កំណត់ហេតុស្តាប់ចម្លើយ គីម យ៉េត ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤១។

ត្រូវរាយការណ៍ជូន[117]។ គាត់បញ្ជាក់ថា អ៊ឹម ចែម ដោយប្រើប្រាស់សិទ្ធិអំណាចរបស់គាត់ ក្នុងនាមជាមេស្រុក បានសម្រេចថានរណាខ្លះដែលត្រូវចាប់ខ្លួន ហើយត្រូវបញ្ជូនទៅមន្ទីរសន្តិសុខ[118]។

26. ទោះបីជាពីដំបូង អ៊ឹម ចែម បានបដិសេធមិនដឹងអ្វីទាំងអស់អំពីគុកភ្នំត្រយោង ដែលស្ថិតនៅត្រឹមទីតាំងក៏ដោយ[119] តែនៅពេលក្រោយមកគាត់បានសារភាពថា ផ្ទះរបស់គាត់មានចម្ងាយត្រឹម២០០ម៉ែត្រពីកន្លែងនោះ[120]។ ពេលខ្លះឈ្លបស្រុកនាំយកអ្នកត្រូវបានចាប់ខ្លួន ទៅផ្ទះរបស់អ៊ឹម ចែម ដែលនៅទីនោះពួកគេបានទទួលការបញ្ជាពីអ៊ឹម ចែម ថាត្រូវធ្វើអ្វីចំពោះអ្នកជាប់ឃុំនោះ[121]។ ក្នុងពេលចាប់ខ្លួន

---

[117] ឯកសារ **D106/5** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយក.ស.ច.ស នៅត្រង់ចម្លើយt A28។ ឯកសារ **D119/65** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១៤៨ [ត្រូវចែមចាត់តាំងឲ្យត្រួតពិនិត្យមើលទីតាំង], ឆ ១៥៨ [ចែម "ប្រាប់ខ្ញុំឲ្យរៀបចំផ្នែកអប់រំ"], ឆ ១៧៥ ["យាយចែមចាត់តាំងខ្ញុំឲ្យទទួលខុសត្រូវលើកន្លែងនោះ។ គាត់បញ្ជាខ្ញុំឲ្យជួយរៀបចំទីកន្លែង នៅពេលដែលគេបញ្ជូនមនុស្សជាច្រើននាក់ទៅទីនោះ"], ឆ ១៧៨ [អ្នកគ្រប់គ្រងមុនគឺជានិរសាររបស់ចែម], ឆ ១៨៣ [និរសាររបស់ចែមមកទីកន្លែងនេះរាល់ពីរឬបីថ្ងៃម្តង]។ សូមមើលផងដែរ ឯកសារ D119/110 កំណត់ហេតុស្តាប់ចម្លើយ ជុំ កន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៨៩ [បញ្ជាក់ថាភ្នំត្រយោងគឺជាមន្ទីរសន្តិសុខតំបន់ ប៉ុន្តែថា "យាយចែមមានសិទ្ធិអំណាចគ្រប់គ្រងមន្ទីរសន្តិសុខនោះ"]។ ឯកសារ **D219/23** កំណត់ហេតុស្តាប់ចម្លើយ ពុំ កូ ដោយក.ស.ច.ស នៅត្រង់ចម្លើយ ១១២ [សក្ខីកម្មរបស់អតីតសមាជិកគណៈស្រុកថា ចែមគ្រប់គ្រងលើការដ្ឋានវាយថ្មភ្នំត្រយោង]។ ឯកសារ **D219/397** កំណត់ហេតុស្តាប់ចម្លើយ ប៊ិន សុខ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤២ [សក្ខីកម្មរបស់អតីតនិរសាចែមថា គាត់ទទួលខុសត្រូវលើ "អ្នកទោសទាំងអស់នៅព្រះនេត្រព្រះ"]។

[118] ឯកសារ **D119/65** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ189, A222-A223។ ឯកសារ **D119/64.1** កិច្ចសម្ភាសន៍ជាមួយ ទុំ សឿន ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ ឯកសារភាសាអង់គ្លេស 00951706។

[119] D123/1/5.1c បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951858-59។

[120] D123/1/5.1c បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951859. សូមមើលផងដែរ ឯកសារ D119/94 កំណត់ហេតុស្តាប់ចម្លើយ ប៊ូ ម៉ៅ ដោយ ក.ស.ច .ស នៅត្រង់ចម្លើយ ៣២ [សាក្សីបានរៀបរាប់ពីការដែលគាត់ជួប អ៊ឹម ចែមនៅ ផ្ទះរបស់អ៊ឹម ចែមនៅភ្នំលាភ ហើយត្រូវបានអមដំណើរដោយឈ្លបទៅមន្ទីរសន្តិសុខដែលមាន "អ្នកទោសជាច្រើននាក់" ស្ថិតនៅចម្ងាយ១០០ម៉ែត្រពីផ្ទះរបស់ចែម]។ ឯកសារ D219/151 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ដែង ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៣ [បញ្ជាក់ថាមានផ្ទះរបស់យោធាមួយនៅទល់មុខផ្ទះចែម ហើយមន្ទីរសន្តិសុខនៅពីក្រោយទីនោះតែម្តង]។

[121] ឯកសារ **D119/94** កំណត់ហេតុស្តាប់ចម្លើយ ប៊ូ ម៉ៅ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤៦ ដល់៤៧។ ឯកសារ **D119/121** កំណត់ហេតុស្តាប់ចម្លើយ កោ ឡែន ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៣៥ដល់៤៤។ ឯកសារ **D119/99 Pech Ruos** កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ រស់ ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៣៣ [រៀបរាប់ពីការចាប់ខ្លួនកម្មាភិបាលក្នុងមូលដ្ឋាន ហើយត្រូវបាននាំយកទៅផ្ទះអ៊ឹម ចែម និងបន្ទាប់មកត្រូវបានយកទៅសម្លាប់នៅ ចន្លោះភ្នំលាភ និងភ្នំត្រយោង]។ ឯកសារ **D101/1.2** កំណត់ហេតុស្តាប់ចម្លើយ តោ ពិនចាង ជាមួយ ក.ស.ច.ស នៅត្រង់ ឯកសារភាសាអង់គ្លេស 00751069។

ពេទ្យស្ត្រីម្នាក់ សាក្សីម្នាក់បានស្តាប់ឮអ៊ឹម ចែម បញ្ជាថា "បើវាពិបាក ឬជាជនក្បត់ សម្លាប់ចោល ហើយកម្ទេចទៅ"[122]។

27. សាក្សីជាច្រើននាក់បានរៀបរាប់ពីឯកសារដែល អ៊ឹម ចែមបានចេញ ដែលឯកសារទាំងនោះអាចជាការបញ្ជាឲ្យចាប់ខ្លួន ឬហៅមនុស្សទៅរៀនសូត្រ ដែលនៅទីនោះពួកគេត្រូវបានចាប់ខ្លួន[123]។ អ្នកដែលត្រូវបានចាប់ខ្លួន ហើយដែលអ៊ឹម ចែម បញ្ជូនទៅភ្នំត្រយោងរួមមាន៖ អ្នកដែលត្រូវបានចោទប្រកាន់ថាជាជនក្បត់ ដោយសារពួកគាត់រិះគន់ ឬតវ៉ាអំពីរបបអាហារ[124] អ្នកដែលត្រូវអ្នកទោសឆ្លើយដាក់ នៅពេលសួរចម្លើយ[125] អ្នកដែលស្រេកឃ្លានហើយបានលួចបេះផ្លែឈើ ដំឡូង ឬអំពៅហូប[126] អ្នកមកពីការដ្ឋានប្រឡាយដែលគេថា "ខ្ជិលឬខ្សោយ"[127] កម្មាភិបាលដែលត្រូវបានបោសម្អា

ឯកសារ **D119/75** កំណត់ហេតុស្តាប់ចម្លើយ ប៊ិន សុខ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៩ដល់២០, ឯកសារ **D219/397** កំណត់ហេតុស្តាប់ចម្លើយ ប៊ិន សុខ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ២០ដល់២៧ [សាក្សីដែលត្រូវបានកំណត់អត្តសញ្ញាណថាជានិរសាររបស់អ៊ឹម ចែម បានរៀបរាប់ពីការដែលគាត់ត្រូវចែមចាត់តាំង ឲ្យដឹកអ្នកទោស៧នាក់ពីគុកជប់ ទៅផ្ទះរបស់ចែម]។ ឯកសារ D119/154 កំណត់ហេតុស្តាប់ចម្លើយ អ៊ីវ ម៉ាភា ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៣៦ ដល់៣៩ [អ្នកត្រូវបានចាប់ខ្លួន ត្រូវគេដឹកទៅផ្ទះយាយ ចែម]។ ឯកសារ D219/151 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ដែង ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៣, ១០ដល់១១ [រៀបរាប់ថា "មន្ទីរឃុំឃាំងបណ្តោះអាសន្ន" នៅជាប់ផ្ទះចែម ហើយអ្នកត្រូវបានចាប់ខ្លួន ត្រូវគេយកទៅទីនោះ មុនបញ្ជូនទៅភ្នំត្រយោង ហើយនៅទីនោះគាត់ឃើញគេវាយអ្នកទោសនិងកៅអីឈើ]។

[122] ឯកសារ **D119/94** កំណត់ហេតុស្តាប់ចម្លើយ ប៊ូ ម៉ៅ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤៦ ដល់៤៧។

[123] ឯកសារ **D119/49** កំណត់ហេតុស្តាប់ចម្លើយ ធីប សម្បត្តិ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤២ ដល់៤៥។ ឯកសារ **D106/8** កំណត់ហេតុស្តាប់ចម្លើយ ធីប សំផាត ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៧ដល់១៣ ។ ឯកសារ **D119/30** កំណត់ហេតុស្តាប់ចម្លើយ ភួន ស៊ុនទី ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ១២ ដល់១៥, ១៨ដល់១៩ [អ៊ឹម ចែមផ្ញើរលិខិតទៅសាក្សីឲ្យ "មករៀនសូត្រ" ហើយនៅពេលគាត់មកដល់មន្ទីររបស់អ៊ឹម ចែម ក៏បញ្ជូនគាត់ទៅភ្នំត្រយោង ហើយនៅទីនោះគាត់ត្រូវបានគេចាប់ខ្លួន]។ ឯកសារ **D219/92** កំណត់ហេតុស្តាប់ចម្លើយ ភួន ស៊ុនទី ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៧ដល់១០, ១៤ ។ ឯកសារ **D219/95** កំណត់ហេតុស្តាប់ចម្លើយ ផុន មុន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៨ ដល់៣៥។

[124] ឯកសារ **D119/49** កំណត់ហេតុស្តាប់ចម្លើយ ធីប សម្បត្តិ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣៣ ដល់៣៦, ៤២ដល់៤៥។ ឯកសារ D1.3.11.20 កិច្ចសម្ភាសន៍ជាមួយ គឹម នៅសួស។

[125] ឯកសារ **D106/6** កំណត់ហេតុស្តាប់ចម្លើយ គីម យ៉េត ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៣, ២១ [មេគុកបានប្រាប់សាក្សីថា ក្រុមរបស់គាត់ត្រូវបានគេចាប់ ដោយសារតែពួកពេទ្យឆ្លើយដាក់]។

[126] ឯកសារ **D119/64.1** កិច្ចសម្ភាសន៍ជាមួយ ទុំ សឿន ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ ឯកសារភាសាអង់គ្លេស 00951709-10/14។ ឯកសារ **D106/6** កំណត់ហេតុស្តាប់ចម្លើយ គីម យ៉េត ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៨។ ឯកសារ **D219/230** កំណត់ហេតុស្តាប់ចម្លើយ លឿង វឿន ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ២។ ឯកសារ **D219/13** កំណត់ហេតុស្តាប់ចម្លើយ ឃុន សេរិន ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៤០ ដល់៤២។

ត និងក្រុមគ្រួសារពួកគេ[128] និងសាច់ញាតិរបស់ទាហានលន់ នល់ ដែលត្រូវបានបញ្ជូនទៅគុក បើទោះបីជា "ពួកគេមិនបានធ្វើកំហុសអ្វីក៏ដោយ"[129]។ មេកងមួយរូបបានចូលរួមក្នុងកិច្ចប្រជុំ ដែលមានកម្មាភិបាលស្រុក ៧០ ទៅ៨០នាក់ ដែលដឹកនាំដោយអ៊ឹម ចែម ក្រោយពេលគាត់មកដល់ ដែលនៅក្នុងកិច្ចប្រជុំនេះ គាត់បានប្រកាសថានឹងស្វែងរកអ្នក "មានបណ្ដាសក្តិខ្ពស់" យកមកសម្លាប់ចោល ដើម្បីសន្សំអង្ករទុកឲ្យអ្នកដែល "មិនមាននិន្នាការចំពោះសង្គមចាស់"[130]។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានរៀបរាប់ពីការដឹកអ្នករដ្ឋការ និងសិស្សនិស្សិតចំនួនប្រាំមួយឡានពេញ ដែលប្រមូលផ្តុំដោយអ៊ឹម ចែម ហើយត្រូវបានគេយកទៅសម្លាប់ចោល[131]។

28. អ្នកនៅរស់រានមានជីវិតម្នាក់ ក្នុងចំណោមអ្នកនៅរស់រានមានជីវិតពីរបីនាក់ មកពីភ្នំត្រយោង មានឈ្មោះទិត សម្បត្តិ ជាប្រជាជនមូលដ្ឋានដែលទទួលខុសត្រូវលើផ្នែកគ្រុនចាញ់ នៅមន្ទីពេទ្យឃុំភ្នំលាភ

[127] ឯកសារ **D219/397** កំណត់ហេតុស្តាប់ចម្លើយ ប៊ិន សុខ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣៥ [សក្ខីកម្មរបស់អតីតនិរសាអ៊ឹម ចែម]។

[128] ឯកសារ **D219/318** កំណត់ហេតុស្តាប់ចម្លើយ ដាន គាំ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៦, ២៤ដល់២៥, ៤៨, ៦២។ ឯកសារ **D219/175** កំណត់ហេតុស្តាប់ចម្លើយ ហង្ស ហ៊ីន ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៣១ដល់៣៣។

[129] ឯកសារ **D106/5** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយក.ស.ច.ស នៅត្រង់ចម្លើយ ២៣។ ឯកសារ **D119/65** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១៤៨ ["អ្នកធ្វើខុស" ត្រូវបានបញ្ជូនទៅភ្នំត្រយោង "ជាមួយក្រុមគ្រួសាររបស់ពួកគេ"]។ ឯកសារ **D119/130** កំណត់ហេតុស្តាប់ចម្លើយ អោម ហឿន ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ២២ ដល់២៤ [ក្រុមគ្រួសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានចាប់ខ្លួនដោយសារបងប្រុសរបស់គាត់ គឺជាអតីតកងទ័ពដែលបានរត់គេចទៅប្រទេសថៃ]។ ឯកសារ D219/153 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សឿន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៤ [ត្រូវបានចាប់ខ្លួនដោយសារតែ "សាច់ញាតិរបស់គាត់ធ្វើការឲ្យរបបមុន"]. សូមមើលផងដែរ ឯកសារ **D101/1.2** កំណត់ហេតុស្តាប់ចម្លើយ តោ ពិនថាង ជាមួយ ក.ស.ច.ស នៅត្រង់ ឯកសារភាសាអង់គ្លេស 00751068-69 [បញ្ជាក់ថាប្រសិនបើប្រជាជនមូលដ្ឋានត្រូវបានចាប់ខ្លួន ជាញឹកញាប់ "ក្រុមគ្រួសារទាំងមូល" របស់ពួកគេ ក៏ត្រូវបានចាប់ខ្លួនដែរ]។ ឯកសារ **D5/1364/1** កំណត់ហេតុស្តាប់ចម្លើយ ពិក សារ៉េត ជាមួយ ក.ស.ច.ស នៅត្រង់ឯកសារភាសាអង់គ្លេស 01061538-39 [បងប្រុសគឺជាអតីតទាហានលន់ នល់ ហើយត្រូវបានគេបញ្ជូនទៅភ្នំត្រយោង]។ ឯកសារ **D5/953/1** កំណត់ហេតុស្តាប់ចម្លើយ ដួន ចាន់រឿម ជាមួយ ក.ស.ច.ស នៅត្រង់ឯកសារភាសាអង់គ្លេស 00981510-11.

[130] ឯកសារ **D119/155** កំណត់ហេតុស្តាប់ចម្លើយ ឡាច ឈាងឡុង ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤៣ ដល់៤៦ [ក៏បានអះអាងផងដែរថាមានការចាប់ខ្លួនជាច្រើន ក្រោយពេលប្រជុំនោះ]។ *សូមមើលផងដែរ* ឯកសារD118/153 កំណត់ហេតុស្តាប់ចម្លើយ ឡុង វុន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៦១ ដល់៦២ [កម្មាភិបាលដែលមានវត្តមាននៅកិច្ចប្រជុំតំបន់ ដែលក្នុងកិច្ចប្រជុំនេះ ចែមបានពិភាក្សាពីការតាមចាប់ខ្មាំងលន់ នល់].

[131] ឯកសារ **D5/1045/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គាំ បុប្ផា នៅត្រង់ ឯកសារភាសាអង់គ្លេស 00991781-82.

ត្រូវបានចាប់ខ្លួន ហើយឃុំខ្លួននៅមន្ទីរសន្តិសុខនោះ ចាប់ពីខែ មិថុនា ឆ្នាំ ១៩៧៨ រហូតដល់ពេលចុងបញ្ចប់នៃរបប។ គាត់ត្រូវបានចាប់ខ្លួនបន្ទាប់ពីប្រធានមន្ទីរពេទ្យគាត់ បានរាយការណ៍ទៅ អ៊ឹម ចែម ថាគាត់បានតវ៉ាអំពីមេដឹកនា និងប្រធានដែលទទួលរបបអាហារល្អជាង អ្នកធ្វើការទូទៅ[132]។ នៅពេលដែលគាត់មកដល់ភ្នំត្រយោង មេគុកបានបង្ហាញគាត់នូវលិខិតមួយ ដែលចុះហត្ថលេខាដោយអ៊ឹម ចែម ដោយចោទប្រកាន់គាត់ថាជាជនក្បត់ ហើយបង្គាប់ឲ្យចាប់ខ្លួនគាត់ និងអ្នកធ្វើការជាមួយគាត់ពីរនាក់ទៀត[133]។ គាត់បានផ្តល់សក្ខីកម្មថា មានអ្នកទោសមិនដល់១០០នាក់ទេ នៅពេលដែលគាត់មកដល់ដំបូង ប៉ុន្តែពីរខែក្រោយមកចំនួនអ្នកទោសបានកើនដល់ "ជាងមួយពាន់គ្រួសារ"[134]។ គាត់បានឃើញអ្នកទោសខ្លះស្លាប់ដោយសារអត់ឃ្លានជារៀងរាល់ថ្ងៃ ហើយអ្នកផ្សេងត្រូវបានគេយកទៅសម្លាប់ជារៀងរាល់យប់[135]។ នៅជិតចុងរបប នៅពេលដែលកងទ័ពវៀតណាមកាន់តែខិតចូលមកដល់ គាត់ត្រូវបានគេបញ្ជាឲ្យជួយជីករណ្តៅរួមមួយ ហើយគាត់បានឃើញឆ្មាំសម្លាប់អ្នកទោស ដែលនៅសល់ចំនួន៩០នាក់[136]។ អ្នកទោសស្ត្រីដែលគេយកទៅសម្លាប់នៅយប់នោះ សុទ្ធតែអាក្រាតកាយ[137]។

---

[132] ឯកសារ D119/49 កំណត់ហេតុស្តាប់ចម្លើយ ធីប សម្បត្តិ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣៣-៣៦។ ឯកសារ D123/1/2.66 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ធីប សំផាត នៅត្រង់ ឯកសារភាសាអង់គ្លេស 00987603-04.

[133] ឯកសារ D119/49 កំណត់ហេតុស្តាប់ចម្លើយ ធីប សម្បត្តិ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤២ដល់៤៥។ ឯកសារ D106/8 កំណត់ហេតុស្តាប់ចម្លើយ ធីប សំផាត ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៧ដល់១៣។ ឯកសារ D123/1/2.66 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ធីប សំផាត នៅត្រង់ឯកសារភាសាអង់គ្លេស 00987605-06។ សូមមើលផងដែរ ឯកសារ D106/6 កំណត់ហេតុស្តាប់ចម្លើយ គីម យ៉េត ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ១០ដល់១១ ["គឺយាយ ចែម ដែលបញ្ជាឲ្យចាប់ខ្លួនសមាជិកក្រុមរបស់ខ្ញុំ"].

[134] ឯកសារ D119/49 កំណត់ហេតុស្តាប់ចម្លើយ ធីប សម្បត្តិ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ53-A54។ ឯកសារ D123/1/2.66 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ធីប សំផាត នៅត្រង់ ឯកសារភាសាអង់គ្លេស 00987610.

[135] ឯកសារ D119/49 កំណត់ហេតុស្តាប់ចម្លើយ ធីប សម្បត្តិ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥៥ ដល់៥៩ ។ ឯកសារ D106/8 កំណត់ហេតុស្តាប់ចម្លើយ ធីប សំផាត ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ២១។

[136] ឯកសារ D119/49 កំណត់ហេតុស្តាប់ចម្លើយ ធីប សម្បត្តិ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៦០ ដល់៦៤ ។ ឯកសារ D106/8 កំណត់ហេតុស្តាប់ចម្លើយ ធីប សំផាត ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៧-៣១។ ឯកសារ D123/1/2.66 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ធីប សំផាត នៅត្រង់ ឯកសារភាសាអង់គ្លេស 00987614-16.

[137] ឯកសារ D119/49 កំណត់ហេតុស្តាប់ចម្លើយ ធីប សម្បត្តិ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៦៤។ ឯកសារ D123/1/2.66 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ធីប សំផាត នៅត្រង់ ឯកសារភាសាអង់គ្លេស

29. ការស៊ើបអង្កេតរបស់ ក.ស.ច.ស ក៏បានកំណត់ផងដែរពី ការទទួលខុសត្រូវរបស់អ៊ឹម ចែម ក្នុងការចាប់ខ្លួន និងសម្លាប់ជនជាតិវៀតណាម។ កម្មករជនជាតិវៀតណាមនៅការដ្ឋានស្ពានស្រែង និងការដ្ឋានត្រពាំងថ្ម ព្រមទាំងប្រជាជនដែលពាក់ព័ន្ធ ឬមានទំនាក់ទំនងនិងជនជាតិវៀតណាម ត្រូវបានចាប់ខ្លួន និងយកទៅបាត់ នៅក្នុងពេលដែលអ៊ឹម ចែម មានសិទ្ធិអំណាចនៅការដ្ឋានទាំងនោះ[138]។ ការសម្លាប់ជនជាតិវៀតណាម ក៏បានកើតឡើងនៅទីតាំងដទៃទៀត នៅក្នុងស្រុកព្រះនេត្រព្រះផងដែរ នៅពេលដែលអ៊ឹម ចែម គឺជាលេខាស្រុក[139]។ សាក្សីម្នាក់បានស្ដាប់ឮអ៊ឹម ចែម និយាយអំពី "ការសម្រិតសម្រាំងជាតិពន្ធុ" ហើយបានរៀបរាប់ពីការចាប់ខ្លួន និងការបាត់ខ្លួនមិត្តភ័ក្តិជាខ្មែរក្រោមម្នាក់[140]។

**00987616.** សូមមើលផងដែរ ឯកសារ**D219/149** កំណត់ហេតុស្ដាប់ចម្លើយ ជុំ ជីម ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣៤ ដល់៣៥ [បញ្ជាក់ថាអ្នកទោសស្ត្រីត្រូវបានឆ្មាំយកទៅរំលោភ].

[138] ឯកសារ **D119/94** កំណត់ហេតុស្ដាប់ចម្លើយ ប៊ូ ម៉ៅ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣៧ [រៀបរាប់ពីការដែលនារី "ដែលជាប់ពាក់ព័ន្ធយួន" ត្រូវបានគេចាប់ខ្លួនហើយយកពីកងចល័តនៅការដ្ឋានភ្នំលាភទៅ នៅក្នុងឆ្នាំ ១៩៧៨]។ ឯកសារ **D219/130** កំណត់ហេតុស្ដាប់ចម្លើយ នៅ ឆាត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៥០ ដល់១៥៣ [បានរៀបរាប់ពីការដែលកម្មករវៀតណាម នៅក្នុងកងរបស់គាត់នៅត្រពាំងថ្ម ត្រូវបានគេយកទៅហើយកប់នៅរណ្ដៅក្បែរនោះ], ឆ ២០៧ [បញ្ជាក់ថាក្រុមនិរតីបានស្រាវជ្រាវប្រវត្តិរូប រកជនជាតិវៀតណាម]។ ឯកសារ D123/1/2.57 កំណត់ហេតុស្ដាប់ចម្លើយ ខោ មុត ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ ឯកសារភាសាអង់គ្លេស 00987554។ ឯកសារ **D119/23** កំណត់ហេតុស្ដាប់ចម្លើយ ប៊ុត ស្វាយ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ២០ [រៀបរាប់ពីការបាត់ខ្លួនគ្រួសារវៀតណាម១០០០គ្រួសារ ពីត្រពាំងថ្មក្នុងដើមឆ្នាំ ១៩៧៨].

[139] ឯកសារ **D119/125** កំណត់ហេតុស្ដាប់ចម្លើយ ម៉ាក វណ្ណី ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៦ដល់១៨ [បញ្ជាក់ថាមនុស្សរាប់ឡានដែលត្រូវបានចោទថាជាវៀតណាម ត្រូវបានគេយកទៅសម្លាប់នៅព្រៃតារុតក្នុងឆ្នាំ ១៩៧៨]។ ឯកសារ D119/73 កំណត់ហេតុស្ដាប់ចម្លើយ នូ ដួង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៧ ដល់២១ [សក្ខីកម្មរបស់សាក្សីដែលត្រូវបានគេបញ្ជា ឱ្យមកកប់សាកសពនៅឃុំព្រះនេត្រព្រះ បាននិយាយថាភ្លាមៗក្រោយពួកគេមកដល់ កម្មាភិបាលនិរតី "ចាប់ផ្ដើមសម្លាប់ជនជាតិចិន វៀតណាម ទាហានលន់ នល់ គ្រូបង្រៀន និងកម្មាភិបាលភូមិភាគពាយ័ព្យ"]។ ឯកសារ **D119/99** កំណត់ហេតុស្ដាប់ចម្លើយ ពេជ្រ រស់ ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៣១ ដល់៣៣ [ផ្ដល់សក្ខីកម្មថាក្នុងខែ កក្កដា ឬសីហា ឆ្នាំ ១៩៧៧ កម្មាភិបាលស្ត្រីជនជាតិវៀតណាមពីរនាក់ ត្រូវបានគេរំលោភ និងសម្លាប់យ៉ាងព្រៃផ្សៃ នៅ ខាងកើតភ្នំលាភ តាមបញ្ជារបស់កម្មាភិបាលនិរតី បន្ទាប់ពីគេបានស៊ើបប្រវត្តិរូប]។ ឯកសារ **D119/121** កំណត់ហេតុស្ដាប់ចម្លើយ កោ ឡែន ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៣ដល់៤, ១១ ដល់២០ [អះអាងពីការសម្លាប់ បន្ថែបានបដិសេធពីការចាប់រំលោភ].

[140] ឯកសារ **D219/13** កំណត់ហេតុស្ដាប់ចម្លើយ ឃុន សេរិន ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៤៧-៤៩. សូមមើលផងដែរ ឯកសារ **D119/121** កំណត់ហេតុស្ដាប់ចម្លើយ កោ ឡែន ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៥៥ [គោលនយោបាយបក្ស

## គ. ការទទួលខុសត្រូវលើការបោសសម្អាតនៅភូមិភាគពាយ័ព្យ

30. អ៊ឹម ចែមត្រូវបានមេដឹកនាំមជ្ឈិមបក្សផ្តល់ទំនុកចិត្ត ឲ្យជួយពិនិត្យមើលលើតំបន់ទីមួយ ដែលត្រូវ "សម្អាត" នៅក្នុងការបោសសម្អាតនៅភូមិភាគពាយ័ព្យ ដែលចាប់ផ្តើមនៅតំបន់៥ ក្នុងខែ មិថុនា ឆ្នាំ ១៩៧៧ ហើយបន្តរហូតដល់ពេលចាប់ខ្លួនលេខាភូមិភាគ រស់ ញឹម នៅពាក់កណ្តាលឆ្នាំ ១៩៧៨[141]។ គាត់បានទទួលស្គាល់ថាគាត់បានមកដល់ មុនពេលចាប់ខ្លួនលេខាស្រុកព្រះនេត្រព្រះ ឈ្មោះមោង និង អនុលេខាឈ្មោះសំអាត ហើយបានជួបជាមួយពួកគាត់ មុនពេលដែលគេយកពួកគាត់ទៅ[142]។ កម្មាភិបាលម្នាក់បានរៀបរាប់ពីកិច្ចប្រជុំមួយ ដែលអ៊ឹម ចែមបានចោទប្រកាន់សំអាតថាជាជនក្បត់ ហើយក្រោយមកគាត់ត្រូវបានចាប់ខ្លួនយកទៅ[143]។ សំអាតត្រូវបានបញ្ជូនពីព្រះនេត្រព្រះទៅសខ២១[144]។ របាយការណ៍មួយចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៧៧ បានរៀបរាប់ពីស្ថានភាពនៃការសួរចម្លើយគាត់៖ "ទារុណកម្មមានភាពធ្ងន់ធ្ងរកន្លងមក ហើយសុខភាពរបស់វាខ្សោយខ្លាំង ប៉ុន្តែវានៅតែធ្វើពើគ្រប់បែប

---

កុម្មុយនីស្តកម្ពុជាក្នុងការសម្លាប់ជនជាតិវៀតណាម ត្រូវបានពិភាក្សាក្នុងកិច្ចប្រជុំឆ្នាំ ១៩៧៦ ដែលដឹកនាំដោយអតីតលេខាស្រុកឈ្មោះមោង].

[141] ឯកសារ D219/294 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៦៤ [សក្ខីកម្មរបស់អតីតលេខាស្រុកបក្សកុម្មុយនីស្តកម្ពុជាថា ចែមទទួលបានសិទ្ធអំណាច ក្នុងការដកហូតកម្មាភិបាលពាយ័ព្យ]។ ឯកសារ **D119/124** កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម អេន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៣ដល់២៧ ["តាម៉ុកបានចាត់តាំងកម្មាភិបាលដែលគាត់ទុកចិត្ត មកពីនិរតី ដើម្បីដឹកនាំភូមិភាគផ្សេងៗទៀតទាំងអស់ រួមទាំងភូមិភាគពាយ័ព្យ" – កម្មាភិបាលដែលស្មោះត្រង់មកពីនិរតីដូចជាអ៊ឹម ចែម ត្រូវបានបញ្ជូនទៅ "កម្ទេច" កម្មាភិបាល "ដែលសង្ស័យថាជាសេអ៊ីអា កាហ្សេបេ ឬភ្នាក់ងារវៀតណាម"]។

[142] ឯកសារ D123/1/5.1a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00089773 ["នៅពេលខ្ញុំមកដល់ តាមោង និងតាអាតនៅរស់នៅឡើយ។ ប៉ុន្តែបន្ទាប់ពីខ្ញុំបានទទួលបញ្ជី ពួកគេទាំងពីរនាក់ត្រូវបានគេយកទៅ"]។ ឯកសារD1.3.12.1 កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, នៅត្រង់ ឯកសារភាសាអង់គ្លេស 00217518-20។ D123/1/5.1c បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951853។

[143] ឯកសារ **D119/74** កំណត់ហេតុស្តាប់ចម្លើយ ប្រាច គិត ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ១។ សូមមើលផងដែរ ឯកសារ **D119/98** កំណត់ហេតុស្តាប់ចម្លើយ កោ ឡេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២០ [ប្អូនប្រុសរបស់សំអាតក៏ត្រូវបានគេយកទៅសម្លាប់ផងដែរ]។

[144] ឯកសារ **D1.3.25.4** បញ្ជីអ្នកទោសស២១, ខែ កញ្ញា ឆ្នាំ ១៩៧៧ នៅត្រង់ឯកសារភាសាអង់គ្លេស 00837611 (លេខ ៥២)។ ឯកសារ **D191.1.110** ចម្លើយសារភាពមន្ទីរស២១ របស់មក់ ឈឿង ហៅសំអាត, ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៧៧។

ថាមិនដឹងអ្វី"[145]។ អតីតលេខាស្រុកមោង បានចូលស២១នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៧៧ ហើយត្រូវបានសម្លាប់នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៧៧ ជាមួយកម្មាភិបាល៦៩នាក់ផ្សេងទៀត មកពីភូមិភាគពាយ័ព្យ[146]។

31. កម្មាភិបាលជាទូទៅត្រូវបានចាប់ខ្លួន បន្ទាប់ពីត្រូវបានគេហៅទៅរៀនសូត្រ ឬទៅប្រជុំនៅមន្ទីរស្រុក[147]។ អតីតប្រធានក្រុមកងចល័តម្នាក់ បានរៀបរាប់ពីកិច្ចប្រជុំមួយនៅផ្ទះ អ៊ឹម ចែម ដែលនៅក្នុងកិច្ចប្រជុំនេះមេឃុំព្រះនេត្រព្រះឈ្មោះ តាក្រក មេសហករណ៍ស្រែឈ្មោះ តាចាម និងកម្មាភិបាលពីរនាក់ទៀតត្រូវបានគេហៅ។ សាក្សីបានស្ដាប់ឮសម្រែកចេញពីក្នុងកន្លែងប្រជុំ ហើយបានបញ្ជាក់ថាកម្មាភិបាលទាំងបួន បានបាត់ខ្លួនតាំងពីពេលនោះមក ហើយមិនដែលឃើញវិញឡើយ[148]។ សាក្សីផ្សេងទៀតបានបញ្ជាក់ពីអត្តសញ្ញាណរបស់កម្មាភិបាលម្នាក់ ដែលត្រូវបានកោះហៅទៅផ្ទះអ៊ឹម ចែម ហើយត្រូវបានគេយកទៅសម្លាប់ បន្ទាប់ពីមានគេរាយការណ៍ប្រាប់ចែមថា មានស្ត្រីពីរនាក់បានទៅ

---

[145] ឯកសារ **D191.1.110** ចម្លើយសារភាពមន្ទីរស២១ របស់មក់ លឿង ហៅសំអាត, ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៧៧ នៅត្រង់ឯកសារភាសាអង់គ្លេស 00782190។

[146] ឯកសារ **D191.1.111** បញ្ជីឈ្មោះអ្នកទោស ស២១ ដែលត្រូវបានកម្ទេចនៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៧៧នៅត្រង់ ឯកសារភាសាអង់គ្លេស 00873645 (No. 134)។ ឯកសារ **D6.1.883** បញ្ជីឈ្មោះអ្នកទោស ស២១ ដែលក.ស.ព បានកែសម្រួលហើយ [No. 57]។ ឯកសារ **D1.3.4.1** ចម្លើយសារភាពមន្ទីរស២១ របស់ អាន មោង, ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៧។

[147] ឯកសារ **D119/98** កំណត់ហេតុស្ដាប់ចម្លើយ កោ ឡេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៣ដល់២៤ [កងទ័ពព្រះនេត្រព្រះ "បានហៅទៅរៀនសូត្រ" ហើយមិនឃើញត្រឡប់មកវិញ]។ ឯកសារ **D219/130** កំណត់ហេតុស្ដាប់ចម្លើយ នៅ ឆាត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៨៦ដល់៨៩ [កម្មាភិបាលពាយ័ព្យ "ត្រូវបានគេហៅទៅរៀនសូត្រ" បន្ទាប់ពីកិច្ចប្រជុំដែលកម្មាភិបាលនិរតីបានប្រកាសថា ពួកគេនឹង "បោសសម្អាតអ្នកចាស់ចោល"]។ ឯកសារ **D119/33** កំណត់ហេតុស្ដាប់ចម្លើយ ឈិត យក់ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៤ ["មនុស្សមួយក្រុមដែលចាប់ខ្លួនគេ គឺមិពីភូមិភាគនិរតី។ កម្មាភិបាលត្រូវបានគេហៅទៅប្រជុំនៅមន្ទីរស្រុក ហើយបន្ទាប់មកត្រូវបានគេចាប់ខ្លួន"]។ ឯកសារ D219/173 កំណត់ហេតុស្ដាប់ចម្លើយ លៀស ស្ដើង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣១ ដល់៣៤ [បានរៀបរាប់ពីការចាប់ខ្លួនកម្មាភិបាលឃុំទៀនកាំ ក្រោយពេលចែមមកដល់]។

[148] ឯកសារ **D119/121** កំណត់ហេតុស្ដាប់ចម្លើយ កោ ឡែន ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៣៥ ដល់៤៤ [បានកំណត់អត្តសញ្ញាណគណៈឃុំភ្នំលាភឈ្មោះតាផាង និងប្រធានសាងសង់ស្ពានត្រពាំងថ្មឈ្មោះតាម៉ាង ថាជាជនរងគ្រោះពីរនាក់ទៀត]។ សូមមើលផងដែរ ឯកសារ **D119/99** កំណត់ហេតុស្ដាប់ចម្លើយ ពេជ្រ រស់ ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ២២, ២៦ ដល់ ២៧។

ផ្ទះកម្មាភិបាលនោះ[149]។ អ៊ឹម ចែមរៀបចំកិច្ចប្រជុំដែលនៅក្នុងកិច្ចប្រជុំនោះ គាត់បានប្រកាសថាកម្មាភិបាលពាយ័ព្យគឺជា "ជនក្បត់" ហើយបានពិភាក្សា "កម្ទេចខ្មាំងផ្ទៃក្នុង"[150]។

32. អ៊ឹម ចែមបានទទួលស្គាល់ថា បក្សកុម្មុយនីស្តកម្ពុជាចង់ឲ្យគាត់ "ចាប់ខ្លួនប្រជាជន និងមេភូមិ" ប៉ុន្តែបានអះអាងថាគាត់ "ជួយលាក់" ប្រជាជនដោយមិនចាប់ខ្លួនពួកគេឡើយ[151]។ ប៉ុន្តែអតីតសមាជិកគណៈកម្មាធិការស្រុកព្រះនេត្រព្រះ ជាមនុស្សដែលអ៊ឹម ចែម បានបញ្ជាក់ថាជាមនុស្សដែលគាត់ "សម្រេចទុក" និង "ការពារ" មិនឲ្យចាប់ខ្លួននោះ[152] គឺជាមនុស្សម្នាក់ក្នុងចំណោមកម្មាភិបាលពាយ័ព្យមួយចំនួនតូចប៉ុណ្ណោះនៅក្នុងស្រុក ដែលនៅរស់រានមានជីវិត[153]។ គាត់បានបញ្ជាក់ថាមូលហេតុដែលគេទុកឲ្យគាត់នៅរស់ ព្រោះដើម្បីជួយកម្មាភិបាលនិរតី ក្នុងការចាប់ខ្លួននិងបោសសម្អាត កម្មាភិបាល

---

[149] ឯកសារ **D119/99** កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ រស់ ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៣៥ [និយាយពីកម្មាភិបាលមូលដ្ឋានឈ្មោះ សម ប៊ុន]។

[150] ឯកសារ **D119/91** កំណត់ហេតុស្តាប់ចម្លើយ ជៀម តាប់ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៥ [សក្ខីកម្មរបស់ប្រធានសហករណ៍ដែលមានវត្តមាននៅកិច្ចប្រជុំ ដែលអ៊ឹម ចែមបានប្រកាសថាអតីតលេខាតំបន់៥ឈ្មោះហឿន គឺជា "ជនក្បត់"]។ ឯកសារD119/143 កំណត់ហេតុស្តាប់ចម្លើយ ឃៀង ឃុន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៦៥។ ឯកសារ D219/13 កំណត់ហេតុស្តាប់ចម្លើយ ឃុន សេរិន ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៣៦ ដល់៣៨។ ឯកសារ **D101/1.1** កំណត់ហេតុស្តាប់ចម្លើយ ប៉ោ បណ្ឌិត ជាមួយ ក.ស.ច.ស នៅត្រង់ឯកសារភាសាអង់គ្លេស 00746366 [រៀបរាប់ពីកិច្ចប្រជុំឆ្នាំ ១៩៧៧ ដែលចែមបានព្រមានពី "ខ្មាំងបង្កប់"]។

[151] ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951808។ ឯកសារ D123/1/5.1a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00089782។

[152] ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951803 & 00951808។ ឯកសារ D123/1/5.1a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00089782 [អះអាងថាគត់មិនមើលលិខិតបីច្បាប់ មកពីមន្ទីរភូមិភាគដែលស្នើសុំឲ្យចាប់ខ្លួន]។ D123/1/5.1c បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951853-54។

[153] ឯកសារ **D219/23** កំណត់ហេតុស្តាប់ចម្លើយ ពុំ កូ ដោយក.ស.ច.ស នៅត្រង់ចម្លើយ ៥១ ដល់៥២ ["តាមខ្ញុំដឹងមានតែខ្ញុំម្នាក់គត់ដែលនៅរស់""], ឆ ៥៣ [ដើម្បីកុំឲ្យគេប្រឆាំងខ្លាំងលក់ការចាប់ខ្លួន "កម្មាភិបាលនិរតីបានបញ្ជាឲ្យចាប់ខ្លួនកម្មាភិបាលពាយ័ព្យ ដោយតាមដានកម្មាភិបាលពាយ័ព្យព្រោះគេគិតថា កម្មាភិបាលពាយ័ព្យស្គាល់គ្នាទៅវិញទៅមក"], ឆ ៧៧ ដល់៨០ [បញ្ជាក់ថាមេភូមិភ្នំលាភឈ្មោះ សុខ គឺជាកម្មាភិបាលមូលដ្ឋានម្នាក់ទៀត ដែលមិនត្រូវបានចាប់ខ្លួន]. សូមមើលផងដែរ ឯកសារ **D119/32** កំណត់ហេតុស្តាប់ចម្លើយ ឈឹម ផាន់ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៧ [សក្ខីកម្មរបស់អតីតសមាជិកឃុំ ព្រះនេត្រព្រះ ដែលថាគាត់និងគោ គឺជាកម្មាភិបាលតែពីរនាក់គត់ "ដែលនៅរស់ក្រោយមពេលក្រុមភូមិភាគនិរតីមកដល់"]។

ពាយ័ព្យចាស់[154]។ កម្មាភិបាលពាយ័ព្យដែលគេស្គាល់ថានៅរស់រានមានជីវិត បានរៀបរាប់ពី "ភាពរញ៉េរញ៉ៃ" នៅពេលដែលកម្មាភិបាលនិរតីមកដល់ ហើយបានបញ្ជាក់ថាគាត់នៅរស់ដោយសារតែឈ្មោះរបស់គាត់មិនមាននៅក្នុង "បញ្ជី" ដែលរៀបចំដោយអ្នកមកថ្មី[155]។ ជារួមកម្មាភិបាលភូមិភាគពាយ័ព្យជាង ១២០០នាក់ ត្រូវបានបញ្ជូនទៅស២១ដើម្បីសម្លាប់ ដែលភាគច្រើនលើសលប់គឺ នៅចន្លោះខែ មិថុនា ឆ្នាំ ១៩៧៧ ដល់ខែ ឧសភា ឆ្នាំ ១៩៧៨[156]។ សាក្សីបានអះអាងថាមនុស្សជាច្រើនត្រូវបានចាប់ខ្លួន និងបាត់ខ្លួននៅក្នុងអំឡុងពេលដែល អ៊ឹម ចែម ជាលេខាស្រុកព្រះនេត្រព្រះ[157]។ ការបោសសម្អាតបានពង្រីកដល់មេភូមិ មេកងចល័ត មេបញ្ជាការកងទ័ព (ដល់ថ្នាក់អនុសេនាតូច) ព្រម

[154] ឯកសារ **D219/359.1** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយពុំ គោ នៅត្រង់ឯកសារភាសាអង់គ្លេស 01112057, 01112059 ["ពួកគេសម្រេចរក្សាទុកគាត់ ហើយប្រើប្រាស់គាត់មួយរយៈពេល ព្រោះវាងាយស្រួលសម្រាប់ពួកគេស្វែងរកកម្មាភិបាលចាស់របស់ភូមិភាគពាយ័ព្យ និងចាប់ខ្លួនពួកគេដោយការសួរសម បើមានគាត់ជួយ"]។

[155] ឯកសារ **D219/347** កំណត់ហេតុស្តាប់ចម្លើយ ឈឹម ផាន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៥, ៥៥ ដល់៥៦ [បង្ហាញពីអារម្មណ៍ធូរស្រាលដែលគាត់នៅរស់ "ព្រោះពួកគេចាប់មនុស្សច្រើនណាស់"]. សូមមើលផងដែរ ឯកសារ**D119/32** កំណត់ហេតុស្តាប់ចម្លើយ ឈឹម ផាន់ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៧, ៤៩ [បញ្ជាក់ថាចែមគឺជា "មនុស្សល្អ" ដែល "ជាមនុស្សមានហេតុផលជាង សមាជិកគណៈស្រុកដទៃទៀត""], ឆ ៥៥ ["ខ្ញុំមិនជឿថាក្រោមការគ្រប់គ្រងរបស់គាត់ មានមនុស្សស្លាប់ដល់រាប់ពាន់នាក់នោះទេ"]. ឈឹម ផានបានទទួលស្គាល់ថាក្នុងឆ្នាំ ១៩៧៧ ក្រោយពេលយាយ ចែម និងកម្មាភិបាលនរតីមកដល់ គាត់បានសម្លាប់សង្ឃាមួយគូ ដែលត្រូវបានគេចោទថាខុសសីលធម៌ នៅវត្តព្រះនេត្រព្រះ តាមបញ្ជារបស់អនុស្រុក នៅត្រង់ (ឯកសារ **D219/347** កំណត់ហេតុស្តាប់ចម្លើយ ឈឹម ផាន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ១ ដល់៨, ១៨)។

[156] ឯកសារ **D6.1.890** បញ្ជីរបស់ ក.ស.ព ស្តីពីអ្នកទោស ស២១ ដែលមកពីភូមិភាគពាយ័ព្យ។

[157] ឯកសារ **D119/94** កំណត់ហេតុស្តាប់ចម្លើយ ប៊ូ ម៉ៅ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤៣ ដល់៤៤ ["ប្រជាជនជាច្រើនបានបាត់ខ្លួន ក្រោមការគ្រប់គ្រងរបស់យាយ ចែម... អ្នកដែលត្រូវបានគេចាប់ខ្លួនរួមមាន កម្មាភិបាលពាយ័ព្យនិងអ្នករស់នៅក្នុងភូមិនេះ"]។ ឯកសារ **D119/99** កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ រស់ ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៣៦ ["នៅកន្លែងដែលស្ថិតក្រោមការគ្រប់គ្រងរបស់យាយ ចែម ការចាប់ខ្លួន និងការសម្លាប់បានកើនឡើង"]។ ឯកសារ **D219/13** កំណត់ហេតុស្តាប់ចម្លើយ ឃុន សេរិន ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៣៦ ដល់៣៨ [បញ្ជាក់ថាកម្មាភិបាលពាយ័ព្យទាំងអស់ ត្រូវបានគេយកទៅសម្លាប់ ក្រោយពេលដែលយាយ ចែម បានដឹកនាំការប្រជុំរិះគន់កម្មាភិបាលដែលត្រូវបានបោសសម្អាត ដោយសារតែចង់រត់គេចទៅប្រទេសថៃ], ឆ ៤០ ។ ឯកសារ D219/173 កំណត់ហេតុស្តាប់ចម្លើយ លៀស ស្តើង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣១ ដល់៣៤, ៤៩ ដល់៥០ [កត់សម្គាល់ផងដែរថា "ប្រជាជនទាំងអស់ខ្លាច" យាយ ចែម ព្រោះ "អំណាចដ៏ខ្លាំង" របស់គាត់"]។ ឯកសារ D123/1/2.57 កំណត់ហេតុស្តាប់ចម្លើយ ខោ មុត ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ឯកសារភាសាអង់គ្លេស 00987571 [រៀបរាប់ពីតំបន់ ៥ ស្ថិតក្រោមកម្មាភិបាលនិរតីថា "ជាតំបន់អាក្រក់បំផុត" ក្នុងផ្នែក "របបអាហារ និងការសម្លាប់"]។ ឯកសារ D119/73 កំណត់ហេតុស្តាប់ចម្លើយ នូ ជួង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៥ ដល់ ២៦ [ឈ្លបបានប្រាប់សាក្សីថា យាយ ចែម បញ្ជាឲ្យចាប់ខ្លួនកម្មាភិបាលពាយ័ព្យ]។

ទាំងក្រុមគ្រួសាររបស់ពួកគេ[158]។ ភាគច្រើននៃកម្មាភិបាលដែលត្រូវបានចាប់ខ្លួន ត្រូវបានសួរចម្លើយនៅមន្ទីរសន្តិសុខតំបន់នៅស្វាយស៊ីសុផុន បើទោះបីជាពួកគេទាំងនោះនៅពេលបន្ទាប់មក ត្រូវបានបញ្ជូនទៅស២១ក៏ដោយ[159] ហើយអ្នកខ្លះទៀតត្រូវបានបញ្ជូនទៅភ្នំត្រយោង[160]។

33. អ៊ឹម ចែម បានដឹងថាគាត់ត្រូវបានគេលើកឈ្មោះនៅក្នុងចម្លើយសារភាព ហើយក៏ដឹងថាលេខាភូមិភាគរស់ ញឹម ចង់ចាប់ខ្លួនគាត់ដែរ ប៉ុន្តែគាត់បានបញ្ជាក់ថាប៉ុល ពត បានបដិសេធមិនយល់ព្រមឲ្យចាប់ខ្លួនគាត់[161]។ (ចម្លើយសារភាពមន្ទីរស២១ ចំនួនពីរដែលឆ្លើយដាក់អ៊ឹម ចែម ត្រូវបានរកឃើញ[162])។ ការលើកឡើងទាំងអស់នេះបានកំណត់ពីការដឹងឮរបស់ អ៊ឹម ចែម អំពីការប្រើប្រាស់

[158] ឯកសារD119/32 កំណត់ហេតុស្តាប់ចម្លើយ ឈឹម ផាន់ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣១ [បង្ហាញពីមេភូមិ និងមេសហករណ៍ នៅឃុំព្រះនេត្រព្រះដែលត្រូវបានបោសសម្អាត ហើយជំនួសដោយ "កម្មាភិបាលស្ត្រីមកពីភូមិភាគនិរតី"]។ ឯកសារ D119/98 កំណត់ហេតុស្តាប់ចម្លើយ កោ ឡេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៨, ២១ ដល់២៤ [ក្រុមនិរតីបានចាប់កម្មាភិបាលពាយ័ព្យ រួមមាន "មេកងចល័ត និងប្រធានវរៈ" ហើយចោទប្រកាន់ពួកគេថាជា "ជនក្បត់"]។ ឯកសារ D219/318 កំណត់ហេតុស្តាប់ចម្លើយ ដាន តាំ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៣ ដល់២៤ [រៀបរាប់ពីការចាប់ខ្លួនប្តីរបស់គាត់ ដែលជាមេបញ្ជាការកងអនុសេនាតូចភូមិភាគ]។

[159] ឯកសារ D219/318 កំណត់ហេតុស្តាប់ចម្លើយ ដាន តាំ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤ ដល់៦, ៣៤ ដល់៣៩ [រៀបរាប់ពីការឃុំខ្លួន ការសួរចម្លើយ ការធ្វើទារុណកម្ម និងការសម្លាប់កងទ័ព និងឈ្លបបក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខចំការគ នៅស្វាយស៊ីសុផុន ដែលក្នុងនោះមានប្តីរបស់គាត់ផង], ឆ ៤៦ [រៀបរាប់ពីការដែលកម្មាភិបាលនិរតីចុះពិនិត្យមើលគុក "ដោយកាន់សៀវភៅ និងកត់ត្រាដើម្បីផ្ទៀងផ្ទាត់"]។

[160] សូមមើលជាឧទាហរណ៍, ឯកសារ D219/318 កំណត់ហេតុស្តាប់ចម្លើយ ដាន តាំ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៦២។ ឯកសារ D219/175 កំណត់ហេតុស្តាប់ចម្លើយ ហង្ស ហ៊ិន ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៣១ ដល់៣៣។

[161] ឯកសារ D123/1/5.1a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00089780-81 ["ពួកគេនិយាយថាពួកគេចង់ចាប់ខ្ញុំ។ គេឆ្លើយដាក់ខ្ញុំក្នុងចម្លើយសារភាពរបស់អ្នកដែលត្រូវបានចាប់ខ្លួន"]។ ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951808-09 ["ប៉ុល ពត ប្រាប់ពួកគេថា គាត់មិនឯកភាពឲ្យចាប់ខ្ញុំទេ... គាត់ដឹងពីប្រវត្តិខ្ញុំច្បាស់"]។ ឯកសារD1.3.12.1 កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, នៅត្រង់ ឯកសារភាសាអង់គ្លេស 00217525។

[162] ឯកសារ D1.3.4.6 ចម្លើយសារភាពមន្ទីរស២១ របស់គង់ សុផល ហៅគោអនុលេខភូមិភាគពាយ័ព្យ, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ១៩៧៨ នៅត្រង់ឯកសារភាសាអង់គ្លេស 00217743 [ឈ្មោះ "ចែម (ស) លេខាស្រុកព្រះនេត្រព្រះ"]។ ឯកសារ D1.3.4.4 ចម្លើយសារភាពរបស់ ហឿង រិន ហៅម៉ី នៅ មន្ទីរស២១, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨ នៅត្រង់ឯកសារភាសាអង់គ្លេស 00217736 [ឆ្លើយដាក់ "ចែម អតីតកម្មាភិបាលនិរតី ដែលក្រោយមកជាកម្មាភិបាលពាយ័ព្យ" និងប្តីរបស់គាត់ឈ្មោះ ញៀន]. អ៊ឹម ចែមហាក់ដូចជាបានដឹងថាគាត់មានឈ្មោះ នៅក្នុងចម្លើយសារភាពនៅមន្ទីរស២១ របស់ ហឿង រិន ដែលជាលេខាភូមិភាគ ៥

ចម្លើយសារភាពនៅ ស២១ ដើម្បីកំណត់អត្តសញ្ញាជនក្បត់ដែលត្រូវបានចោទប្រកាន់ និងធ្វើការចាប់ខ្លួនបន្ថែមទៀត ព្រមទាំងសម្លាប់ចោល។ ការពិតដែលថាគាត់មិនដែលត្រូវបានគេចាប់ខ្លួន បង្ហាញថាគាត់ត្រូវបានទុកចិត្ត ហើយការពារដោយមេដឹកនាំកំពូលបក្ស នៅទីក្រុងភ្នំពេញ។

### ឃ. ការទទួលខុសត្រូវលើការដ្ឋានពលកម្មដោយបង្ខំ

34. អ៊ឹម ចែម បានទទួលស្គាល់ពីការទទួលខុសត្រូវរបស់គាត់ ចំពោះការសាងសង់ទំនប់ និងប្រឡាយនៅស្រុកព្រះនេត្រព្រះ និងតំបន់៥ នៃភូមិភាគពាយ័ព្យ។ គាត់បានទទួលស្គាល់ថា គាត់បានចាត់តាំងកម្លាំងពលកម្ម ឲ្យទៅធ្វើការនៅទំនប់ត្រពាំងថ្ម ហើយបានទៅមើលទីនោះ ព្រមទាំងបានចូលរួមក្នុងកិច្ចប្រជុំ និងបានត្រួតពិនិត្យទៅលើកម្មករមកពីព្រះនេត្រព្រះ នៅការដ្ឋាននោះផងដែរ[163]។ គាត់ក៏បានរៀបរាប់ថាគាត់បានផ្តួចផ្តើម និងពិនិត្យមើលលើការបញ្ចប់គម្រោងធារាសាស្ត្រ នៅស្រុកព្រះនេត្រព្រះតាមរបៀបណា រួមបញ្ចូលទាំងទំនប់មួយដែលគេស្គាល់ថាជា "ទំនប់យាយចែម"[164]។

---

មកពីកំពត។ សូមមើល ឯកសារ D123/1/5.1a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00089780 [កំណត់អត្តសញ្ញាណ "ចៅហ្វាយខេត្តកំពត" ជាការឆ្លើយតបទៅនឹងសំណួរអំពី នរណាដែលឆ្លើយដាក់គាត់]។

[163] ឯកសារD1.3.12.1 កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, នៅត្រង់ ឯកសារភាសាអង់គ្លេស 00217523។ ឯកសារ D123/1/5.1a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00089771-74 ["ខ្ញុំចុះពិនិត្យកន្លែងនោះ និងតំបន់ក្រោមៗ... ខ្ញុំបញ្ជូនកម្លាំងខ្ញុំទៅជួយបំពេញ និងជួយធ្វើការ"], 00089778-79 ["កម្លាំងរបស់ខ្ញុំមានគ្នា ៨០០នាក់... ខ្ញុំចល័ត២០០នាក់ មកពីឃុំនីមួយៗ"]. សូមមើលផងដែរ ឯកសារ D123/1/2.57 កំណត់ហេតុស្តាប់ចម្លើយ ខោ មុត ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ ឯកសារភាសាអង់គ្លេស 00987568-69។ ឯកសារ D119/90 កំណត់ហេតុស្តាប់ចម្លើយ ជួន ភាព ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ១២។ ឯកសារ D219/130 កំណត់ហេតុស្តាប់ចម្លើយ នៅ ឆាត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១០៩។ ឯកសារ D219/361 កំណត់ហេតុស្តាប់ចម្លើយ លើយ តេះ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤៤, ៧៣ ដល់៧៦ [ចែមទៅពិនិត្យការដ្ឋានរាល់សប្តាហ៍ ហើយជំរុញឲ្យកម្មករ "ខំធ្វើការ"]។ ឯកសារ **D119/124** កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម អេន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៦ ដល់១៩ [សាក្សីបានជួបជាមួយ អ៊ឹម ចែម នៅទំនប់ត្រពាំងថ្ម ក្នុងខែ មិថុនា ឬកក្កដា ឆ្នាំ ១៩៧៧]។ ឯកសារ **D67.9** កិច្ចសម្ភាសន៍ជាមួយ ឈីត យឿក ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ ឯកសារភាសាអង់គ្លេស 00731135 [ចម្លើយរបស់ប្រធានសេដ្ឋកិច្ចចល័តតំបន់ ៥ ដែលថា ទំនប់ត្រពាំងថ្មបញ្ចប់ទើបបាន ៣០ %ទេ នៅពេលចាប់ខ្លួន តា វ៉ាល់ និងកម្មាភិបាលពាយ័ព្យដទៃទៀត ក្នុងខែ មិថុនា ឆ្នាំ ១៩៧៧], ឯកសារភាសាអង់គ្លេស 00731142 [អ៊ឹម ចែម ចុះពិនិត្យត្រពាំងថ្ម]។

[164] ឯកសារD1.3.12.1 កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, នៅត្រង់ ឯកសារភាសាអង់គ្លេស 00217524 ["ខ្ញុំចាប់ផ្តើមធ្វើផែនការ និងធ្វើការងារសាងសង់"], 00217527-28 ["ខ្ញុំបានកសាងទ្វាទឹកបានបី ក្នុងទំនប់មួយ

គម្រោងនោះរួមមានប្រឡាយមួយ ប្រវែង១០គីឡូម៉ែត្រ និងទទឹង៣០ម៉ែត្រ ដែលហូរកាត់ផ្នែកខាងកើតភ្នំលាភ ដែលទំនប់នេះត្រូវបានកសាងឡើងក្នុងពេលត្រឹមតែបីខែប៉ុណ្ណោះ[165]។ គាត់បានទាក់ទងប៉ុល ពតដោយផ្ទាល់ ដើម្បីស្នើសុំការជួយពីប៉ុល ពត[166] ហើយបានបញ្ជាក់ថា "អង្គការលើយកចិត្តទុកដាក់ចំពោះការងារ (របស់គាត់)"[167]។ គាត់បានទទួលស្គាល់ថាគាត់បានចាត់ចែងកម្មករ នៅការដ្ឋានទាំងអស់នោះ ហើយការបញ្ជារបស់គាត់ "គឺម៉ឺងម៉ាត់" ហើយអ្នកដែលមិនធ្វើការគឺខ្លាចគាត់ណាស់[168]។

35. គម្រោងធារាសាស្ត្រធំដែលអ៊ឹម ចែម ទទួលខុសត្រូវក្នុងការកសាង ត្រូវបានគេហៅជាទូទៅថាជាទំនប់ប្រឡាយស្ពានស្រែង ឬអូរលាភ។ ទំនប់ស្ពានស្រែងត្រូវបានកសាង នៅព្រំប្រទល់ស្រុកព្រះនេត្រ

---

ហើយនិងទ្វាទឹកមួយទៀតនៅផ្លូវជាតិលេខ ៦"]។ D123/1/5.1c បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951855។ ឯកសារ D123/1/5.1a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00089774-77 [បញ្ជាក់ថាក្នុងឆ្នាំ ១៩៧៨ គាត់បានរៀបចំផែនការ និងកសាង "ទំនប់ពីរ ប្រឡាយមួយ ដែលភ្ជាប់ត្រពាំងថ្ម" រួមទាំងស្ពានស្រែងផង ]. សូមមើលផងដែរ ឯកសារ **D219/253** កំណត់ហេតុស្តាប់ចម្លើយ សាន ហាវ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៧។ ឯកសារ **D119/65** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ២០៧ [អះអាងពីការទទួលខុសត្រូវរបស់ចែម ក្នុងការសង់ទំនប់និងប្រឡាយ]។ ឯកសារ **D219/397** កំណត់ហេតុស្តាប់ចម្លើយ ប៊ិន សុខ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ២ដល់៦ [ចែម "បញ្ជាយើងឲ្យសង់ទំនប់ និងជីកប្រឡាយ"]។ ឯកសារ **D119/98** កំណត់ហេតុស្តាប់ចម្លើយ កោ ឡេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣២ [ប្រធានក្រុមបានរៀបរាប់ពីអ៊ឹម ចែម ដែលចុះពិនិត្យមើលការដ្ឋាននៅស្រុកព្រះនេត្រព្រះ ហើយបញ្ជាក់ថាគាត់ពេលខ្លះជួយរែកដីកម្មករ]។

[165] ឯកសារD1.3.12.1 កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, នៅត្រង់ ឯកសារភាសាអង់គ្លេស 00217524 ["ខ្ញុំប្រើពេលតែបីខែប៉ុណ្ណោះដើម្បីសង់ប្រឡាយនេះ"], 00217527-28។ ឯកសារ D123/1/5.1a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00089775-76 ["យើងសង់ប្រឡាយមួយដែលមានទទឹង ៣០ម៉ែត្រ និងបណ្តោយ ១០គីឡូម៉ែត្រ ដោយភ្ជាប់ពីត្រពាំងថ្ម ចុះទៅទន្លេអូរជីត"]។ ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951810។

[166] ឯកសារD1.3.12.1 កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, នៅត្រង់ ឯកសារភាសាអង់គ្លេស 00217524។

[167] ឯកសារ D123/1/5.1a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00089776។

[168] ឯកសារD1.3.12.1 កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, នៅត្រង់ ឯកសារភាសាអង់គ្លេស 00217526, 00217547។

ព្រះ និងស្រុកក្រឡាញ់[169]។ ទំនប់នេះត្រូវបានភ្ជាប់ទៅនឹងប្រឡាយជាច្រើន ដែលហូរទៅទិសខាងត្បូង ពីឃុំស្ពានស្រែង (ស្រុកភ្នំស្រុក) កាត់តាមទឹកជួរ ភ្នំលាភ និងឃុំប្រាសាទ (ស្រុកព្រះនេត្រព្រះ) ទៅអាងស្តុកទឹកទំហំ១០គីឡូម៉ែត្រ នៅព្រៃរនាម[170]។ ទំនប់ស្ពានស្រែង និងប្រឡាយមួយក្នុងចំណោមប្រឡាយជាច្រើនរបស់វា អាចត្រូវបានចាប់ផ្តើមនៅក្នុងឆ្នាំ ១៩៧៧ មុនពេលកម្មាភិបាលនិរតីបានមកដល់[171] ប៉ុន្តែភាគច្រើននៃគម្រោងធារាសាស្ត្រ (រួមទាំងអាងស្តុកទឹក១០គីឡូម៉ែត្រ) ត្រូវ

---

[169] ឯកសារ **D119/97** កំណត់ហេតុស្តាប់ចម្លើយ លន់ រួប ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៧, ១៥ ។ ឯកសារ**D119/143** កំណត់ហេតុស្តាប់ចម្លើយ ឃៀង ឃុន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៧៦។

[170]ឯកសារ **D6.1.825** ការផ្សាយរបស់វិទ្យុកម្ពុជាប្រជាធិបតេយ្យ, ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៧៨, នៅត្រង់ឯកសារភាសាអង់គ្លេស 00170355 [យោងទៅរក "ប្រព័ន្ធធារាសាស្ត្រដែលភ្ជាប់ទៅស្ទឹងស្រែង"]។ ឯកសារ **D219/130** កំណត់ហេតុស្តាប់ចម្លើយ នៅ ឆាត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៩៥ ដល់១៩៧, ២០៨ ដល់២១៨ [រៀបរាប់ពី "ប្រឡាយស្ទឹងស្រែងចំនួនពីរ" ដែលជួបគ្នារវាងភូមិឆាលើ និងភូមិឆាក្រោម និងប្រឡាយអូរលាបពីរ]។ ឯកសារ **D119/93** កំណត់ហេតុស្តាប់ចម្លើយ ចាន់ ផន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៤ [បញ្ជាក់ថាការដ្ឋានទំនប់អូរលាភគឺនៅខាងត្បូងផ្លូវជាតិលេខ ៦ និងមានចម្ងាយបីគីឡូម៉ែត្រខាងកើតភ្នំលាភ]។ ឯកសារ **D219/397** កំណត់ហេតុស្តាប់ចម្លើយ ប៊ិន សុខ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥ ដល់៦ [ប្រឡាយអូរលាភឆ្លងកាត់ "ខាងជើងរហូតដល់ស្ពានស្រែង"]។ ឯកសារ D106/10 កំណត់ហេតុស្តាប់ចម្លើយ រឹម សឿត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ29 [អាងស្តុកទឹកព្រៃរនាមមានទំហំ១០គីឡូម៉ែត្រ គុណ១០គីឡូម៉ែត្រ]។ឯកសារ **D119/92** កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ តៅ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣១ ដល់៣២ [អ្នកស៊ើបអង្កេតក.ស.ច.ស បានអះអាងថា ប្រឡាយអូរលាភ និងទំនប់ស្ពានស្រែង គឺជាផ្នែកនៃការដ្ឋានតែមួយ]. ទោះបីជាសាក្សីខ្លះបានប្រើប្រាស់ឈ្មោះស្ពានស្រែង និងអូរលាភជំនួសគ្នាទៅវិញទៅមកក៏ដោយ តែមានអ្នកខ្លះបានយោងទៅរកផ្នែកខាងជើងនៃគម្រោង ថាស្ពានស្រែង និងផ្នែកខាងត្បូងថាអូរលាភ។ សូមមើលជាឧទាហរណ៍, ឯកសារ **D119/98** កំណត់ហេតុស្តាប់ចម្លើយ កោ ឡេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៧ ដល់៣០ [រៀបរាប់ពីស្ពានស្រែងថាជាការចាប់ផ្តើមនៅស្រុកភ្នំស្រុក និងអូរលាភថាជាអាងស្តុកទឹកនៅព្រៃរនាម]។ ឯកសារ **D219/127** កំណត់ហេតុស្តាប់ចម្លើយ ប្រាំង សាល ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ១៩ [ប្រឡាយអូរលាភ "ស្ថិតនៅខាងត្បូងនៃផ្លូវជាតិលេខ ៦"]។

[171] ឯកសារ**D219/149** កំណត់ហេតុស្តាប់ចម្លើយ ជុំ ជឹម ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៩ដល់១២។ ឯកសារ **D119/40** កំណត់ហេតុស្តាប់ចម្លើយ ឆាយ ផន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៥។ ឯកសារ **D1.3.10.1** របាយការណ៍ប្រចាំសប្តាហ៍របស់គណៈតំបន់ ៥, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៧៧, នៅត្រង់ ឯកសារភាសាអង់គ្លេស 00342719 ["នៅស្រុកព្រះនេត្រព្រះ សង្កាត់ប្រាសាទបានសម្រុកកសាងបញ្ចប់ប្រឡាយមួយ ដែលមានប្រវែង៥០០ម៉ែត្រ ដែលមានមាត់លើទទឹង១២ម៉ែត្រ និងបាតក្រោមទទឹងពីរម៉ែត្រ មានជម្រៅបួនម៉ែត្រ ហើយត្រូវជីកពីទន្លេស្ពានស្រែង រហូតដល់ទំនប់នៅជិតវត្តឆា"]។

បានកសាងឡើងនៅឆ្នាំ ១៩៧៨ ហើយត្រូតពិនិត្យមើលដោយ អ៊ឹម ចែម[172]។ មនុស្សជាងមួយម៉ឺននាក់ធ្វើការនៅការដ្ឋានទាំងនេះ[173]។

36. ទោះបីជាអ៊ឹម ចែមបានអះអាងថា ប្រជាជននៅក្នុងស្រុករបស់គាត់យល់ស្រប ជាមួយគម្រោងការងារទាំងអស់នេះ ហើយ "រីករាយ" និងបំពេញការងារ "យ៉ាងធូន់ធូរទាំងថ្ងៃ ទាំងយប់ ដោយមិនមានការត្រួតពិនិត្យមើល" ដើម្បីគោរពតាមពេលវេលាកំណត់ក៏ដោយ[174] តែការស៊ើបអង្កេតរបស់ ក.ស.ច.ស មិនបានគាំទ្រដល់ការអះអាងរបស់គាត់ឡើយ។ សាក្សីពីរនាក់ដែលធ្វើការនៅទំនប់ស្ពានស្រែង និងទំនប់ត្រពាំងថ្ម សាក្សីម្នាក់ដែលជាប្រធានកងកម្មករ ២០០នាក់ បានរៀបរាប់ពី "កម្មករដែលស្គមស្គាំង" ដែលព្យាយាមរត់ចេញពីការដ្ឋាន ប៉ុន្តែត្រូវបានកងកម្លាំងរបស់អ៊ឹម ចែម ចាប់ខ្លួន

[172] ឯកសារ **D119/121** កំណត់ហេតុស្ដាប់ចម្លើយ កោ ឡែន ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៣៨ ["ទំនប់ស្ពានស្រែង ត្រូវបានបញ្ចប់នៅក្នុងអំឡុងខែមីនា ឬមេសា ឆ្នាំ ១៩៧៨ ហើយយើងទៅធ្វើការនៅការដ្ឋានភ្នំលាភ អំឡុងខែមិថុនា ឬកក្កដា ឆ្នាំ ១៩៧៨"], ឆ ៣៩ [ភ្នំលាភស្ថិតក្រោមការគ្រប់គ្រងរបស់អ៊ឹម ចែម]។ ឯកសារ **D119/93** កំណត់ហេតុស្ដាប់ចម្លើយ ចាន់ ផន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៦ ដល់១៧ [សាក្សីធ្វើការនៅទំនប់អូរលាភក្នុងឆ្នាំ ១៩៧៨ និងបានបញ្ជាក់ថា ចែម និងសឿន គ្រប់គ្រងការដ្ឋាន]។ ឯកសារ **D219/397** កំណត់ហេតុស្ដាប់ចម្លើយ ប៊ិន សុខ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤ ដល់៦ [រៀបរាប់ពីប្រឡាយអូលាភថា ចែម "បង្គាប់ឱ្យប្រជាជនជីក"]។ ឯកសារ **D67.9** កិច្ចសម្ភាសន៍ជាមួយ ឈីត យឿក ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ឯកសារភាសាអង់គ្លេស 00731142 [ប្រឡាយនៅខាងកើតភ្នំលាភ]។ ឯកសារ D119/110 កំណត់ហេតុស្ដាប់ចម្លើយ ជុំ កន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៦៥ដល់៧០។ ឯកសារ D67.10 កំណត់ហេតុស្ដាប់ចម្លើយ មុន មុត ដោយ ក.ស.ច.ស នៅត្រង់ឯកសារភាសាអង់គ្លេស 00731175, 00731186។ ឯកសារ D119/65 កំណត់ហេតុស្ដាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១២៤, ១២៨ ។ ឯកសារ **D6.1.813** ការផ្សាយរបស់វិទ្យុកម្ពុជាប្រជាធិបតេយ្យ, ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៧៧, នៅត្រង់ឯកសារភាសាអង់គ្លេស 00168507 [យោងទៅលើផែនការកសាងប្រឡាយ នៅជុំវិញស្ទឹងស្រែង ដើម្បីប្រែក្លាយតំបន់នេះទៅជាអាងស្តុកទឹកទំហំ១០គីឡូម៉ែត្រ"]។ ឯកសារ **D1.3.30.19** របាយការណ៍ពីលេខាភូមិភាគពាយ័ព្យ ញឹម, ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៨, នៅត្រង់ឯកសារភាសាអង់គ្លេស 00185217 ["ការកសាងអាងស្តុកទឹក មកពីស្ពានស្រែង រហូតដល់ទួលភ្នំស្រុក ជិតបញ្ចប់ហើយ នៅសល់តែទ្វាទឹកដែលមិនទាន់ធ្វើ"]។

[173] ឯកសារ D119/110 កំណត់ហេតុស្ដាប់ចម្លើយ ជុំ កន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤៨ ដល់៤៩ ["ប្រជាជនរាប់ម៉ឺននាក់ត្រូវបានប្រមូលផ្តុំពីភូមិនានា នៅក្នុងខេត្តទាំងមូល"]។ ឯកសារ **D119/93** កំណត់ហេតុស្ដាប់ចម្លើយ ចាន់ ផន ដោយ ក.ស .ច.ស នៅត្រង់ចម្លើយ ២៥ ["កម្មកររាប់ពាន់នាក់"]។ ឯកសារ **D219/1** កំណត់ហេតុស្ដាប់ចម្លើយ យូ មុត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៨៥។

[174] ឯកសារ D1.3.12.1 កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, នៅត្រង់ ឯកសារភាសាអង់គ្លេស 00217524-25។

ហើយបញ្ជូនត្រឡប់ទៅវិញ[175]។ ប្រធានកងបានរៀបរាប់ពីការដែលអ៊ឹម ចែម "ឲ្យពួកយើងធ្វើការធ្ងន់ នៅពេលដែលគាត់មកត្រួតពិនិត្យមើលការដ្ឋាន" ហើយបានបញ្ជាក់ថាកម្មករដែលមានកំហុសខ្លាចគាត់ខ្លាំង ដោយសារតែអ្នកដែលធ្វើការយឺត ត្រូវបានបញ្ជូនទៅរៀនសូត្រ និងអ្នកដែលត្រូវគេចាត់ទុកថាមាន "និន្នាការប្រឆាំងអង្គការ" ត្រូវបានគេសម្លាប់ចោល[176]។ គាត់ក៏បានបញ្ជាក់ផងដែរថា ស្ថានភាពរស់នៅក្នុងការដ្ឋានរបស់អ៊ឹម ចែម គឺ"លំបាកជាងមុន" ហើយ "ពេលខ្លះយើងហូបមិនគ្រប់គ្រាន់ទេ"[177]។

37. សាក្សីដទៃទៀតបានអះអាងពីស្ថានភាពអមនុស្សធម៌ នៅការដ្ឋានស្ពានស្រែង។ ការងារបានចាប់ផ្ដើមឡើងនៅម៉ោង៥ព្រឹក ហើយបន្តរហូតដល់ម៉ោង១០យប់ ឬក៏យូរជាងនេះទៀត[178] ដោយមិនមានថ្ងៃឈប់សម្រាកឡើយ[179]។ ផែនការការងារដែលត្រូវបានកំណត់ ហើយកម្មករត្រូវបានតម្រូវឲ្យរែកដី៣ម៉ែត្រគូបកន្លះ ក្នុងមួយថ្ងៃ[180]។ របបអាហារមិនគ្រប់គ្រាន់[181] ហើយចំពោះអ្នកឈឺ និងអ្នកដែលធ្វើ

---

[175] ឯកសារ **D119/94** កំណត់ហេតុស្តាប់ចម្លើយ ប៊ូ ម៉ៅ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៩ ដល់៣២ ។ ឯកសារ **D119/121** កំណត់ហេតុស្តាប់ចម្លើយ កោ ឡែន ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ២៦ ដល់៣០ [បញ្ជាក់ថាគាត់ត្រូវបានជូនដំណឹងអំពីការចាប់ខ្លួនកម្មករទាំងអស់នោះ ដោយនិរសាររបស់ចែម ប៉ុន្តែក៏បានអះអាងផងដែរថា កម្មករដែលស្គមខ្លាំងពេក មិនអាចធ្វើការកើតត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ឬបញ្ជូនត្រឡប់ទៅសហករណ៍របស់ពួកគេ], ឆ ៣២ [បញ្ជាក់ថាការរត់គេចរបស់កម្មករត្រូវបានរាយការណ៍ទៅ អ៊ឹម ចែម ដែលបន្ទាប់មកនឹងបញ្ជាទៅឈ្លប "ឲ្យស្រាវជ្រាវរកអ្នករត់គេចខ្លួន ហើយនាំពួកគេត្រឡប់មក" ការដ្ឋានវិញ]. សូមមើលផងដែរ ឯកសារ **D5/1616/1** ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឈិន សាំង នៅត្រង់ឯកសារភាសាអង់គ្លេស 01092560-61 [កម្មករដែលព្យាយាមរត់ចេញពីការដ្ឋាន ត្រូវបានបញ្ជូនទៅភ្នំត្រយោង តាមបញ្ជារបស់ចែម]។

[176] ឯកសារ **D119/98** កំណត់ហេតុស្តាប់ចម្លើយ កោ ឡេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣២ ដល់៣៥, ៤១។

[177] ឯកសារ **D119/98** កំណត់ហេតុស្តាប់ចម្លើយ កោ ឡេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤២។

[178] ឯកសារ **D119/93** កំណត់ហេតុស្តាប់ចម្លើយ ចាន់ ផន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៦ [រៀបរាប់ពីរយៈពេលដែលការងារបន្តរហូតដល់ពេលយប់]។ ឯកសារ D106/10 កំណត់ហេតុស្តាប់ចម្លើយ រឹម សឿត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៧ [ការងារនៅការដ្ឋានព្រៃរនាមចាប់ផ្ដើមនៅម៉ោង ១រំលងអាធាត្រ ហើយបញ្ចប់នៅ ម៉ោង ៨ ឬ៩យប់]។ ឯកសារ D119/42 កំណត់ហេតុស្តាប់ចម្លើយ គ្រិត រ៉េត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៣។ ឯកសារ **D5/1360/1** ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឈិន ភួង។

[179] ឯកសារ **D119/93** កំណត់ហេតុស្តាប់ចម្លើយ ចាន់ ផន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៧។

[180] ឯកសារ D106/10 កំណត់ហេតុស្តាប់ចម្លើយ រឹម សឿត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៨។ ឯកសារ **D119/93** កំណត់ហេតុស្តាប់ចម្លើយ ចាន់ ផន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៦ [ផែនការដំបូងគឺ២ម៉ែត្រគូប ក្នុងមួយថ្ងៃ ប៉ុន្តែក្រោយមកបានកើនឡើងដល់៣ ទៅ៥ម៉ែត្រគូប]។ ឯកសារ **D119/153** កំណត់ហេតុស្តាប់ចម្លើយ គង់ រិន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៩ [បញ្ជាក់ថាចែម "កំណត់ផែនការការងារបីម៉ែត្រគូបដីក្នុងមួយថ្ងៃ"]។ ឯកសារ **D219/175** កំណត់ហេតុ

មិនគ្រប់តាមផែនការ[182]។ មានអ្នកស្លាប់ដោយធ្វើការធ្ងន់ហួស ដោយសារការបាក់កម្លាំង និងភាពអត់ឃ្លាន ព្រមទាំងមានកម្មករដែលត្រូវបានចាប់ខ្លួន និងបាត់ខ្លួន[183]។ ពួកឈ្លបនៅយាមកម្មករ ដើម្បីកុំឱ្យពួកគេអាចរត់គេចបាន[184]។

---

ស្តាប់ចម្លើយ ហង្ស ហ៊ន ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ២៧។ ឯកសារ **D5/937/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ផុន ផា។ ឯកសារ **D5/1360/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឈិន ភួង។ ឯកសារ **D5/962/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អៀម វុយ [បីម៉ែត្រគូបក្នុងមួយថ្ងៃ]។ ឯកសារ **D5/1624/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ព្រីក សាវាញ [បីម៉ែត្រគូបក្នុងមួយថ្ងៃ]។ ឯកសារ **D5/928/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ រស់ ធន់ [បួនម៉ែត្រគូបក្នុងមួយថ្ងៃ]. សម្រាប់ក្រុមដែលបន្តធ្វើការនៅប្រឡាយនៅរដូវវស្សា ផែនការការងារនិងម៉ោងការងារ ត្រូវបានកាត់បន្ថយ។ ឯកសារ **D219/130** កំណត់ហេតុស្តាប់ចម្លើយ នៅ ឆាត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៣៨ ដល់២៣៩។

[181] ឯកសារ **D219/130** កំណត់ហេតុស្តាប់ចម្លើយ នៅ ឆាត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៤០ ដល់២៤២ [កម្មករទទួលបានអាហារពីរពេលក្នុងមួយថ្ងៃ ដែលរួមមាន "សម្លរត្រកួន" និង "បបរពីរវែក"]។ ឯកសារ **D119/153** កំណត់ហេតុស្តាប់ចម្លើយ គង់ វិន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២០ ["បបររាវមួយវែកក្នុងមួយពេល"]។ ឯកសារ **D119/98** កំណត់ហេតុស្តាប់ចម្លើយ កោ ឡេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤២។ ឯកសារ **D219/1** កំណត់ហេតុស្តាប់ចម្លើយ យូ មុត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៨៤។ ឯកសារ D106/10 កំណត់ហេតុស្តាប់ចម្លើយ រឹម សឿត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៦។ ឯកសារ D119/42 កំណត់ហេតុស្តាប់ចម្លើយ គ្រិត រ៉េត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៣។ ឯកសារ **D5/935/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ រស់ អិត [អង្ករមួយកំប៉ុងសម្រាប់កម្មករ២០នាក់]។ ឯកសារ **D5/928/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ រស់ ធន់ ["បបររាវ"]. សូមមើលផងដែរ ឯកសារ **D219/253** កំណត់ហេតុស្តាប់ចម្លើយ សាន ហាវ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៤ [ស្ថានភាពការងារនៅក្រោមថែម "គឺអាក្រក់ខ្លាំង" ហើយកម្មករបានទទួលត្រឹម "បបររាវដូចទឹក"។

[182] ឯកសារ **D219/130** កំណត់ហេតុស្តាប់ចម្លើយ នៅ ឆាត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៤៣ [អ្នកឈឺបានទទួល "ត្រឹមតែបបរមួយវែក"]។ ឯកសារ **D119/153** កំណត់ហេតុស្តាប់ចម្លើយ គង់ វិន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៩។ ឯកសារ **D5/1110/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អឿម ជា នៅត្រង់ឯកសារភាសាអង់គ្លេស 01025956 ។ ឯកសារ **D5/1030/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ែន ចាន់ធូ នៅត្រង់ឯកសារភាសាអង់គ្លេស 00991187។

[183] ឯកសារ D119/42 កំណត់ហេតុស្តាប់ចម្លើយ គ្រិត រ៉េត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២០ [បានឃើញ "មនុស្សជាច្រើន" ត្រូវបានចាប់ខ្លួន "ភាគច្រើននៅទំនប់ស្ពានស្រែង"]។ ឯកសារ **D119/94** កំណត់ហេតុស្តាប់ចម្លើយ ប៊ូ ម៉ៅ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥១។ ឯកសារ **D123/1/2.53** កំណត់ហេតុស្តាប់ចម្លើយ ប៊ូ ម៉ៅ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា, នៅត្រង់ឯកសារភាសាអង់គ្លេស 00969912-13 ["ប្រជាជនជាច្រើនបានស្លាប់" នៅអាងស្តុកទឹកអូរលោភ]។ ឯកសារ **D119/93** កំណត់ហេតុស្តាប់ចម្លើយ ចាន់ ផន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៩ ដល់៣០។ ឯកសារ **D219/253** កំណត់ហេតុស្តាប់ចម្លើយ សាន ហាវ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៤ ["ប្រជាជនជាច្រើនបានស្លាប់ដោយសារអត់អាហារ"]។

38. សាក្សីមួយចំនួនបានរៀបរាប់ពីលក្ខខណ្ឌការងារ និងការរស់នៅថាមានលក្ខណៈប្រសើរជាង ក្នុងពេលដែលការដ្ឋានស្ថិតក្រោមការត្រួតពិនិត្យ ពីកម្មាភិបាលភូមិភាគពាយ័ព្យ ហើយប្រែជាលំបាកជាងមុន នៅពេលកម្មាភិបាលនិរតីចូលមកគ្រប់គ្រង[185]។ ទោះបីជាអ៊ឹម ចែម បានអះអាងថាបានដោះស្រាយកង្វះអាហារនៅព្រះនេត្រព្រះក៏ដោយ[186] ប៉ុន្តែអ្នកនៅរស់រានមានជីវិតមកពីស្រុកនោះបានបញ្ជាក់ថា ភាពអត់ឃ្លានកាន់តែ "ធ្ងន់ធ្ងរ" នៅចុងឆ្នាំ ១៩៧៧ ហើយមនុស្សជាច្រើនបានស្លាប់[187]។

---

ឯកសារ **D219/397** កំណត់ហេតុស្តាប់ចម្លើយ ប៊ិន សុខ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣៥។ ឯកសារ **D5/880/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ែន បាន។ ឯកសារ **D5/937/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ផុន ផា។ ឯកសារ **D5/1251/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ាត់ ឈឿយ។ ឯកសារ **D5/1360/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឈិន ភួង។ ឯកសារ **D5/1093/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ Mles Oat [កម្មករឈើត្រូវបានចោទប្រកាន់ថា "ឈឺសតិអារម្មណ៍" ដោយអ៊ឹម ចែម ហើយត្រូវបានបញ្ជូនទៅភ្នំត្រយោង]. *សូមមើលផងដែរ* ឯកសារ **D119/131** កំណត់ហេតុស្តាប់ចម្លើយ ថាង ធុយ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៨៣ ដល់៩០ [បានរៀបរាប់ពីការសម្លាប់ស្ត្រីមានផ្ទៃពោះប្រាំនាក់ នៅទំនប់ត្រពាំងថ្ម ដែលមេកងរបស់គាត់ប្រាប់ថា ជាបញ្ជារបស់អ៊ឹម ចែម].

[184] ឯកសារ **D219/127** កំណត់ហេតុស្តាប់ចម្លើយ ប្រាំង សាល ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ១៦ [សក្ខីកម្មរបស់សមាជិកឈ្លបឃុំ ដែលត្រូវបានចាត់តាំងឱ្យយាមកម្មករ នៅប្រឡាយអូរលោភ]។ ឯកសារ **D119/93** កំណត់ហេតុស្តាប់ចម្លើយ ចាន់ ផន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៨។

[185] ឯកសារ **D119/98** កំណត់ហេតុស្តាប់ចម្លើយ កោ ឡេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤២។ ឯកសារ**D219/149** កំណត់ហេតុស្តាប់ចម្លើយ ជុំ ជឹម ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៨, ១៣, ១៦។ ឯកសារ **D119/155** កំណត់ហេតុស្តាប់ចម្លើយ ឡាច ឈាងឡុង ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣៧ [សក្ខីកម្មរបស់មេកងថា លក្ខខណ្ឌតម្រូវការងារបានកើនឡើង ហើយរបបអាហារថយចុះ ក្រោមការគ្រប់គ្រងរបស់កម្មាភិបាលនិរតី]។ ឯកសារ D219/361 កំណត់ហេតុស្តាប់ចម្លើយ លើយ តេះ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៨៧ ដល់៩០ [បានរៀបរាប់ពីចែម ដែលបង្កើនផែនការការងារពីមួយ ទៅបីម៉ែត្រគូបក្នុងមួយថ្ងៃ នៅត្រពាំងថ្ម]។ ឯកសារ **D219/130** កំណត់ហេតុស្តាប់ចម្លើយ នៅ ឆាត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១២០[បន្ទាប់ពីក្រុមនិរតីមកដល់ត្រពាំងថ្ម របបអាហារក្នុងក្រុមគាត់បានថយចុះ "ពីប្រាំកំប៉ុងអង្ករសម្រាប់មនុស្ស១០នាក់" ទៅត្រឹម "មួយកំប៉ុងអង្ករសម្រាប់មនុស្ស៣០នាក់"], ឆ ១៥៣ ["នៅពេលយាយ ចែម ទទួលខុសត្រូវ មនុស្សជាច្រើនត្រូវបានសម្លាប់"]។ ឯកសារ **D119/93** កំណត់ហេតុស្តាប់ចម្លើយ ចាន់ ផន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១១ ដល់១២។ ឯកសារ **D119/139** កំណត់ហេតុស្តាប់ចម្លើយ ម៉ុន មុត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤៧។

[186] ឯកសារ D123/1/5.1a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ នៅត្រង់ ឯកសារភាសាអង់គ្លេស 00089777, 00089779-80។ ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ ឯកសារភាសាអង់គ្លេស 00951805 ["នៅពេលខ្ញុំមកដល់ ខ្ញុំឱ្យពួកគេទៅក្រៅដើម្បីស្វែងរកអាហារខ្លួនឯង។ ខ្ញុំផ្តល់អង្ករដល់ពួកគេនៅពេលពួកគេត្រូវការ"]។

[187] ឯកសារ **D219/359.1** របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ស្តីពីការសម្ភាសន៍ ពុំ គោ, នៅត្រង់ឯកសារភាសាអង់គ្លេស 01112059។ ឯកសារ **D219/152** កំណត់ហេតុស្តាប់ចម្លើយសាក្សី មេត ឌួង ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ

សារទូលេខាថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ មកពីមន្ទីរភូមិភាគពាយ័ព្យ (ម៥៦០) បានរាយការណ៍ថាប្រជាជនទូទៅ "បានរត់គេចខ្លួនម្ដងមួយៗ" ពីស្រុកព្រះនេត្រព្រះ[188]។ នៅក្នុងកិច្ចប្រជុំមួយនាឆ្នាំ ១៩៧៨ នៅបាត់ដំបង តា ម៉ុក "បានជេរយាយចែមដែលបង្អត់អាហារប្រជាជន ដែលស្ថិតក្រោមការបញ្ជារបស់គាត់"[189]។

39. មុនពេលដែលគាត់មកធ្វើជាប្រធានគុកភ្នំត្រយោង ទុំ សឿនត្រូវបានអ៊ឹម ចែមតែងតាំងជាប្រធានកងចល័ត ដែលមានមនុស្ស ៣០០នាក់ ដោយធ្វើការនៅប្រឡាយទាំងនេះ[190]។ សឿនបានផ្ដល់សក្ខីកម្មថា ប្រឡាយត្រូវបានសាងសង់ឡើងដោយដៃទាំងស្រុង ដោយមិនមានប្រើគ្រឿងចក្រអ្វីឡើយ ហើយមានការខ្វះខាតអាហារនៅក្នុងកងចល័ត[191]។ គាត់បានទទួលស្គាល់ថាប្រជាជនមិនមានសិទ្ធិ ត្រលប់ទៅភូមិរបស់ពួកគេទេ ប្រសិនបើពួកគេមិនចង់ធ្វើការនៅប្រឡាយ ហើយថាអ្នកណាដែលគោរពតាម

---

៨ ដល់៩ [សក្ខីកម្មរបស់បុគ្គលិកពេទ្យថា មានមនុស្សជាច្រើនស្លាប់ដោយសារអត់អាហារ ក្រោយពេលកម្មាភិបាលនិរតីមកដល់]។ ឯកសារ D219/294 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥៨។ ឯកសារ **D119/98** កំណត់ហេតុស្តាប់ចម្លើយ កោ ឡេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៣ ["ក្រោមការគ្រប់គ្រងរបស់ក្រុមនិរតី ស្ថានភាពគឺលំបាកខ្លាំងដោយសារតែយើងមិនមានអាហារគ្រប់គ្រាន់"]។ ឯកសារ **D119/19** កំណត់ហេតុស្តាប់ចម្លើយ ផន មុន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៤ [របបអាងហារកាន់តែអាក្រក់ ក្រោយពេលនិរតីមកដល់]។ ឯកសារ **D219/130** កំណត់ហេតុស្តាប់ចម្លើយ ឆៅ ឆាត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៩២ ដល់៩៤ [របបអាហារត្រូវបានក្រុមនិរតីកាត់បន្ថយ, "ប្រជាជនអត់អាហារ" ហើយអ្នកដែលជីកដំឡូងដើម្បីហូប "ត្រូវគេចាប់ខ្លួននិងសម្លាប់"]។ ឯកសារ D106/10 កំណត់ហេតុស្តាប់ចម្លើយ រឹម សឿត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣១ ["នៅពេលនិរតីមកគ្រប់គ្រងយើងបានត្រឹមបបរ... របបអង្ករមួយកំប៉ុងសម្រាប់មនុស្ស១០នាក់"]។ ឯកសារ **D119/154** កំណត់ហេតុស្តាប់ចម្លើយ អ៊ីវ ម៉ារា ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ៤២ [នៅក្រោមកម្មាភិបាលនិរតី បានត្រឹម "បាយមួយស្លាបព្រា" ក្នុងមួយថ្ងៃ]។

[188] ឯកសារ **D6.1.794** ទូរលេខសាន ផ្ញើជូនបងញ៉ឹម, ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧។ សូមមើលផងដែរ ឯកសារ D123/1/5.1b បទសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ នៅត្រង់ឯកសារភាសាអង់គ្លេស 00951809-10 [ទទួលស្គាល់ថាប្រជាជន "រត់គេចចេញពីស្រុកខ្ញុំ"]។

[189] ឯកសារ D219/294 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥៨ [សក្ខីកម្មរបស់អតីតលេខាស្រុកបវិល]។

[190] ឯកសារ **D119/65** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ៩៦ ["យាយ ចែម តែងតាំងខ្ញុំឲ្យដឹកនាំកងចល័ត ទៅជីកប្រឡាយនៅស្រុកព្រះនេត្រព្រះ"], ឆ ១១១, ១២២។ ឯកសារ D123/1/5.1a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹម ចែម, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ នៅត្រង់ឯកសារភាសាអង់គ្លេស 00089774 [បានកំណត់ថាសឿនជាបុគ្គលម្នាក់ដែលធ្វើការឲ្យគាត់នៅការដ្ឋានទំនប់]។ ឯកសារ **D119/93** កំណត់ហេតុស្តាប់ចម្លើយ ចាន់ ផន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៧ [សឿន និងយាយ ចែម ទទួលខុសត្រូវលើការដ្ឋានទំនប់អូរលាភ]។

[191] ឯកសារ **D119/65** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១០៧។

បញ្ហា នឹងត្រូវបញ្ជូនទៅរៀនសូត្រ[192]។ គាត់បានបញ្ជាក់ថាមាន "មនុស្សរាប់ពាន់នាក់" ធ្វើការនៅការដ្ឋាន ហើយកងចល័តទាំងអស់ត្រូវរាយការណ៍ទៅអ៊ឹម ចែម ហើយគាត់មកត្រួតពិនិត្យមើលការដ្ឋាន រៀងរាល់ពីរទៅបីថ្ងៃម្តង[193]។

40. សាក្សីដទៃទៀតក៏បានអះអាងពីវត្តមានរបស់អ៊ឹម ចែម នៅការដ្ឋានស្ពានស្រែង-អូរលាភផងដែរ[194]។ សាក្សីម្នាក់បានរៀបរាប់ពីកិច្ចប្រជុំ ដែលចូលរួមដោយអ្នកតំណាង មកពីស្រុកទាំងអស់នៅក្នុងតំបន់ ៥ ដែលនៅក្នុងកិច្ចប្រជុំនេះអ៊ឹម ចែម "បាននិយាយអំពីការវាយប្រយុទ្ធដូចព្យុះ ដើម្បីសម្រេចផែនការការងារ ហើយបាននិយាយថាប្រសិនបើមិនបានសម្រេចគោលដៅទេ យើងនឹងត្រូវទទួលទណ្ឌកម្ម"[195]។ បន្ទាប់មកគាត់ក៏បានឃើញកម្មករបីនាក់ ត្រូវបានចាប់ខ្លួនយកទៅ ដោយសារតែធ្វើការមិនបានគ្រប់ផែនការ[196]។ អតីតនីរសារបស់អ៊ឹម ចែម បានផ្តល់សក្ខីកម្មថាកម្មករ នៅការដ្ឋានប្រឡាយដែលត្រូវគេចាត់ទុកថា "ខ្ជិលឬខ្សោយ" ត្រូវបានចាប់ខ្លួនហើយបញ្ជូនទៅភ្នំត្រយោង ដើម្បីវាយចោល[197]។ សាក្សីម្នាក់ទៀតបានរៀបរាប់ពីមនុស្ស៨០ ទៅ៩០នាក់ដែលបាននិយាយប្រឆាំងអង្គការ

---

[192] ឯកសារ **D119/65** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១៣៨ ដល់១៤០។

[193] ឯកសារ **D119/65** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១១២, ១២៣ ដល់១២៤, ២០៧។

[194] ឯកសារ **D119/93** កំណត់ហេតុស្តាប់ចម្លើយ ចាន់ ផន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២២ ដល់២៣ [បានឃើញអ៊ឹម ចែម នៅការដ្ឋានអូរលាភពីរដង "អមដំណើរដោយទាហានប្រដាប់ដោយអាវុធ ៥ទៅ១០នាក់"]។ ឯកសារ **D119/98** កំណត់ហេតុស្តាប់ចម្លើយ កោ ឡេង ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣២ [ប្រធានក្រុមបានឃើញចែម "ត្រួតពិនិត្យការដ្ឋាន" ហើយពេលខ្លះជួយរែកដី]។ ឯកសារ D106/10 កំណត់ហេតុស្តាប់ចម្លើយ រីម សឿត ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៣ ដល់២៥។ឯកសារ **D119/69** កំណត់ហេតុស្តាប់ចម្លើយ គ្រួច ទឹម ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៣៩ ដល់១៤០ [បញ្ជាក់ថាអ៊ឹម ចែម ដឹកនាំការប្រជុំនៅស្ពានស្រែង ហើយ "ជំរុញពួកយើងឲ្យប្រឹងធ្វើការកាន់តែខ្លាំង និងកាន់តែលឿន"]។ ឯកសារ D67.10 កំណត់ហេតុស្តាប់ចម្លើយ មុន មុត ដោយ ក.ស.ច.ស នៅត្រង់ឯកសារភាសាអង់គ្លេស 00731175, 00731186។

[195] ឯកសារ **D119/93** កំណត់ហេតុស្តាប់ចម្លើយ ចាន់ ផន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៩ ដល់២០។ សូមមើលផងដែរ ឯកសារ D119/110 កំណត់ហេតុស្តាប់ចម្លើយ ជុំ កន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥១, ៥៥ ដល់៥៧ [សក្ខីកម្មរបស់មេឃុំភ្នំលាភដែលថាមេភូមិ និងមេឃុំត្រូវបានព្រមានថា "ពួកគេនឹងមានបញ្ហា" ប្រសិនបើកងរបស់ពួកគេ មិនអាចសម្រេចផែនការ]។ ឯកសារ D106/4 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ខន ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ២២។

[196] ឯកសារ **D119/93** កំណត់ហេតុស្តាប់ចម្លើយ ចាន់ ផន ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៩ ដល់៣០។

[197] ឯកសារ **D219/397** កំណត់ហេតុស្តាប់ចម្លើយ ប៊ិន សុខ ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣៤ ដល់៣៥។

នៅក្នុងកិច្ចប្រជុំមួយដែលដឹកនាំដោយតា ម៉ុក និងអ៊ឹម ចែម ហើយត្រូវបានគេដឹកតាមឡានយកទៅសម្លាប់ នៅត្រពាំងថ្ម[198]។

41. នៅភ្នំត្រយោង អ្នកទោសល្មើសធ្ងន់ធ្ងរត្រូវគេតម្រូវឲ្យធ្វើការ នៅក្នុងការដ្ឋានវាយថ្ម ដើម្បីជីកនិងវាយបំបែកថ្ម សម្រាប់យកមកសង់ទំនប់ និងទ្វារទឹក[199]។ នៅពេលយប់អ្នកទោសទាំងនោះ ត្រូវបានគេដាក់ខ្នោះជើងនៅក្នុងអគារមួយ នៅប៉ែកខាងជើងភ្នំត្រយោង[200] តាមបញ្ជារបស់អ៊ឹម ចែម[201]។

### ង. ការទទួលខុសត្រូវលើការរៀបការដោយបង្ខំ

42. អតីតកម្មាភិបាលនារីម្នាក់បានរៀបរាប់ពី ការចូលរួមរបស់អ៊ឹម ចែម នៅក្នុងការរៀបការដោយបង្ខំ ដោយបញ្ជាក់ថានារីត្រូវបានគេហៅ "ម្តងហើយម្តងទៀត" ឲ្យចូលរួមប្រជុំដែលក្នុងកិច្ចប្រជុំនោះ អ៊ឹម ចែម "ជំរុញឲ្យស្ត្រីទាំងអស់នោះរៀបការ"[202]។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានរៀបរាប់ ពីការ

---

[198] ឯកសារ **D119/66** កំណត់ហេតុស្តាប់ចម្លើយ ប៊ិន ហុយ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៥។

[199] ឯកសារ **D119/65** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១៥៤, ១៥៩, ១៦២, ១៦៨។ ។ ឯកសារ D106/7 កំណត់ហេតុស្តាប់ចម្លើយ ស៊ុម សល ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៤ដល់១៥ ["អ្នកទោសប្រុសត្រូវបានចាត់តាំងឲ្យបំបែកថ្ម ចំណែកអ្នកទោសស្រីត្រូវបានស្នើឲ្យធ្វើស្រែ"]។ ឯកសារ **D219/127** កំណត់ហេតុស្តាប់ចម្លើយ ប្រាំង សាល ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ២៩។ ឯកសារ **D119/159** កំណត់ហេតុស្តាប់ចម្លើយ ឡេង រឿន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៥១ ដល់៥២។

[200] ឯកសារ**D106/8** កំណត់ហេតុស្តាប់ចម្លើយ ធីប សំផាត ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ២១ [អ្នកទោសដែលជាប់ខ្នោះជើង ត្រូវបានឃុំឃាំងនៅអគារមួយ នៅខាងជើងភ្នំ]។ ឯកសារ D119/30 កំណត់ហេតុស្តាប់ចម្លើយ ភួន ស៊ុនទី ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៨ ដល់១៩ [ជាអ្នកជាប់ឃុំនៅភ្នំត្រយោងដែលជាប់ខ្នោះជើង ជាមួយអ្នកទោសបទល្មើសធ្ងន់ធ្ងរ៣០នាក់]។ ឯកសារ D106/7 កំណត់ហេតុស្តាប់ចម្លើយ ស៊ុម សល ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ១៥ [សក្ខីកម្មរបស់អតីតឆ្មាំថា អ្នកទោសបទល្មើសធ្ងន់ធ្ងរត្រូវបាន "ដាក់ខ្នោះដៃនៅក្នុងរោង ហើយមានការយាមកាម"]។ ឯកសារ **D219/230** កំណត់ហេតុស្តាប់ចម្លើយ លឿង រឿន ដោយ ក.ស.ច.ស, នៅត្រង់ចម្លើយ ១៥ ដល់១៦។ ឯកសារ **D119/94** កំណត់ហេតុស្តាប់ចម្លើយ ប៊ូ ម៉ៅ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៣៣ [សាក្សីត្រូវបានដាក់ខ្នោះជើងនៅក្នុងអគារឃុំឃាំងដែលមានបួនជួរ]។ ឯកសារ **D219/149** កំណត់ហេតុស្តាប់ចម្លើយ ជុំ ជឹម ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ២៤។ ឯកសារ **D219/102** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤១ ដល់៤៣ [ទទួលស្គាល់ថាអ្នកទោសបទល្មើសធ្ងន់ធ្ងរ ត្រូវបានដាក់ខ្នោះជើងនៅពេលយប់]។

[201] ឯកសារ **D219/102** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន ជាមួយ ក.ស.ច.ស នៅត្រង់ចម្លើយ ៤៥ [បញ្ជាក់ថាអ៊ឹម ចែម "នឹងសម្រេចថាតើត្រូវដាក់ខ្នោះជើងអ្នកទោស ឬអត់]។

[202] ឯកសារ D119/108 កំណត់ហេតុស្តាប់ចម្លើយ សុខ រុំ ដោយ ក.ស.ច.ស នៅ ត្រង់ចម្លើយ ១០៨ ដល់១១០ [ក៏បានបញ្ជាក់ផងដែរថាអ្នកណាដែលបដិសេធមិនព្រមរៀបការ "ប្រាកដជាត្រូវចាប់ខ្លួន"]។

ត្រូវបានបង្ខំឲ្យរៀបការក្នុងពិធីរៀបការរួមគ្នា ដែលមានដល់ទៅ៨៥គូ ហើយស្ថិតក្រោមការដឹកនាំរបស់អ៊ឹម ចែម[203]។ ដើមបណ្ដឹងរដ្ឋប្បវេណីនោះបញ្ជាក់ថា គាត់ចូលរួមក្នុងពិធីរៀបការដោយសារតែគេគម្រាមសម្លាប់គាត់ ហើយថាអ៊ឹម ចែម បញ្ជាឲ្យឈ្លបលួចមើលប្ដីប្រពន្ធដែលរៀបការហើយ ហើយត្រូវសម្លាប់ចោលអ្នកដែលមិនព្រមផ្សំដំណេក[204]។

### ច. ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី បានចោទប្រកាន់ពីឧក្រិដ្ឋកម្មនៅព្រះនេត្រព្រះ

43. ទោះបីជា អ៊ឹម ចែមអះអាងថាគាត់ត្រូវបាន "អបអរសាទរ" អរគុណ និងស្រឡាញ់ដោយប្រជាជននៅស្រុកព្រះនេត្រព្រះចំពោះការខិតខំប្រឹងប្រែងរបស់គាត់ ក្នុងការលើកកម្ពស់ជីវភាពរបស់ប្រជាជនទាំងនោះក៏ដោយ[205] តែសាក្សីដែលត្រូវបានស្ដាប់ចម្លើយដោយ ក.ស.ច.ស បាននិយាយប្រាប់នូវរឿងរ៉ាវផ្ទុយពីនេះ ដូចដែលបានលើកឡើងនៅផ្នែកខាងលើ។ ការពិតនៃកេរ្តិ៍ដំណែលរបស់អ៊ឹម ចែម ក៏មានឃើញផងដែរនៅក្នុង ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីយ៉ាងច្រើន ក្នុងសំណុំរឿង ០០៤ ដែលបានដាក់ពាក្យប្ដឹងអំពីឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តឡើងនៅស្រុកព្រះនេត្រព្រះ។ សហព្រះរាជអាជ្ញាអន្តរជាតិបានកំណត់អត្តសញ្ញាណ អ្នកដាក់ពាក្យសុំតាំងខ្លួនជាង១០០នាក់ ដែលបានរៀបរាប់ពីឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើង នៅក្នុងស្រុកនោះក្នុងអំឡុងពេលដែលអ៊ឹម ចែម ជាលេខាស្រុក។ (ឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងនោះ ត្រូវបានរៀបរាប់និងសង្ខេបនៅក្នុងឧបសម្ព័ន្ធ ខ)។ ភាគច្រើននៃជនរងគ្រោះទាំងអស់នោះ បានកំណត់អត្តសញ្ញាណចំឈ្មោះយ៉ាងជាក់ច្បាស់ អំពីអ៊ឹម ចែមថាជាបុគ្គលដែលទទួលខុសត្រូវ ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងប្រឆាំងពួកគាត់ និងសាច់ញាតិរបស់ពួកគាត់[206]។ ភាគច្រើនលើសលប់នៃអ្នកដាក់ពាក្យសុំតាំងខ្លួនជា

---

[203] ឯកសារ **D119/131** កំណត់ហេតុស្ដាប់ចម្លើយ ថាង ធុយ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៦៥ ដល់៧២។ សូមមើលផងដែរ **D5/1501/1** ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ស្រៀប សាមុត [រៀបរាប់ពីការរៀបការដោយបង្ខំ ដែលមានចំនួន២៨គូ ហើយស្ថិតក្រោមអធិបតីភាពរបស់ "សមមិត្តនារីចែម"]។ ឯកសារ **D5/1033/1** ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ រិទ្ធិ ធួង [ត្រូវបានសមមិត្តនារីចែមប្រាប់ថា គាត់ត្រូវតែរៀបការជាមួយបុរសម្នាក់]។

[204] ឯកសារ **D119/131** កំណត់ហេតុស្ដាប់ចម្លើយ ថាង ធុយ ដោយ ក.ស.ច.ស នៅត្រង់ចម្លើយ ៧៣ ដល់៧៤, ៧៧ ដល់៨២។

[205] សូមមើលជាឧទាហរណ៍, ឯកសារD1.3.12.1 កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧, នៅត្រង់ឯកសារភាសាអង់គ្លេស 00217521-22 ["ប្រជាជនអបអរការខិតខំប្រឹងប្រែងរបស់ខ្ញុំ និងសមិទ្ធផលរបស់ខ្ញុំ ដោយស្រែកថា៖ ឥឡូវយើងឃើញពន្លឺពិតនៃបដិវត្តហើយ"], 00217525 ["ពួកគេរីករាយជាមួយខ្ញុំ ហើយសូម្បីតែបច្ចុប្បន្នក៏ប្រជាជនទាំងនេះនៅបន្តទំនាក់ទំនងជាមួយខ្ញុំ"]។

[206] រាល់ឯកសារយោងចំពោះអ៊ឹម ចែម បែបនេះទាំងអស់ ត្រូវបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ ខ។

ដើមបណ្តឹងរដ្ឋប្បវេណី បើប្រៀបធៀបជាពិសេសជាមួយចំនួនដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់ទីតាំងឧក្រិដ្ឋកម្មក្នុងសំណុំរឿង ០០២[207] បានបង្ហាញពីផលប្រយោជន៍សាធារណៈយ៉ាងខ្លាំងក្លា ក្នុងការជំនុំជម្រះអ៊ឹម ចែម ចំពោះបទឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើង នៅក្នុងស្រុករបស់គាត់។

## IV. សារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិ

44. សហព្រះរាជអាជ្ញាអន្តរជាតិសូមលើកឡើងថាអ៊ឹម ចែម មិនមែនជា "មេដឹកនាំជាន់ខ្ពស់" នៃរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងអត្ថន័យនៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ឬកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.កឡើយ។ គាត់មិនមែនជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម ឬ គណៈកម្មាធិការអចិន្ត្រៃយ៍ បក្សកុម្មុយនីស្តកម្ពុជាឡើយ។ តួនាទីខ្ពស់បំផុតរបស់គាត់គឺលេខាស្រុក (កោះអណ្តែត និងព្រះនេត្រព្រះ) និងជាសមាជិកនៃគណៈកម្មាធិការ តំបន់១៣និងតំបន់១៥ រួមទាំងតួនាទីជាអនុលេខាតំបន់៥។ ទោះបីជាតួនាទីទាំងអស់នេះមានភាពសំខាន់ ដោយផ្តល់ដល់គាត់នូវការគ្រប់គ្រងទៅលើ កម្លាំងឈ្លប និងជីវិតរបស់ប្រជាជនស៊ីវិលរាប់ម៉ឺននាក់ក៏ដោយ តែគាត់ស្ថិតនៅក្រោមគណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការមជ្ឈិម លេខាភូមិភាគ និងលេខាតំបន់ នៅក្នុងឋានានុក្រមបក្សកុម្មុយនីស្តកម្ពុជា ហើយបើតាមទស្សនៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ គាត់មិនមែនជា "មេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ"ទេ។

45. ប៉ុន្តែសហព្រះរាជអាជ្ញាអន្តរជាតិសូមលើកឡើងថា អ៊ឹម ចែមស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងអត្ថន័យនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក។ ភស្តុតាងដែលបានប្រមូលក្នុងកិច្ចស៊ើបអង្កេតសំណុំរឿង ០០៤ រហូតមកដល់ពេលនេះ បានកំណត់ថាក្នុងនាមជាកម្មាភិបាលដែលមានឋានៈសំខាន់ របស់បក្សកុម្មុយនីស្តកម្ពុជា អ៊ឹម ចែមបានដើរតួនាទីយ៉ាងសំខាន់ក្នុងការ

[207] ជាឧទាហរណ៍ ដើមបណ្តឹងរដ្ឋប្បវេណី៥១នាក់ ត្រូវបានទទួលយកនៅក្នុងសំណុំរឿង ០០២ ពាក់ព័ន្ធទៅនឹងសហករណ៍ត្រាំកក់, ដើមបណ្តឹងរដ្ឋប្បវេណី៤៥នាក់ ត្រូវបានទទួលយក ពាក់ព័ន្ធទំនប់១មករា, ដើមបណ្តឹងរដ្ឋប្បវេណី៣១នាក់ ត្រូវបានទទួលយក ពាក់ព័ន្ធមន្ទីរសន្តិសុខភូមិភាគឧត្តរ, ដើមបណ្តឹងរដ្ឋប្បវេណី២៧នាក់ ត្រូវបានទទួលយក ពាក់ព័ន្ធមន្ទីរសន្តិសុខសង់ ដើមបណ្តឹងរដ្ឋប្បវេណី១៧នាក់ ត្រូវបានទទួលយក ពាក់ព័ន្ធស្រែអំបិលនិងមានដើមបណ្តឹងរដ្ឋប្បវេណីតែ៩នាក់ ត្រូវបានទទួលយក ពាក់ព័ន្ធការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង។ CF2-D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ៣២២, ៣៦៨, ៣៨២, ៣៩៩, ៤៨៨, ៥៨៨។ គួរកត់សម្គាល់ផងដែរថា មានយ៉ាងហោចណាស់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣០០ នាក់ ក្នុងសំណុំរឿង ០០៤ ដែលបានចោទប្រកាន់ពីឧក្រិដ្ឋកម្ម នៅក្នុងផ្នែកផ្សេងទៀត នៅក្នុងតំបន់៥ ដែលអ៊ឹម ចែមទទួលខុសត្រូវក្នុងនាមជាសមាជិកនៃគណៈតំបន់នោះ។

ប្រព្រឹត្ត ឧក្រិដ្ឋកម្មដែលបង្កផលប៉ះពាល់ដល់ជីវិតមនុស្សរាប់ម៉ឺននាក់ ហើយបង្កឲ្យបាត់បង់ជីវិតមនុស្សរាប់ពាន់នាក់។

46. អ៊ឹម ចែមមានការទទួលខុសត្រូវក្នុងកម្រិតខ្ពស់ នៅពេលគាត់បានចូលរួមក្នុងឧក្រិដ្ឋកម្មទាំងនេះ។ ក្នុងនាមជាលេខាស្រុកព្រះនេត្រព្រះ ពីខែមិថុនា ឆ្នាំ ១៩៧៧ ដល់ខែ មករា ឆ្នាំ ១៩៧៩ គាត់បានប្រើប្រាស់អំណាចសឹងតែទាំងស្រុង ទៅលើជីវិតរបស់ប្រជាជនប្រហែលមួយសែននាក់ នៅក្នុងស្រុករបស់គាត់។ ប្រជាជនទាំងនោះត្រូវទទួលរងការធ្វើការដោយបង្ខំ ក្នុងស្ថានភាពមួយដែលអាចចាត់ទុកថាជាការដាក់ឲ្យទៅជាទាសករ ដោយទទួលរងការខ្វះអាហារ ខ្វះថ្នាំសង្កូវ និងធ្វើការធ្ងន់ធ្ងរ ហើយប្រជាជនមិនបានទទួលសិទ្ធិមនុស្សជាសារវន្ត ដូចជាសេរីភាពក្នុងការផ្លាស់ទី សេរីភាពក្នុងការនិយាយស្ដី សេរីភាពក្នុងការបង្កើតសមាគម សេរីភាពលើជំនឿសាសនា និងជីវភាពគ្រួសារ។ អ្នកណាដែលមិនគោរពអំណាចរបស់គាត់ នឹងត្រូវចាប់ខ្លួន ហើយមនុស្សរាប់ម៉ឺននាក់ត្រូវបានសម្លាប់។

47. សិទ្ធិអំណាចរបស់អ៊ឹម ចែម រួមមានអំណាចក្នុងការបញ្ជាឲ្យចាប់ខ្លួន និងឃុំខ្លួននៅក្នុងមន្ទីរសន្តិសុខដែលនៅទីនោះការកាប់សម្លាប់គឺមានជាប្រចាំ។ គាត់ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើត និងដំណើរការមន្ទីរសន្តិសុខភ្នំត្រយោង ដែលជាមន្ទីរសន្តិសុខមួយ ក្នុងចំណោមមន្ទីរសន្តិសុខធំៗជាច្រើន នៅក្នុងកម្ពុជាប្រជាធិបតេយ្យ ដែលមានលទ្ធភាពផ្ទុកអ្នកទោស បានជាងមួយពាន់នាក់ក្នុងមួយពេលៗ។ ក្នុងអំឡុងពេលប្រតិបត្តិការមន្ទីរនេះរយៈពេល១៨ខែ មនុស្សរាប់ម៉ឺននាក់ត្រូវបានសម្លាប់។ ការចូលរួមរបស់ អ៊ឹម ចែម ក្នុងឧក្រិដ្ឋកម្មក៏រួមមានផងដែរការសម្លាប់ជាទ្រង់ទ្រាយធំ ទៅលើជនជាតិវៀតណាម និងអ្នកដែលជាប់ពាក់ព័ន្ធនឹងរបបចាស់ ដែលគាត់ជាអ្នករៀបចំ នឹងបញ្ជាការសម្លាប់នេះ។ គាត់ក៏មានតួនាទីយ៉ាងចម្បងផងដែរ នៅក្នុងការបោសសម្អាតភូមិភាគពាយ័ព្យ ដែលបណ្ដាលឲ្យមានការធ្វើទារុណកម្ម និងការសម្លាប់កម្មាភិបាលជាង១២០០ នាក់ នៅស២១ និងមនុស្សដែលមិនអាចរាប់បាននៅមន្ទីរសន្តិសុខតំបន់៥។

48. ក្នុងនាមជាសមាជិកគណៈកម្មាធិការតំបន់ ១៣ តាំងពីមុនឆ្នាំ ១៩៧៥ រហូតដល់ខែ មិថុនា ឆ្នាំ ១៩៧៧ និងជាសមាជិក (និងក្រោយមកជាអនុ) គណៈកម្មាធិការតំបន់៥ ពីខែ មិថុនា ឆ្នាំ ១៩៧៧ ដល់ពេលបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ អ៊ឹម ចែម បានរួមចំណែកក្នុងការសម្រេច និងអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា នៅតំបន់សំខាន់ៗចំនួនពីរក្នុងប្រទេសគឺ៖ តាកែវ និងបាត់ដំបង។ គាត់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយតា ម៉ុក និងបានដឹកនាំកិច្ចប្រជុំដែល កម្មាភិបាលស្រុក និងកម្មាភិបាលឃុំ ត្រូវបានបង្គាប់ឲ្យអនុវត្តគោលនយោបាយ ធ្វើការដោយបង្ខំ គោលនយោបាយចំពោះ

ខ្លាំង និងគោលនយោបាយចំពោះការរៀបការដោយបង្ខំរបស់បក្ស។ ហេតុដូច្នេះឥទ្ធិពល និងសិទ្ធិអំណាចរបស់អ៊ឹម ចែម គឺហួសឆ្ងាយពីកម្រិតស្រុកដែលគាត់ត្រូវទទួលខុសត្រូវទៅទៀត។

49. លើសពីនេះទៀតឧក្រិដ្ឋកម្មដែលអ៊ឹម ចែម ត្រូវទទួលខុសត្រូវគឺមិនមែនជាហេតុការណ៍ដាច់ដោយឡែកឡើយ តែវាជាឧក្រិដ្ឋកម្មដែលបានកើតឡើងជាបន្តបន្ទាប់ ពេញរយៈពេលក្នុងពេលដែលគាត់កាន់តួនាទីដែលមានសិទ្ធិអំណាចនេះ។ ឧក្រិដ្ឋកម្មទាំងអស់នេះបានកើតឡើង នៅការដ្ឋានដែលគាត់ខ្លួនឯងផ្ទាល់ បានត្រួតពិនិត្យមើល និងនៅមន្ទីរសន្តិសុខមួយដែលមានទីតាំង មិនដល់២០០ម៉ែត្រពីផ្ទះរបស់គាត់ ដែលអ្នកទោសពេលខ្លះត្រូវបានគេនាំយកមក មុនពេលបញ្ជូនទៅភ្នំត្រយោង។

50. សហព្រះរាជអាជ្ញាអន្តរជាតិទទួលស្គាល់ថា ការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺតិចជាងជនជាប់ចោទដែលកំពុងត្រូវបានជំនុំជម្រះ ក្នុងសំណុំរឿង ០០២ និងជនសង្ស័យដទៃទៀតក្នុងសំណុំរឿង ០០៣ និង០០៤។ ប៉ុន្តែកម្រិតនៃការទទួលខុសត្រូវរបស់គាត់ គឺប្រហាក់ប្រហែលនិងការទទួលខុសត្រូវរបស់កាំងហ្គេកអាវ ហៅឌុច ជាជនជាប់ចោទក្នុងសំណុំរឿង ០០១ ហើយប្រហែលជាធំជាងជនជាប់ចោទ អៀង ធីរិទ្ធក្នុងសំណុំរឿង ០០២។ ទោះបីជាឌុច មានតួនាទីផ្ទាល់ជាង និងកៀកជាង ក្នុងការសម្លាប់និងធ្វើទារុណកម្មនៅ ស២១ តែអ៊ឹម ចែម មានកម្រិតនៃសិទ្ធិអំណាចខ្ពស់ជាង ក្នុងការគ្រប់គ្រងលើការរស់នៅរបស់ជនស៊ីវិលច្រើនជាងច្រើនដង ហើយប្រើប្រាស់សិទ្ធិអំណាចទៅលើមន្ទីរសន្តិសុខមួយ ដែលចំនួននៃជនរងគ្រោះស្មើ ឬលើសចំនួនជនរងគ្រោះនៅស២១ ក្នុងអំឡុងពេលប្រតិបត្តិដែលតិចជាងខ្លាំង។ ទោះបីជាអៀង ធីរិទ្ធមានតួនាទីជារដ្ឋមន្ត្រី ហើយដើរតួនាទីនៅកម្រិតថ្នាក់ជាតិ ប៉ុន្តែអៀង ធីរិទ្ធមិនមានកងកម្លាំងឈ្លប ឬមន្ទីរសន្តិសុខនៅក្រោមការគ្រប់គ្រងផ្ទាល់របស់គាត់ទេ ហើយគាត់មានសិទ្ធិអំណាចតែទៅលើមនុស្សប្រហែល១២០០ ទៅ១៣០០នាក់ ហើយគាត់ជាប់ពាក់ព័ន្ធដោយផ្ទាល់ ក្នុងការចាប់ខ្លួនមនុស្សតិចតួចបំផុត ធៀបទៅនឹងអ៊ឹម ចែម។ ហេតុដូច្នេះការរួមចំណែករបស់អៀង ធីរិទ្ធចំពោះបទឧក្រិដ្ឋកម្មទាំងនេះ គឺមិនផ្ទាល់ និងមិនច្រើនដូចការរួមចំណែករបស់អ៊ឹម ចែម ក្នុងឧក្រិដ្ឋកម្មឡើយ។

51. ដោយផ្អែកលើភស្តុតាងនេះ សហព្រះរាជអាជ្ញាអន្តរជាតិពិចារណាថា អ៊ឹម ចែម មិនមានលក្ខណៈគ្រប់គ្រាន់ជាមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមឡើយ តែស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងអត្ថន័យនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក។ ការជំនុំជម្រះ អ៊ឹម ចែម ដែលជាកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលទទួលខុសត្រូវលើឧក្រិដ្ឋកម្ម ក្នុងទ្រង់

ទ្រាយធំ ដែលបង្កឲ្យមានការឈឺចាប់ចំពោះប្រជាជនកម្ពុជា ជាង១០០ ០០០នាក់ ហើយបណ្តាលឲ្យមានការស្លាប់មនុស្សរាប់ម៉ឺននាក់ នឹងជំរុញដល់ការស្វែងរកយុត្តិធម៌ ព្រមទាំងតាមគោលបំណងដែល អ.វ.ត.ក ត្រូវបានបង្កើតឡើង។

52. ប្រតិកម្មវិជ្ជមាននិងដោយសន្តិភាពរបស់ប្រជាជនកម្ពុជា ចំពោះការផ្តន្ទាទោសនួន ជា និងខៀវ សំផន ដែលជាមេដឹកនាំខ្ពស់បំផុតរបស់ខ្មែរក្រហម ដែលនៅរស់រានមានជីវិត បានបង្ហាញថាការជំនុំជម្រះទៅលើកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាមួយចំនួនតូច នឹងមិនមែនជាការគម្រាមកំហែងដល់សន្តិភាព និងសន្តិសុខកម្ពុជាឡើយ។ ផ្ទុយទៅវិញការជំនុំជម្រះបានបង្ហាញការចោទប្រកាន់បែបនេះ នឹងជួយលើកកំពស់ទស្សនៈរបស់ប្រជាជនកម្ពុជាថា បច្ចុប្បន្នពួកគាត់កំពុងរស់នៅក្នុងសង្គមមួយ ដែលគោលនយោបាយឧក្រិដ្ឋកម្មព្រៃផ្សៃ ដូចគោលនយោបាយដែលបង្កើតឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ នឹងមិនត្រូវបានទទួលការអត់ធ្មត់ទៀតឡើយ។

53. ហេតុដូច្នេះសហព្រះរាជអាជ្ញាអន្តរជាតិជឿជាក់ថា កិច្ចដំណើរការនីតិវិធីក្នុងការស៊ើបអង្កេត និងជំនុំជម្រះលើអ៊ឹម ចែម គឺជាការប្រើប្រាស់ដ៏សមស្របនូវឆន្ទានុសិទ្ធិ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយថាប្រសិនបើការជំនុំជម្រះនេះបន្តដំណើរទៅមុខ ការងាររបស់ អ.វ.ត.ក អាចត្រូវបានបញ្ចប់ក្នុងរយៈពេលដ៏សមស្របមួយ

ដោយសេចក្តីគោរព

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៥ | Nicholas KOUMJIAN<br>International Co-Prosecutor | ភ្នំពេញ | |